01448567 E1/331.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Apr-2017, 14:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣១២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew Boyle)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ (Mr.Victor KOPPE)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន (Mr. Arthur VERCKEN)

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ (Mr. Calvin SAUNDERS)

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ (Ms. Marie GUIRAUD)

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកកែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឈិត យឿក (2-TCW-937) | ខ្មែរ |
| លោក ឈុំ សេង (2-TCW-828) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឈិត យឿក** (2-TCW-937)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................................................................ទំព័រ ៣

សួរដោយលោក អាកទួរ វែកគែន ផ្តើមពី ....................................................................ទំព័រ ២៦

សួរដោយលោក គង់ សំអុន ផ្តើមពី ....................................................................ទំព័រ ២៨

**ការសួរសំណួរទៅសាក្សី៖ លោក ឈុំ សេង** (2-TCW-828)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................................ទំព័រ ៣៣

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ....................................................................ទំព័រ ៣៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ..........................................................ទំព័រ ៤៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ លើអង្គសេចក្តីពិនិត្យភស្តុតាងលើសំណុំរឿង០០២/០២។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឈិត យឿក បន្តបញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-828។ អង្គជំនុំជម្រះសូមជម្រាបជូនភាគីនិងសាធារណជនជ្រាបផងដែរថា នៅក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីនៅសវនាការថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ ដោយលោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិអវត្តមានដោយមូលហេតុមានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ ហើយបន្ទាប់ពីយើងពិភាក្សា ពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាន រហូតដល់ពេលណាដែលលោកចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅអង្គ ជំនុំជម្រះសាលាដំបូងនេះវិញបាន។ ហើយការសម្រេចនេះផ្អែកលើតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៣:៣៣]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់

សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ឈិត យឿក។ លោក និងមេធាវីប្រឹក្សាលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-828។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះ នឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅថ្ងៃនេះ មុនពេលមកផ្ដល់សក្ខីកម្ម ហើយសាក្សីក៏មានមេធាវីប្រឹក្សា លោក ឌុច ផារី ផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥។

[០៩:០៥:១៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះមានអាការៈឈឺចង្កេះខ្លាំង និងឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា

អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ឈិត យឿក។ ហើយដំបូងនេះ ចាប់ផ្តើមពីក្រុមមេធាវីការពារក្តី នួន ជា មុនមេធាវីការពារក្តី ខៀវ សំផន។ សូមអញ្ជើញបាទ!

[០៩:០៦:៤៤]

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរតិចតួចទៀតទេ។ ទាក់ទងទៅនឹងសក្ខីកម្មរបស់លោកដែលបានឆ្លើយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន។ ខ្ញុំសូមសួរលោកពាក់ព័ន្ធទៅនឹង តាវ៉ាល់ ហើយ និង តាហឿង -- តាវ៉ាល់ និង តាហ៊ីង្ស។ ឥឡូវនេះខ្ញុំសូមសួរលម្អិតបន្តិចអំពីអត្តចរិតផ្ទាល់ខ្លួនរបស់គាត់។ លោកចាំ នៅចាំអ្វីបានខ្លះដែរអំពីឈ្មោះ តាវ៉ាល់ នេះ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ខ្ញុំនៅចាំបានថា គាត់សម្តីង៉ោកង៉ាក។ ហើយចំណែក តាហ៊ីង្ស នោះគឺមិនសូវបានទទួលសម្តីអីពីគាត់ទេ ប៉ុន្តែគាត់មិនមែនជាង៉ោកង៉ាកទេ តែយ៉ាងម៉េចទៀត អានោះខ្ញុំអត់ដឹងទេ។

**ស៖** លោកនៅនឹកឃើញទេថា តាវ៉ាល់ គាត់មកពីណាដែរ? ប្រភពដើមគាត់មកពីខាងផ្នែកណាដែរ?

**ឆ៖** ទេ បើតាមឮគេថា ព្រោះគាត់ថាមកពីកំពង់ចាម។

[០៩:០៨:៤២]

**ស៖** ចុះអំពីជំហរនយោបាយរបស់គាត់ ទស្សនៈនយោបាយរបស់គាត់ លោកនៅនឹកឃើញទេ?

**ឆ៖** ខ្ញុំដូចនឹកមិនឃើញ ពីព្រោះជំនាន់នោះវាមិនទាន់បានជានឹងទៅគិតពីរឿងបញ្ហាអស់នោះផង គិតតែគេឲ្យធ្វើអី គឺធ្វើបាទ។

**ស៖** លោកសាក្សី ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច។ សូមអានសម្រង់ចេញពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចម្លើយរបស់លោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារ <E3/9008> ERN ជាភាសាអង់គ្លេស 00731123-24, ខ្មែរ 00728796 ដល់ 797។ លោកបានឆ្លើយប្រាប់ទៅអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាថា៖ “ម្នាក់ៗស្គាល់ តាវ៉ាល់ ។ជាមនុស្សចិត្តអាក្រក់។ តាវ៉ាល់ ជាមនុស្សដែលមានជំហរដាច់ខាត។ គាត់ធ្លាប់ធ្វើជាគ្រូបង្រៀន ហើយនៅឯការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង គាត់បាននិយាយភាសាបារាំងជាមួយ ហ៊ីង្ស។” តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកបានខ្លះទេ លោកសាក្សី?

**ឆ៖** បាទ ពីព្រោះបើតាមយើងស្ដាប់សម្ដីរបស់គាត់ ដូចជាពិបាកដូចថា យើងគួរខ្លាច។ តែត្រង់គាត់យ៉ាងណាយ៉ាងណី គឺយើងមិនដឹងទេ មិន -- សម្ដីរបស់គាត់គឺរ៉ូសវ៉ាសបន្តិចហើយ ព្រោះអត់មាននិយាយអីស្រួលបួលទេ គាត់បាទ។

[០៩:១១:១០]

**ស៖** ចុះការនិយាយភាសាបារាំងរបស់គាត់ជាមួយ តាហ៊ីង្ស នោះ លោកស្ដាប់ដឹងថាម៉េចដែរ?

**ឆ៖** បាទ មិនដឹងទេ ព្រោះខ្ញុំស្ដាប់ ទោះបីជាឮក៏ស្ដាប់មិនដឹងដែរ ព្រោះគេអ្នកៗដើរជិតហ្នឹងគេថានិយាយបារាំង ក៏ខ្ញុំវាថាតាមគេទៅ បាទ។

**ស៖** ខ្ញុំសុំអានសម្រង់នៃចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ ERN 00731124, ខ្មែរ <00278798>, បារាំង <01123720>។ “សួរ៖ ថាតើគាត់និយាយថាម៉េច? លោកឆ្លើយថា៖ គាត់គឺជាមនុស្សដែលមានជំហរដាច់ខាត។ សួរ៖ ជំហរដាច់ខាត? តាម<សម្ដីសំដៅ និងអត្តចរិត> របស់គាត់ គឺថាតាមស្ដាប់មើលទៅ គាត់ធ្លាប់ធ្វើជាគ្រូបង្រៀន។ <សួរ៖ គ្រូបង្រៀន?> ថាបាទ! គាត់និយាយភាសាបារាំងជាមួយ តាហ៊ីង្ស ព្រោះ តាហ៊ីង្ស ជាប្រហ្វេសស៊ឺរនៅភ្នំពេញ។ សួរ៖ គាត់មាននិយាយភាសាបារាំងជាមួយ តាហ៊ីង្ស ទេ? ឆ្លើយ៖ បាទ <>គាត់និយាយភាសាបារាំង<ពេលគាត់ដើរ>។ សួរ៖ លោកធ្លាប់ឮគាត់និយាយភាសាបារាំងជាមួយ តាហ៊ីង្ស ដែរឬយ៉ាងម៉េច? ឆ្លើយ៖ <ពួកគាត់> និយាយ<> <ជួនកាលខ្ញុំដើរពីក្រោយគាត់មើលប្រជាជនលើកទំនប់ ហើយអ្វីដែលគាត់មិនចង់ឲ្យយើងដឹងឮ ពេលនោះ ពួកគាត់និយាយជាភាសាបារាំង។> តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** បាទ ពិតមែនថាអ៊ីចឹងមែន ប៉ុន្តែក៏យើងស្ដាប់អីមិនបាន ព្រោះវានៅឆ្ងាយ។ គេនិយាយប្អូនដប់ម៉ាត់ទៅ គេឈប់ទៅ។

[០៩:១៣:៣៦]

**ស៖** លោកសាក្សី ទាំងតាហ៊ីង្ស ទាំងតាវ៉ាល់ ត្រូវបានគេដឹងថាជាបញ្ញវន្ត។ មានសាក្សីម្នាក់ដែលបាន ដែលៗផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះថា តាហ៊ីង្ស នេះគឺជាបញ្ញវន្តថ្នាក់ខ្ពស់ម្នាក់ បញ្ញវន្តកំពូលម្នាក់។ តើលោកចាំទេចំណុចនេះ?

**ឆ៖** បាទ ខ្ញុំអានេះខ្ញុំឮគេនិយាយថា គាត់ក៏ជាអ្នកបញ្ញវន្តកំពូល ប៉ុន្តែមិនដឹងថាគាត់រៀនដល់ប៉ុនណាអីប៉ុណ្ណី ខ្ញុំអត់បានដឹងដែរ បាទ។

**ស៖** លោកសាក្សី លោកក៏បានឆ្លើយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ត្រង់ចំណុចមួយនោះដែលថាលោកត្រូវបានគេទម្លាក់បុណ្យស័ក្តិ។ តាវ៉ាល់ បានទម្លាក់បុណ្យស័ក្តិ ឬក៏ដកលោក ហើយគេឲ្យលោកទៅទទួលខុសត្រូវប្រមូលធ្វើជីលេខមួយ។ ខ្ញុំមិនដឹងថា ខ្ញុំបានស្តាប់ឮលោកពន្យល់អំពីហេតុផលនៃការទម្លាក់បុណ្យស័ក្តិលោកនេះ ឬក៏អត់ទេ។ <>លោកថា លោក<មិន>ហ៊ានសួរទេ<> ហើយសួរថា ហេតុអីបាន -- លោកដឹងទេ មាន ឬក៏ស្តាប់ពីអ្នកដទៃ ថាហេតុអីបានជា តាវ៉ាល់ ទម្លាក់បុណ្យស័ក្តិលោក?

**ឆ៖** បាទ ពីព្រោះជំនាន់នោះ វាមិនអាចដឹង។ មិនដឹងថា យើងខុសអី ឬក៏ខុសអី ក៏គេដកចេញទៅ ឲ្យទៅរែកជីលេខមួយនោះបាទ។ វាមិនហ៊ានសួរ មិនហ៊ាននេះគេទេ គឺជំនាន់នោះអត់។

**ស៖** ប៉ុន្តែក្រោយមក នៅពេលគេចាប់ តាវ៉ាល់ ទៅ ហើយ តាវ៉ាល់ ឈប់ធ្វើការនៅការដ្ឋាននោះទៀតហើយ តើលោកមានស្តាប់ឮពីអ្នកដទៃ ថាហេតុអ្វីបានជា តាវ៉ាល់ នេះដកតួនាទីរបស់លោកទេ?

[០៩:១៦:២០]

**ឆ៖** បាទ វាមានពាក់ព័ន្ធដូចថា អ្នកខ្លះទៅថាខ្ញុំនេះវាកូនមេឃុំ ជំទប់អីពីសម័យ លន់ នល់ ទៅក៏ប៉ង ហើយខុសអីទៀត អាហ្នឹងមិនដឹងដែរ គេបន្ថែមបូកសរុបទៅ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីការចាប់ខ្លួន តាវ៉ាល់ និង តាហ៊ីង្ស ក៏ដូចជាការចាប់ខ្លួនអ្នកដទៃទៀតផងដែរ។ តើលោកនៅចាំការចាប់ខ្លួនរបស់គាត់ទេ? លោកដឹងថា ចាប់នៅក្នុងខែណា ឆ្នាំណាទេ? លោកដឹងថា ការចាប់ខ្លួនកើតឡើងនៅពេលណាដែរ?

**ឆ៖** បាទ ការចាប់ខ្លួននោះវា របស់គាត់ក៏វាមិនសូវច្បាស់ដែរ ប៉ុន្តែខ្ញុំថាប្រហែលជាឆ្នាំ៧៧ ចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨។ វាចាំអត់បានដែរ ព្រោះភ្លេច។

**ស៖** បើសិនណាខ្ញុំប្រាប់លោកថា ខែមិថុនា ១៩៧៧ តើវាអាចជួយរំឭក ជួយពញ្ញាក់ដល់ការចងចាំរបស់លោកដែរទេ?

**ឆ៖** មិន -- រកនឹកមិនឃើញខ្ញុំ ប្រហែលជាពិបាកគិត ព្រោះវាបោះបង់ចោលយូរទៅ អត់បានគិតគូរអីសោះ។ គ្រាន់តែដឹងថា ប្រហាក់ប្រហែល ដូចថាចុងឆ្នាំ៧៧ ឬក៏ពាក់កណ្ដាលឆ្នាំ៧៧ ទៅដល់ឆ្នាំ៧៨។

**ស៖** លោកនៅនឹកឃើញទេថា មានរយៈពេលប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានសប្ដាហ៍ ចន្លោះពីពេលលោកពេលគាត់ទម្លាក់តួនាទីរបស់លោក និងដល់ពេលគេចាប់ខ្លួន តាវ៉ាល់?

**ឆ៖** យូរដែរ បើតាមខ្ញុំគិត។ តាំងពី គិតទៅតាំងពីរដូវវស្សា៧៦ មិនដឹង ហើយមកទល់នឹងចុងឆ្នាំ៧៧។

[០៩:១៩:២៤]

**ស៖** ខ្ញុំដឹងថា ពិបាកនឹងចាំពេលវេលាពិតប្រាកដ ថ្ងៃខែឆ្នាំឲ្យបានពិតប្រាកដហើយ ក៏ប៉ុន្តែសំណួរខ្ញុំ គឺចង់សួរចន្លោះពេលគេចាប់ខ្លួន តាវ៉ាល់ និងពេលដែលគេដកហូតមុខងាររបស់លោក។ ន័ចន្លោះពីពេលគេទម្លាក់តួនាទីលោក ទៅដល់ពេលគេចាប់ តាវ៉ាល់ តើវាមានរយៈពេលប៉ុន្មានសប្ដាហ៍? វាមានរយៈប៉ុន្មានខែ លោកអាចនឹកឃើញទេ?

**ឆ៖** ប្រហែលជា អានេះតាមប៉ាន់ស្មាន ប្រហែលជា៧ទៅ៨ខែ នេះតាមខ្ញុំគិត។

**ស៖** ខ្ញុំសូមចាប់និយាយអំពីពេលប្រជាជនចាប់ផ្ដើមធ្វើការលើកទំនប់ត្រពាំងថ្មហ្នឹង គឺខែកុម្ភៈ ១៩៧៧។ តាវ៉ាល់ <ត្រូវបាន>ចាប់ខ្លួននៅខែមិថុនា ១៩៧៧។ តើលោកនេះ ត្រូវបានគេដកតួនាទីចន្លោះពីខែកុម្ភៈ ១៩៧៧ ទៅដល់ខែមិថុនា ១៩៧៧ គឺចន្លោះពេលហ្នឹង លោកនឹកឃើញខ្លះទេ?

**ឆ៖** ដូចនឹកមិនឃើញ ដូចភ្លេចតែម្ដង។ វាមិនបានជាគិតអី នេះទៅវាភ្លេចឈឹងទៅ មិនដឹងខែណា ខែណីអី ចេះតែធ្វើទៅ។ ហើយជំនាន់នោះ វាអត់មានប្រតិទិនដែរ។

**ស៖** លោកនៅចាំទេថា អ្នកណាជាអ្នកមកចាប់ តាវ៉ាល់ ហើយនិង ហ៊ីង្ស?

**ឆ៖** វាការចាប់របស់ តាវ៉ាល់ និង តាហ៊ីង្ស គឺខ្ញុំក៏មិនបានដឹងថា ពីខាងណាមកចាប់។ ស្រាប់តែគេថា ដូចនៅចល័តទាំងអស់គ្នាទៅថា បាត់ខ្លួនគាត់ទៅ ក៏បាត់ទៅ។ វាអត់ដឹង អត់ដឹងថាពីខាងណា ពីខាងណីមកចាប់មនុស្សម៉េច អត់ដឹងសោះ។

**ស៖** លោកនៅមានចាំថា មានទំនាក់ទំនងគ្នារវាងការមកដល់របស់កម្មាភិបាលនិរតី ឬក៏ភូមិ

ភាគបូព៌ា និងការចាប់ខ្លួន តាវ៉ាល់ ហើយនិង តាហ៊ីង្ស នៅពេលក្រោយ តើវាមានជាប់ទំនាក់ទំនងគ្នាទេ?

**ឆ៖** បាទ ពីព្រោះពេលនោះវា គេដូរពីបូព៌ា ហើយនិងមកពីភូមិភាគនិរតីទៅ ក៏វាមិនដឹងថាទំនាក់ទំនងជាប់គ្នាឯណា វាពិបាក ព្រោះពេលនោះវាមិនបានទៅជួប ទៅជុំគ្នាអីស្រួលទេ ព្រោះការផ្លាស់ប្តូរមកហើយ ក៏នៅតែស្ងៀមទៅ វាអត់ដឹង។

[០៩:២៣:០៥]

**ស៖** តើលោកនៅចាំការមកដល់របស់កម្មាភិបាលភូមិភាគ<បូព៌ា>នៅតំបន់៥ដែរទេ?

**ឆ៖** ខ្ញុំ តាមការស្មានរបស់ខ្ញុំ ប្រហែលជាពាក់កណ្តាលឆ្នាំ៧៧ ឬក៏ជិតបំណាច់ឆ្នាំ៧៧។

**ស៖** ប៉ុន្តែសំណួររបស់ខ្ញុំនេះគឺថា តើលោកនៅមានចងចាំចំណុចណាមួយអំពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី -- (សូមទោស) កម្មាភិបាលភូមិភាគបូព៌ាដែរទេ?

**ឆ៖** ពីបូព៌ាមិនបានចាំច្បាស់លាស់ទេ ព្រោះមកហើយនោះ ក៏វាមិនទាន់ឮអ្នកណាគេនិយាយថាបូព៌ា បូព៌អី។ ស្រាប់តែដល់ពេលក្រោយនេះ ឮគេនិយាយថា កម្មាភិបាលមកពីបូព៌ាទៅ ក៏ប្រហែលជាមុន មុនភូមិភាគនិរតី ប្រហែលជា២ខែអីនេះ ឬក៏៣ខែបើតាមខ្ញុំគិត។

**ស៖** លោកនៅចាំកម្មាភិបាលណាម្នាក់ជាក់លាក់ទេ គឺកម្មាភិបាល<ភូមិភាគ>បូព៌ា<ដែលបានមកភូមិភាគពាយ័ព្យទេ?>

**ឆ៖** ដែលខ្ញុំចាំបាន គឺមកពីនិរតីមាន តាយ៉ាន់ នៅនឹងទំនប់ត្រពាំងថ្មហ្នឹង ហើយនិង តារិនតំបន់ គាត់តែងទៅ។ អានោះ គឺនៅចាំបានបាទ។

**ស៖** លោកដឹងថា អ្នកទាំងនុ៎ងមកពីភូមិភាគបូព៌ា ឬក៏មកពីភូមិភាគនិរតី?

**ឆ៖** បាទ គាត់ភូមិភាគនិរតីបាទ។

[០៩:២៥:៤០]

**ស៖** ចុះមនុស្សម្នាក់ឈ្មោះ ទុយ លោកនៅនឹកឃើញទេ?

**ឆ៖** នឹកឃើញ ទុយ នោះ ក៏ភូមិភាគបូព៌ាបាទ។

**ស៖** តើលោកនៅចាំទេថា ទុយ ពេលនុ៎ងគាត់ធ្វើអ្វីដែរ? ហេតុអ្វីបានជាគេបញ្ជូន ទុយ ឲ្យមកភូមិភាគពាយ័ព្យ? គេបញ្ជូនឲ្យមកធ្វើអ្វីដែរ?

**ឆ៖** ទេ ខ្ញុំដូចជាចាំមិនបាន ដោយសារថា គាត់មកនោះ គឺវា គាត់មិនដែលទៅបើកប្រជុំនឹងចល័ត ឬក៏នឹងអី អត់ទេ។ ស្រាប់តែនៅយូរៗទៅ ក៏មិនដឹងគេដូរទៅខាងណាទៅបាទ។

**សៈ** តើលោកនៅចាំបានទេ រយៈពេលប៉ុន្មានដែរ មុននឹងពេលគេចាប់ខ្លួន តាវ៉ាល់ -- ក្រោយពេលចាប់ខ្លួន តាវ៉ាល់? តើអ្នកដែលមកពីភូមិភាគនិរតីហ្នឹង គឺមកដល់នៅពេលណាដែរ? <តើលោកនៅចាំពេលលោកបានជួបពួកគេដំបូង ឬក៏ពេលបានឮពីការមកដល់របស់ពួកគេដំបូងទេ?>

**ឆៈ** ទេ ពីភូមិភាគនិរតី មកដូចខ្ញុំជម្រាបថា ប្រហែលពាក់កណ្តាល៧៧ តែខែឆ្នាំអីវា អើ!ខែថ្ងៃអី វាអត់បានចាំទេ។

**សៈ** ប៉ុន្តែលោកចាំទេ ពេលនុ៎ងខាងកម្មាភិបាលនិរតីហ្នឹងមកម្តងម្នាក់ៗ ឬគេមកម្តងមួយក្រុមៗ? លោកចាំអ្វីឲ្យបានពិតប្រាកដខ្លះដែរ?

**ឆៈ** បាទ អង្កាល់ជំនាន់នោះ មកដូចថាមកទាំងក្រុមៗមក ដូចថាខាងចល័តក៏មកខាងចល័តខាងអីណាអីណើទៀត អានោះក៏ទៅតាមនុ៎ងទៅ ប៉ុន្តែចំណែកដែលខ្ញុំដឹងថាមក ខាងចល័តគឺមកទាំងក្រុមបាទ។

[០៩:២៨:១៩]

**សៈ** លោកសាក្សី ខ្ញុំសូមអានសម្រង់មួយពីចម្លើយផ្ទាល់របស់លោក ចម្លើយដែលលោកឆ្លើយ៤ឆ្នាំមកហើយ ឆ្លើយទៅប្រាប់អ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារដូចមុនដែរលោកប្រធាន ERN ជាភាសាអង់គ្លេស 00731135, បារាំង 01123729-30, ខ្មែរ 00728815 ដល់ 16។ លោកសាក្សី ខ្ញុំនឹងអានសម្រង់ខ្លីមួយដែលលោកបានឆ្លើយកាលពី៤ឆ្នាំមុននេះ ហើយសួរទៅលោកមើល៍ តើចម្លើយនេះត្រឹមត្រូវ ឬក៏អត់ទេ។ “សួរ៖ តើនៅក្នុងខែណា? តើខែប៉ុន្មាន ដែលគេចាប់ តាវ៉ាល់? លោកឆ្លើយថា៖ ប្រហែលជាក្នុងខែមិថុនា។ សួរ៖ ប្រហែលជាខែមិថុនា <១៩៧៧>? បាទ។ តើភូមិភាគនិរតីមកហើយឬនៅពេលដែល តាវ៉ាល់ គេចាប់ខ្លួនហ្នឹង? គឺថា ខាងភូមិភាគនិរតីមកម្តងមួយៗ។ សួរ៖ មកម្តងមួយៗ? ឆ្លើយ៖ គឺថាពួកគេមិនបានមកជាក្រុមទេ រហូតដល់ពេលចាប់ខ្លួន តាវ៉ាល់ ឯណោះ បានមកជាក្រុម។ ដូចអ៊ីចឹង អ្នកហ្នឹងមកតែខាងនិរតី អត់មានពីខាងណាផ្សេងទេ? លោកឆ្លើយថា៖ ទេ ដំបូងមកពីបូព៌ា ហើយបូព៌ា គេចាប់បូព៌ាហ្នឹងមួយលើកទៀត។ និយាយទៅវាមានច្រើនគន្លាក់ណាស់ មកពីបូព៌ា ខ្ញុំភ្លេចឈ្មោះគាត់ទៅ។ គាត់ទទួលខុសត្រូវខាងផ្នែកកងចល័ត<តំបន់> ជំនួយការរបស់គាត់មានការរៀនសូត្រចេះដឹង គឺថាគាត់រៀន រៀនបានបាក់ឌុប។ គាត់មើលទៅដូចជាក្មេង ប៉ុន្តែក្រោយក៏បាត់ខ្លួនទៅ។ អ៎!ខ្ញុំចាំហើយ គាត់ឈ្មោះ ទុយ គាត់ទទួលខុសត្រូវការងារនេះរួមតែម្តង។ ខ្ញុំមិនដឹងថា ទុយ នេះត្រូវបានគេចាប់ខ្លួន ឬអត់ទេ ប៉ុន្តែគាត់បានបាត់ខ្លួនទៅ នៅពេលដែលខាងភូមិភាគនិរតី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មកគ្រប់គ្រងតំបន់នោះ។" ក្រោយពីខ្ញុំអានសម្រង់នេះឲ្យលោកស្ដាប់ លោកសាក្សី តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** បាទ ដល់ពេលក្រោយមកវាបាត់គាត់។ ដល់បាត់គាត់ទៅ ក៏ភូមិភាគនិរតីចុះមកបណ្ដោយ។ តែមក ជួនកាលក៏មក មុនដំបូងទៅដូចថា បួនប្រាំនាក់ បួនដប់នាក់អីមកទៅ បាទ។

[០៩:៣១:២១]

**ស៖** ប៉ុន្តែតើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា កម្មាភិបាលនិរតីត្រូវគេបញ្ជូនមកម្ដងម្នាក់ៗ ឬក៏តែបីបួននាក់មុនពេល តាវ៉ាល់ ចាប់ខ្លួន ឬក៏យ៉ាងម៉េច? មុនពេលគេចាប់ខ្លួន តាវ៉ាល់ ឬយ៉ាងម៉េច?

**ឆ៖** បាទ មុនពេលចាប់ខ្លួន តាវ៉ាល់ មកម្ដងមួយ ម្ដងពីរ ប្រាំប្រាំមួយអីទៅ ដល់ក្រោយមកបានច្រើនដែរបាទ។

**ស៖** លោកសាក្សី ខ្លួនលោកផ្ទាល់នេះបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា តាវ៉ាល់ ជាមនុស្សចិត្តអាក្រក់ ជាកម្មាភិបាលម៉ឺងម៉ាត់។ សាក្សីមួយចំនួនក៏បានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា តាវ៉ាល់ ជាឃាតករកាចសាហាវណាស់។ តើលោកនឹកឃើញអ្វីខ្លះអំពីគាត់នេះ មុនពេលគេចាប់ខ្លួន តាវ៉ាល់ នេះ?

**ឆ៖** តែរឿងឃាតករ មិនឃាតករ អាហ្នឹងខ្ញុំមិនអាចក្ដាប់គាត់បាន ដោយសារថា ក្ដាប់បានថា គាត់រឿងសម្ដី មើលទៅហាក់ដូចជាកាច បានខ្ញុំថា តាវ៉ាល់ គាត់ដូចកាចណាស់ បាទ។ ប៉ុន្តែអារឿងថា ទៅឃាតករអីផ្សេងៗ អានោះខ្ញុំមិនអាចបានដឹងទេ ព្រោះខ្ញុំនៅល្អិតល្អោចដែរបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយអំពី តាហ៊ីង្ស វិញម្ដង ដែលត្រូវបានគេចាប់ខ្លួននៅពេលប្រហែលៗគ្នានោះដែរ។ កាលពីថ្ងៃព្រហស្បតិ៍ សប្ដាហ៍មុន លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញានៅត្រង់ចំណុចមួយថា តារិន ត្រូវគេយកមកដាក់ជំនួស តាហ៊ីង្ស ប៉ុន្តែតាមដែលខ្ញុំចាំនោះ គឺថាមុនពេល រិន ទទួលបានអំណាចនេះ គឺថាវាមានមនុស្សម្នាក់ គាត់ទទួលបន្ទុកជាបណ្ដោះអាសន្នសិន ជាបណ្ដោះអាសន្នសិន គឺឈ្មោះ តាជាល។ ត្រឹមត្រូវទេ?

[០៩:៣៣:៥៨]

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ។

**ស៖** ឥឡូវខ្ញុំសូមសួរខ្លះៗអំពី តាជាល លោកចាំអ្វីខ្លះអំពី តាជាល នេះ?

**ឆ៖** បើនិយាយពីរឿង តាជាល ខ្ញុំអត់មានចាំអីសោះ ពីព្រោះអត់បានគិតគូរអីរឿង តាជាល ទេ

ប៉ុន្តែគ្រាន់តែឮថា បណ្តោះអាសន្នតំបន់៥ បាទ។

**ស៖** លោកចាំទេ ឪពុក តាជាល ឈ្មោះអ្វីដែរ?

**ឆ៖** បាទ ឈ្មោះ រស់ ញឹម។

**ស៖** លោកដឹងដែរថា ប្រពន្ធ តាជាល ឈ្មោះអ្វីដែរ?

**ឆ៖** អត់បានដឹងប្រពន្ធ។ និយាយរួមគឺប្រពន្ធ កូនអី គឺមិនស្គាល់ទេ ប៉ុន្តែស្គាល់ដឹងថាគាត់ជាកូនរបស់ រស់ ញឹម បាទ។

**ស៖** ខ្ញុំប្រាប់ថា ជាល នេះរៀបការជាមួយ<កូនស្រី>មេដឹកនាំភូមិភាគបូព៌ា ឈ្មោះ សោ ភឹម តើអាចជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** មិនអាចដឹង ឬក៏ចាំ ព្រោះខ្ញុំពិបាកដែរ ព្រោះគេថ្នាក់លើវា គេការងណាឯណី វាមិនសូវបានដឹងទេជំនាន់នោះបាទ។

[០៩:៣៦:១០]

**ស៖** មិនថ្វីទេលោកសាក្សី។ ឥឡូវនេះយើងចូលទៅនិយាយមនុស្សម្នាក់ឈ្មោះ តារិន ដែលគាត់គេយកមកដាក់ជំនួស តាហ៊ីង្ស។ ព្រះរាជអាជ្ញាបានសួរលោកអំពីឈ្មោះនេះអង្គាល់ពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ហើយក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកឆ្លើយថានៅពេលដែលគេយក រិន នេះមកជំនួស វ៉ាល់ ដកស្រង់៖ “គឺថាអ្វីៗទាំងអស់ផ្លាស់ប្តូរទាំងអស់” បិទការដកស្រង់។ តើលោកចង់និយាយថាម៉េច នៅពេលលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាថា ពេល តារិន ចូលមក អ្វីៗគឺថាវាប្រែប្រួលទាំងអស់នោះ?

**ឆ៖** បាទ ការប្រែប្រួលដូចថា វាស្ថានភាពវាវាងដូចថាច្របូកច្របល់ ដូចថាក្តាប់អីធ្វើអីវាមិនដឹងឯណាឯណី ព្រោះមនុស្សប្រជាជនភាគច្រើន ដល់ពួកភូមិភាគនិរតីមកចេះតែភ័យទៅបាទ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសម្រង់ខ្លីមួយពីឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីឈ្មោះ រិន នេះ។ ឯកសារដដែលនេះទេលោកប្រធាន អង់គ្លេស ERN គឺ 00731140, បារាំង <01123733> ហើយខ្មែរ <00728823-24>។ លោកសាក្សីអ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជា សួរលោកកាលពី៤ឆ្នាំមុន ឲ្យលោករៀបរាប់អំពីឈ្មោះ រិន ហើយលោកឆ្លើយថា៖ “បាទ រិន ជាមនុស្សដែលគួរសម។ ហើយថាចុះសម្តីរបស់គាត់ម៉េចដែរ?” លោកឆ្លើយថា៖ “គាត់ស្លូតបូតណាស់។ តើគាត់នៅសម្រាកនៅឯទំនប់ត្រពាំងថ្ម ឬក៏<ល្ងាចឡើង>ត្រឡប់មកវិញ? ជួនកាល – ឆ្លើយ៖ ជួនកាលគាត់ដេក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅទីនោះ <ជាមួយគណៈកម្មាធិការតំបន់ហ្នឹង>។ ខ្ញុំគិតថាគាត់ជាមនុស្សខុសពីគេ គឺថាមនុស្ស ហ្មត់ចត់ និងត្រឹមត្រូវណាស់។ សួរ៖ ថាត្រឹមត្រូវ?" លោកឆ្លើយថា៖ "ឧទាហរណ៍បើថា <ពេលយើង កាប់គោមួយ យើងត្រូវប្រាកដថា អ្នកគ្រប់គ្នាទទួលបានសាច់។ គាត់ថែមទាំងឆែកគ្រប់ថង់ត្រីនៅក្នុង ឃ្លាំង> គឺថាគាត់ខ្លាចយើងលាក់ទុកសាច់ណាខ្លះនោះ ហើយខ្ញុំមានចំណាប់អារម្មណ៍មែនទែន។ សួរ៖ <លោកចូលចិត្ត> តារិន ហ្នឹង? បាទគឺថាម្នាក់ៗ គឺថាសរសើរគាត់ណាស់។ ហើយសរសើរគាត់ ដោយសារអី? ថាគេធ្វើខុសនោះ គឺយើងអត់ដឹងទេ ប៉ុន្តែយើងដាក់ស្តែង <គាត់នឹងបន្ទោសអ្នកណា ដែល>យកអង្ករច្រើន<>។" តើលោកនៅចាំទេ លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា រិន នេះជាមនុស្សហ្មត់ចត់ និងត្រឹមត្រូវ? <ហើយធ្វើឱ្យលោកមានចំណាប់អារម្មណ៍។ តើលោកអាចឱ្យ ជាឧទាហរណ៍ ជាក់លាក់ជាងនេះ បានទេថាតើ>ហេតុអីបានជាលោកឆ្លើយថា គាត់ជាមនុស្សហ្មត់ចត់ និងត្រឹមត្រូវទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា?

[០៩:៣៩:៤៩]

**ឆ៖** បាទ ពីព្រោះខ្ញុំឃើញដូចលោកនិយាយអំមិញ ដូចថាអាការចែកចាយអី គឺគាត់មិនមែនប ណ្តោយឱ្យយើងចែក គឺគាត់តាមមកមើលបណ្តោយ ដូចថាកាប់គោអីចេះ មិនថាចែកទៅតាមកងគឺ ចិញ្ច្រាំពោះថ្លើមអីទាំងអស់ ឱ្យចែកទៅតាមនោះបានម្នាក់ប៉ុនណា គឺយកប៉ុណ្ណោះ។ គិតតាមគីឡូ តាម ក្រាម ច្បាស់លាស់ណាស់បាទ។

**ស៖** បាទ ខ្ញុំយល់ហើយលោកសាក្សី ប៉ុន្តែខ្ញុំព្យាយាមស្វែងយល់ឱ្យបានត្រឹមត្រូវ។ ដោយសារ ថាម្យ៉ាងនោះ លោកបានរៀបរាប់ថា តាវ៉ាល់ ជាមនុស្សដែលតឹងតែង ហើយនិងម៉ឺងម៉ាត់។ ឯ រិន វិញ លោកថា ជាមនុស្សដែលហ្មត់ចត់ និងត្រឹមត្រូវ។ អីចឹងដូចជាផ្ទុយគ្នា រវាងមនុស្សពីរនាក់ហ្នឹង ខ្ញុំចង់ ដឹង។ សូមលោកពន្យល់បន្ថែមបន្តិចបានទេ លក្ខណៈខុសគ្នារវាងអ្នកទាំងពីរនេះ?

**ឆ៖** បាទ ខ្ញុំជម្រាបបាន។ ដូច តាវ៉ាល់ គាត់ហ្មត់ចត់ ការធ្វើការងារ ដូចជាលើកទំនប់លើកអី គឺហ្មត់ចត់ ច្បាស់លាស់។ តែឈ្មោះ រិន នេះក៏គាត់ហ្មត់ចត់ដែរ ប៉ុន្តែវាហ្មត់ចត់រហូតដល់សេដ្ឋកិច្ច។ គាត់ខ្លាចយើងទុកស៊ី ទុកអីតែឯង ហេតុនេះគាត់ហ្មត់ចត់ថា ធ្វើម៉េចឱ្យវាបានទាំងអស់គ្នាបាទ។ វាប្លែក គ្នាត្រង់ណោះបាទ។

**ស៖** ឥឡូវនេះខ្ញុំរៀបសំណួរផ្សេងគ្នាវិញ។ តើមានអ្វីៗប្រែលប្រួលសម្រាប់ប្រជាជនដែលធ្វើការ នៅទំនប់នោះទេ ពាក់ព័ន្ធទៅនឹងរបស់អាហារ លក្ខខណ្ឌការងារនៅពេលដែលគេយក តារិន មកជំនួស

តាហ៊ីង្ស តើមានការប្រែប្រួលអ្វីៗខ្លះដែរទេ ឬក៏អ្វីៗវានៅតែដដែលទេ?

[០៩:៤២:៣៨]

**ឆ៖** បាទ វាជាមិនខុសគ្នាប៉ុន្មានទេ ប៉ុន្តែដល់ពេលគាត់ចុះមកទៅ ដូចថាអង្ករអីវាគាត់ចេះតែបញ្ជូនមកអ្នកបើកអង្ករហ្នឹង ដូចថារបបប៉ុន្មាន ក៏បីកំប៉ុង ឬក៏អី ក៏គាត់យកមក។ តែក៏មានពេលខ្លះក៏ដាច់ដែរបាទ។ វាមិនបានជាអចិន្ត្រៃយ៍ទេ ដូចថាខែណាដែលគេលើកទំនប់ខ្លាំង ធ្វើខ្លាំងទៅ ក៏បានរបបនោះក៏បីកំប៉ុងទៅ។ តែដល់រដូវវស្សាមិនបានទេ បានមួយកំប៉ុងកន្លះចល័តបាទ។

**ស៖** លោកសាក្សី មានភស្តុតាងមួយចំនួនហាក់ដូចជាបញ្ជាក់ថា ឬក៏សម្តីរបស់សាក្សីខ្លះនិយាយថា ការងារនៅឯទំនប់ហ្នឹង កាន់តែលំបាកឡើងៗពេល តារិន មកដល់។ ខ្ញុំជឿជាក់ថាលោកទើបតែឆ្លើយអម្បាញ់មិញនេះ ថាមានលក្ខណៈខុសគ្នាច្រើន។ ប៉ុន្តែតើលោកមានចាំថាមានការខុសគ្នាមានភាពខុសគ្នាយ៉ាងម៉េចដែរទេ នៅឯទំនប់ហ្នឹងក្នុងអំឡុងពេលនៃការផ្លាស់ប្តូរគ្នានេះ?

**ឆ៖** តែបើខ្ញុំគិតទៅ វាមិនមានជាការប្រែប្រួលអីខុសគ្នាប៉ុន្មានទេ ប៉ុន្តែអង្កាល់ពីជំនាន់ តាវ៉ាល់ វាមានធ្វើយប់ធ្វើអីទៅ។ ដល់មកជំនាន់ តារិន នេះដូចជាមិនសូវ ៗដូចជាមិនដែលឃើញធ្វើយប់បាទ។ វាប្លែកគ្នាប៉ុណ្ណោះ តែរឿងការលំបាកវាមិនខុសគ្នាទេ ព្រោះយើងជីកដី រែកដី ទាំងគេទាំងខ្ញុំ វាលំបាកហើយ ព្រោះពេលដែល តារិន មកនេះគេត្រូវធ្វើទំនប់នោះឲ្យវា បន្ថែមទំនប់ឲ្យបាន ថាឲ្យបានរួច ប៉ុន្តែវាអត់បានរួច។

**ស៖** លោកសាក្សីសំណួរឥឡូវនេះ ខ្ញុំដឹងថាវាមិនមានភាពខុសគ្នាទេ ពាក់ព័ន្ធទៅនឹងផែនការការងារនៅពេល តាវ៉ាល់ គាត់ទទួលខុសត្រូវ និង តាហ៊ីង្ស ទទួលខុសត្រូវ ប៉ុន្តែបើសិនណាជាលោកដឹងលោកដឹងថា មូលហេតុអីបានជាគេចាប់ តាវ៉ាល់ និង តាហ៊ីង្ស ទេ?

[០៩:៤៥:៥៧]

**ឆ៖** មិនៗអាចដឹងលោក ពីព្រោះនិយាយឲ្យខ្លីទៅ ខ្ញុំជម្រាបថាជំនាន់នោះគឺ លោកសួរចុះសាក្សីណាក៏ដោយ មិនងាយបានគេឲ្យដឹងថា ចាប់ឈ្មោះនេះ គឺវាមានមកពីខាងណេះខាងណោះអី គឺអត់ដឹងទេលោក ព្រោះមិនមានអ្នកណាហ៊ានទៅនិយាយទៅសួរអីគ្នាផង បាទ។

**ស៖** លោកសាក្សី តាមពិតសំណួរដែលខ្ញុំសួរលោកនេះ ក៏ត្រូវបានគេសួរទៅអ្នកដែលសាក្សីដែលធ្លាប់ទៅទទួលខុសត្រូវនៅឯទំនប់នោះដែរ កាលនោះ។ ហើយអ្នកទាំងនោះគេបាននិយាយអំពីតាហ៊ីង្ស, តាវ៉ាល់ នេះ ថាបានចូលរួមពាក់ព័ន្ធនៅក្នុងការប្រមូលអាវុធដើម្បីចាប់ផ្តើមធ្វើការតស៊ូប្រឆាំងតបត

វិញ។ តើលោកនឹកឃើញទេចំណុចនេះ? បាទ ខ្ញុំនឹងរៀបសំណួរឡើងវិញ។

**លោក នីកូឡាស គូមជែន៖**

តែយ៉ាងហោចណាស់ សូមឆ្លើយសិនថា គឺជាសំណួរនាំមុខហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនជាសំណួរនាំមុខទេ ខ្ញុំព្យាយាមចង់ដឹងថាតើគាត់ដឹងអំពីការចាប់ខ្លួន ឬក៏អត់តែប៉ុណ្ណោះ ប៉ុន្តែខ្ញុំ<នឹងអានទទូវអត្ថបទដកស្រង់>--

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន <ការប្រាប់ទៅសាក្សីនេះថា នេះគឺអ្វី -->

[០៩:៤៧:២៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវមេធាវី វ៉ិចទ័រ កូប៉េ រៀបចំសំណួរសាជាថ្មីម្តងទៀត ហើយសហព្រះរាជអាជ្ញាអន្តរជាតិចាំស្តាប់សំណួរដែលរៀបចំឡើងសាជាថ្មីដោយមេធាវី វ៉ិចទ័រ កូប៉េ ជាមុនសិន មុននឹងធ្វើការជំទាស់ ព្រោះមេធាវីបានបង្ហាញនូវជំហររបស់ខ្លួនហើយ ថាខ្លួននឹងរៀបចំនូវការតាំងសំណួរនោះឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំត្រឡប់ថយក្រោយវិញបន្តិច លោកសាក្សី។ បើខ្ញុំស្តាប់ចម្លើយរបស់លោកមិនច្រឡំទេ លោកថាលោកមិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួន តាវ៉ាល់ និង តាហ៊ីង្ស ទេ។ លោកឆ្លើយថាអ៊ីចឹង? លោកអត់ដឹងមូលហេតុទេឬ?

**លោក ឈិត យឿក៖**

**ឆ៖** ទេ ខ្ញុំអត់ដឹងមូលហេតុទេ។ មិនដឹងមូលហេតុអីបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

ការដែលខ្ញុំព្យាយាមស្វែងយល់អំពីចំណុចនេះ។ លោកប្រធានខ្ញុំយល់ថា ខ្ញុំមានសិទ្ធិអានសម្រង់ពីសាក្សីផ្សេងទៀត ដើម្បីយកមកសួរសាក្សីរូបនេះ ថាតើវាជួយរំឭកដល់ការចងចាំរបស់គាត់ដែរឬក៏អត់។ ឥឡូវនេះខ្ញុំសូមអានសម្រង់ដូចខាងក្រោមនេះលោកប្រធាន។

[០៩:៤៨:៥៣]

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សាក្សីរូបនេះបានឆ្លើយច្បាស់ហើយថា គាត់មិនបានដឹងអំពីការចាប់ខ្លួនអ្នកទាំងនេះទេ។ ការអានចម្លើយរបស់អ្នកដទៃមកសួរគាត់ ថាតើវាជួយរំឭកដល់ការចងចាំទេ។ វាជានិយមន័យនៃការអានទេតើ វាជាការអាន ហើយហុចតម្រុយមកទៅវិញហ្នឹង។ គាត់អាន -- គាត់អាចសួរទៅសាក្សីរូបនេះ ផ្ទាល់ៗតែម្ដង ថាតើដឹងការចាប់ តាវ៉ាល់ ទេ ឬក៏យកចម្លើយសាក្សីនេះមុនៗយកមកសួរ ទើបបាន។ ប៉ុន្តែការដែលយកចម្លើយរបស់សាក្សីមុនៗមកសួរ ថាតើវាជួយរំឭក ជួយដាស់ដល់ការចងចាំអីនោះ គឺថាមិនជាការត្រឹមត្រូវទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយល់ឃើញថា នេះគឺជាការមធ្យោបាយមួយនៃការតាំងសំណួរដែលបានត្រឹមត្រូវហើយ។ ទី១ ខ្ញុំព្យាយាមសួរសំណួរបើក ហើយប៉ុន្តែដោយសារសាក្សីរូបនេះ ជួនកាលត្រូវការជួយរំឭកនូវការចងចាំរបស់គាត់ខ្លះ សូម្បីតែចម្លើយរបស់គាត់ក្ដី។ អ៊ីចឹងហើយខ្ញុំបានស្នើសុំអានចម្លើយរបស់សាក្សីផ្សេង ដើម្បីយកមកសួរគាត់។ បើគាត់ដឹង គាត់ឆ្លើយថាដឹង។ បើគាត់មិនដឹង ក៏ចម្លើយថាមិនដឹងទៅ។

[០៩:៥០:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៥:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីការពារក្ដី មុននឹងឲ្យលោកអានសម្រង់ខ្លីៗ យើងចង់សួរចំណុចពីរ។ ថាតើចម្លើយទាំងអស់នេះ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺជាឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារ E3/9076, ERN អង់គ្លេស 0073 1170, ខ្មែរ 00728868 និងពីរទំព័រមកខាងក្រោមទៀត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សំណួរមួយទៀត តើបុគ្គលមួយនេះ តើត្រូវបានតុលាការសួរនៅក្នុងអំឡុងពេលមុនសវនាការនេះហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

ដូចជាតាមដែលខ្ញុំដឹង លោកស្រីចៅក្រម មិនទាន់ទេ។

[០៩:៥៧:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងតាមដែលលោកដឹង<តើបុគ្គលហ្នឹង>នៅលើបញ្ជីដែលត្រូវមកឆ្លើយនៅទីនេះ <ឬក្នុងពេលកាត់ក្តី>?

**លោក វ៉ិចទ័រ កូប៉េ៖**

<មាននៅលើបញ្ជីរបស់យើង នៅពេលណាមួយ តែមិនមែនឥឡូវនេះទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សុំម្តងទៀត?>

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំកំពុងតែពិចារណាសួរ ស្នើសុំឲ្យសាក្សីរូបនេះ ចូលខ្លួននៅក្នុងដំណាក់កាលនេះ ឬក៏នៅក្នុងវគ្គជំនុំជម្រះនៃការបោសសម្អាតដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកសួរសំណួរយកពីចម្លើយតែមនុស្សម្នាក់មកសួរសាក្សីរូបនេះ ឬក៏យ៉ាងម៉េចហ្នឹង?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏មានសួរចម្លើយផ្សេងៗទៀតដែរ រួមទាំងសាក្សីដែលបានមកឆ្លើយនៅទីនេះរួចហើយ<កាលពីសប្តាហ៍មុន>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះ អ៊ីចឹងហាក់បីដូចជា មើលទៅលោកមិនមែនសួរដើម្បីរំឭកការចងចាំទេ គឺថាលោកយកចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោកកំពុងតែសួរផ្ទុញទៅនឹងសាក្សីរូបនេះហើយមែនទេ ប៉ុន្តែចាប់ផ្តើមសួរចុះ អនុញ្ញាត។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[០៩:៥៨:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសូមអានសម្រង់មួយចេញពីចម្លើយរបស់មនុស្សម្នាក់ដែលគាត់ធ្លាប់ដឹងអំពីការងារនៅការដ្ឋានលើកទំនប់នោះ។ គាត់ឆ្លើយប្រាប់ទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដោយសារតែបុគ្គលនេះ នៅពេលណាមួយគឺថា នឹងត្រូវកោះហៅក្នុងឋានៈជាសាក្សីហើយ។ ដូច្នេះសូមឱ្យលោកមើលទំព័រទី១ នៃចម្លើយរបស់គាត់ឆ្លើយ មជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមមើលឈ្មោះគាត់ ប៉ុន្តែលោកកុំនិយាយឈ្មោះនេះ កុំឱ្យគេឮណ៎ា គ្រាន់តែលោកមើលមើល៍ ថាតើលោកស្គាល់ឈ្មោះនេះដែរឬក៏អត់?

ដូច្នេះលោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញទំព័រទី១នៃឯកសារនេះ ជូនទៅសាក្សីមើល ថាតើគាត់ស្គាល់បុគ្គលនេះដែរឬក៏អត់ ជាមុនសិន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្គាល់មនុស្សម្នាក់នេះទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ នេះគ្រាន់តែឮឈ្មោះ តែវាមិនដែលស្គាល់រូបរាងអីសោះបាទ។

[១០:០០:១៦]

**ស៖** មិនថ្វីទេលោកសាក្សី។ បុគ្គលរូបនេះបានឆ្លើយប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាអង់គ្លេសគឺ ខ្ញុំប្រាប់ហើយ <00731170, ខ្មែរ 00728868 សាក្សីបានផ្តល់សក្ខីកម្មដូចខាងក្រោម>--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន គាត់អាន ERN ញាប់ពេក តាមអត់ទាន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកមេធាវីអានលេខERN ជាថ្មីម្តងទៀត ព្រោះអំមិញញាប់ពេក អ្នកបកប្រែតាមមិនទាន់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោក វ៉ិចទ័រ កូប៉េ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី កូប៉េ តើលោកអាចផ្តល់លេខ ERN ជាភាសាបារាំងបានទេ<?> កាលសប្តាហ៍មុនហ្នឹង គឺលោកអត់មានឃើញផ្តល់លេខ ERN ជាភាសាបារាំងទេ។ ខ្ញុំគិតថា លោក<មិន>មានពេលច្រើនដើម្បីរៀបចំសួរសំណួរសាក្សី <តែខ្ញុំជឿថា លោកមានពេលគ្រប់គ្រាន់សម្រាប់រៀបចំខ្លួន> ហើយដូច្នេះ សូមឱ្យលោកធ្វើតាមទម្លាប់អនុវត្តរបស់យើង គឺថាសូមឱ្យផ្តល់លេខ ERN ជាបីភាសា។

[១០:០១:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកចៅក្រម ខ្ញុំនឹងជម្រាបជូនតាមនេះ។ ERN ជាភាសាបារាំង ក៏ខ្ញុំបានផ្តល់ដែរ ក៏ប៉ុន្តែនៅក្នុងឯកសារកំពុងតែសួរនេះ ERN ជាភាសាបារាំង គឺអត់ទាន់មានបកជាបារាំងទេ។ អ៊ីចឹងមិនអាចផ្តល់បានទេ លោកចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ស៖ លោកសាក្សី បុគ្គលរូបនេះបានឆ្លើយថា បានឆ្លើយដូចខាងក្រោម៖ “ក្រោយមក តាហ៊ីង្សមានផែនការយកកម្លាំងកងចល័តទាំងអស់ឱ្យក្លាយទៅជាកងទ័ព ដើម្បីវាយប្រយុទ្ធប្រឆាំងជាមួយនឹងខ្មែរក្រហម។ គាត់ផ្តល់ខោអាវមួយកំប្លេ ហើយក្រមាមួយ ហើយបំពាក់អាវុធទៅដល់កម្លាំងកងចល័តទាំងនេះ។” តើលោកធ្លាប់ឮចំណុចនេះទេ ក្រោយខ្ញុំអានឱ្យស្តាប់ហើយ លោកធ្លាប់ឮទេ ឬក៏មិនដែលឮទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ខ្ញុំដូចមិនដែលឮ ពីព្រោះកន្លែងបើកអង្ករវានៅឆ្ងាយពីចល័តដែរ ហេតុនេះដូចមិនដឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា គេរៀបចំអីម៉េច អត់ដឹងបាទ។

[១០:០៣:១០]

**ស៖** សាក្សីដដែលនេះក៏បាននិយាយមកខាងក្រោម ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចតទៅ ERN ជាភាសាអង់គ្លេស 00731172, ខ្មែរ 00728870។ សាក្សីរូបនេះ ត្រូវបានសួរអំពី តាជាល, តាញ៉ែម ហើយនិង តាហ៊ីង្ស។ ឥឡូវនេះ សំណួរសួរអំពីតាញ៉ែម "តើ តាញ៉ែម មកញ៉ែកញ៉ាប់ទេ? សាក្សីនេះឆ្លើយថា៖ "គាត់មកជាញ៉ឹកញ៉ាប់ នៅពេលគាត់មានផែនការ។ ក្រោយមកគាត់មកទាំងថ្ងៃទាំងយប់ ជួនកាលមកពេលល្ងាច ជួនកាលមកពីម៉ោងពីររសៀល។ សួរ៖ គាត់មកធ្វើអ្វី? គាត់ហ្នឹង គឺ រស់ ញ៉ែម។ គាត់យកស្បែកជើងមកពីភូមិភាគបូព៌ា មកឲ្យកងចល័ត។ សួរ៖ អូ៎! យកស្បែកជើងផ្ទាត់? យកស្បែកជើង បាទ ស្បែកជើងស្អាតៗ ត្រូវបានផ្តល់មកឲ្យយើង។ នៅពេលហ្នឹងមានផែនការមួយ ខ្ញុំភ័យខ្លាចណាស់ឮសូរផែនការហ្នឹង។ សួរ៖ តើផែនការអ្វី? ឆ្លើយ៖ នៅពេល តាវ៉ាល់ និយាយក្នុងពេលដដែលនុ៎ងជាមួយគ្នានុ៎ង គឺថា<ក្រមា ដែកកេះ និងអាវស ផ្តល់ឲ្យអ្នកដឹកនាំ។> ហើយគាត់និយាយថា អ្នកឯងទាំងអស់គ្នា គឺថាជាអនុសេនីយ៍ឯកហើយ។ <គាត់និយាយហើយនិយាយទៀតថា អ្នកទាំងអស់ជាអនុសេនីយ៍ឯក, វរសេនីយ៍ឯក។ គាត់បានចង្អុល ហើយដើរចេញទៅ>និយាយកំប្លែងលេងជាមួយ<កម្មាភិបាលផ្សេងទៀត បន្ទាប់ពីប្រជុំរួច។> គាត់ប្រៀបធៀបថា កម្លាំងកងចល័តនេះ ក៏ដូចជាកម្លាំងកងទ័ពដែរ<។> ផែនការគឺភ្នំកូនខ្លែង។ ផែនការនេះមិនអាចសម្រេចទៅបានទេ <ប៉ុន្តែខ្ញុំដឹងពីផែនការនេះ> គឺមិនមែនជាកិច្ចប្រជុំសម្លាប់មនុស្ស<ទេ។ បើការ>ប្រជុំ<មានផែនការអីមួយ គឺវាជាផែនការ>សម្លាត់< >។" លោកសាក្សី សាក្សីរូបនេះ<បាននិយាយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>ពី តាញ៉ែម យកស្បែកជើងពីភូមិភាគបូព៌ា ហើយ តាវ៉ាល់ គាត់ឡើងនិយាយថា កម្លាំងទាំងអស់ហ្នឹងនឹងក្លាយទៅជាអនុសេនីយ៍ឯកហើយ មានផែនការសម្លាត់។ តើចំណុចទាំងអស់នេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** បាទ អារឿងថាផែនការសម្លាត់អីយ៉ាងម៉េចៗ គឺខ្ញុំអត់ដឹងទេ។ តែរឿងស្បែកជើងពីបូព៌ានោះ ឃើញគេចែកឲ្យចល័តដែរអង្កាល់នោះ ព្រោះការចែកនោះមិនមែនជាខ្ញុំទេ គេចែកផ្សេងបាទ។

[១០:០៦:១៨]

**ស៖** លោកសាក្សី តើអាចទេដែលថាលោកមិនបានដឹងអំពីផែនការនេះ ដោយសារពីដំបូង គឺថា តាវ៉ាល់ គាត់បានដកតួនាទីរបស់លោក អ៊ីចឹងលោកអត់ដឹងផែនការនេះទេ?

**ឆ៖** បាទ អត់ដឹងទេ។ អង្កាល់ដែលខ្ញុំធ្វើនោះ ក៏វាដូចថាវានៅចុងកន្ទុយគេទៅ ព្រោះគេគ្រាន់តែរុញយើងទៅលើកខាងណេះ ទៅលើកខាងណោះ អាលើកដីទំនប់ហ្នឹងបាទ វាអត់ដឹង។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមើលទៅនាឡិកាហើយ ឃើញថាអាចដល់ម៉ោងសម្រាកហើយ។ តើយ៉ាងម៉េចដែរ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៧ នាទី ដល់ម៉ោង ១០:២៨ នាទី)*

[១០:២៨:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមកែតម្រូវខ្លួនខ្ញុំជាមុនសិន លោកស្រីចៅក្រម ហ្វែនស៍។ ដោយសារសម្រង់ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលខ្ញុំទើបតែអានឲ្យសាក្សីស្តាប់នោះ វាជាឯកសាររបស់ខាង ដាប់ប៊ែលយូ.អា.អាយ។ ជាកំណត់ហេតុស្តាប់ចម្លើយទេ ដែលសហចៅក្រម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស៊ើបអង្កេតបានសួរ គឺឯកសារ E319/19.3.18 ហើយទំព័រដែលពាក់ព័ន្ធនោះ គឺជាសំណួរលេខ <៤៨-៥១ -- ERN អង់គ្លេស>គឺ <01044804> ខ្មែរ ERN 01003885។ យើងមិនទាន់មានការបកប្រែជាភាសាបារាំងនៅឡើយទេ។ ជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីមុន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរតទល់របស់លោក ដោយអានសម្រង់ខ្លីចេញពីសាក្សីផ្សេង។ ខ្ញុំចង់សួរមើល ថាតើលោកស្គាល់បុគ្គលនេះទេ? ខ្ញុំសូមយោងទៅសំដៅមនុស្សម្នាក់ដែលនឹងផ្តល់សក្ខីកម្មនៅពេលខាងមុខនេះគឺ 2-TCW-918។ សម្រង់ដែលខ្ញុំអានឱ្យគាត់ស្តាប់នោះ គឺថាអាចរកបាននៅ ERN ជាភាសាអង់គ្លេស 00728683, ខ្មែរ 00734089 និងបារាំង 01123644។

បាទលោកប្រធាន ខ្ញុំសូមបង្ហាញនូវទំព័រដំបូងនៃចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាសិន ដើម្បីសួរមើលថាតើសាក្សីស្គាល់បុគ្គលម្នាក់នេះដែរឬក៏អត់? ហើយខ្ញុំស្នើសុំឱ្យលោកសាក្សីកុំនិយាយបញ្ចេញនូវឈ្មោះរបស់បុគ្គលម្នាក់នេះ។

[១០:៣១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី សូមលោកកុំអានឈ្មោះបុគ្គលនេះឱ្យឮឱ្យសោះណា ហើយតើលោកស្គាល់មនុស្សនេះទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ខ្ញុំស្គាល់កាលដែលនៅចល័តទាំងអស់គ្នាបាទ។

**ស៖** សាក្សីរូបនេះក៏បានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ហើយគាត់បានប្រាប់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា៖ "តាហ៊ីង្ស និង តាវ៉ាល់ ពេលមួយនោះបានប្រាប់មកខ្ញុំចង្អុលបង្ហាញខ្ញុំថា កងកម្លាំង<ចល័ត>ទាំងអស់នៅពេលទៅដល់ គេទៅដល់ដាំដើមកប្បាសនៅឯភ្នំ<កងវ៉ា> គឺថាពេល<គេ>ទៅដាំនៅហ្នឹង <គាត់បំពាក់អាវុធពួកគេទាំងអស់នោះ> គឺថាយើងនឹងរត់ចូលទៅថៃ <>"។ តើលោកដឹងទេ ថាមានកម្លាំងគេយកទៅប្រើប្រាស់លួចលាក់ដោយ តាហ៊ីង្ស និង តាវ៉ាល់ នៅភ្នំក្រវាញ -- នៅភ្នំកងវ៉ា?

**ឆ៖** បាទ កាលណោះ ដូចខ្ញុំដូចមិនដឹង ពីព្រោះខ្ញុំនៅខាងចល័តស្រុកនោះវិញ មិនទាន់ទៅចល័តតំបន់ទេ។

[១០:៣៤:២៤]

**ស៖** មិនថ្វីទេលោកសាក្សី ខ្ញុំបន្តទៅមុខទៀត។ ប៉ុន្តែមុនទាក់ទងទៅនឹងតួនាទីរបស់លោកជាប្រធានផ្នែកសេដ្ឋកិច្ចនៃតំបន់៥ ខ្ញុំសូមសួរលោកអំពី យាយថែម – អ៊ឹម ថែម។ លោកចាំអ្វីខ្លះដែរអំពី អ៊ឹម ថែម ហៅ យាយថែម នេះ?

**ឆ៖** បាទ ខ្ញុំចាំបានថា មុនដំបូងគាត់ៗធ្វើគណៈស្រុកព្រះនេត្រព្រះបាទ។

**ស៖** លោកមានចាំទេថា លោកបានធ្វើអ្វីដែរនៅចុងឆ្នាំ១៩៧៨ នៅពេលដែលវៀតណាមចូលមកលុកលុយកម្ពុជា? តើលោកធ្វើការស៊ីចង្វាក់គ្នា ស្របគ្នាជាមួយនឹង យាយថែម ដែរទេ?

**ឆ៖** បាទ មុនវៀតណាមចូល ខ្ញុំនៅតែបើកអង្ករដដែល។ វាមិន -- នៅកម្លាំងតូចតាច តែបើកអង្ករដដែលបាទ។

**ស៖** ប៉ុន្តែ តើលោកធ្លាប់ដែលធ្វើទាហានទេ នៅជាមួយ យាយថែម?

**ឆ៖** ខ្ញុំមិនដែលធ្លាប់ធ្វើទាហានទេ ដែលកាលដែលធ្វើនោះទាល់តែរត់មកដល់ភ្នំដងរែកទៅ ក៏គេឱ្យកាន់កាំភ្លើងអឺយាមកាមទៅ បាទ។ តែនៅឯក្នុងនោះអត់ទេ ខ្ញុំមិនដែលបានមកធ្វើទ័ពធ្វើអីទេ។

**ស៖** ប៉ុន្តែ តើខ្លួនលោកផ្ទាល់នេះ នៅ<ចុង>ឆ្នាំ១៩៧៨ ធ្លាប់ដែលធ្វើកងទ័ព<ជាមួយ>យាយថែម ដែរទេ?

**ឆ៖** បាទ អត់ទេ។ ខ្ញុំអត់ដែលបានធ្វើ បើនិយាយពីទ័ពគឺអត់តែម្តងបាទ។

[១០:៣៧:១៤]

**ស៖** បាទ ដើម្បីបញ្ជាក់ថាតើខ្ញុំយល់ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាច្បាស់ ឬក៏មិនច្បាស់នេះ ខ្ញុំសូមប្រាប់ដល់ភាគីថា គឺឯកសារគឺ ERN 00731145 ជាភាសាអង់គ្លេស, ខ្មែរ 00728832 និងបារាំង <01123738> ។ លោកនិយាយពីការទៅភ្នំដងរែក៖ "សួរ៖ តើលោកធ្លាប់ធ្វើជាកងទ័ពជាមួយ យាយថែម ទេ? ហើយលោកឆ្លើយថា៖ បាទខ្ញុំធ្លាប់ធ្វើ។ សួរ៖ តើលោកធ្វើកងទ័ពនៅជាមួយ យាយថែម ប៉ុន្មានឆ្នាំ? រហូតដល់ៗៗពេលរំដោះ <ចុងឆ្នាំ១៩៨០ -- ចុងឆ្នាំ១៩៧៩ នៅចុងឆ្នាំ៨០ អាចក្នុងខែធ្នូ ឬខែមករា"។> ចម្លើយក្នុងដដែលខាងក្រោម ERN ជាភាសាអង់គ្លេស 00731146, ខ្មែរ 00728833 ហើយនិងបារាំង <01123738>។ លោកឆ្លើយជូនមជ្ឈមណ្ឌលឯក-

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សារកម្ពុជាថា នៅឯៗភ្នំ<ផ័ត្រ>ហ្នឹង គឺថាវាយជាមួយវៀតណាម<ឆ្នាំ១៩៨៤> ហើយនៅៗ លោកនៅស្នាក់នៅឯជំរំ<ក្ងក់>រហូតដល់<១៩៩២>។ ត្រឹមត្រូវទេ?

**ឆ៖** វាមិនមែនភ្នំវាយចាបទេ លោក។ ដំបូងដែលរត់មក គឺនៅភ្នំដងរែក។ ដល់ក្រោយមកខ្ញុំមកនៅជំរំជនភៀសខ្លួនបាទ។

**ស៖** ឥឡូវបើនិយាយថា នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ហើយក្រោយមកទៀត ក្រោយឆ្នាំ១៩៧៩ គឺថាលោកបានចូលរួមវាយប្រយុទ្ធជាមួយអតីតកងកម្លាំង<ពាយ័ព្យ> ហើយក្រោយមកក៏វាយប្រយុទ្ធជាមួយក៏ទ័ពវៀតណាមទៀត។ តើត្រឹមត្រូវដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ទេបើកាលមុន៧៩ គឺខ្ញុំមិនដែលបានធ្វើទ័ពទេ។ អត់ដែលធ្វើសោះបាទ ប៉ុន្តែការដាក់ហ្នឹងគេដាក់ម៉េច។

[១០:៤០:២៥]

**ស៖** បាទមិនថ្វីទេ ប៉ុន្តែលោកដែលឮសូរមានការប៉ះទង្គិចប្រដាប់អាវុធ ឬក៏ការវាយប្រយុទ្ធគ្នារវាងកម្លាំងពាយ័ព្យ និងកម្លាំងទ័ពពីនិរតីដែរទេ?

**ឆ៖** បាទ អត់ធ្លាប់ឮ ព្រោះមិនដែលមាននៅតំបន់ខ្ញុំនោះ អត់ៗមានប៉ះទង្គិចអី បាទ។

**ស៖** លោកច្បាស់ទេថា មិនដែលមានការប៉ះទង្គិចគ្នារវាងកម្លាំងពីរនេះ?

**ឆ៖** ពេលមកនៅតំបន់ខ្ញុំ គឺដូចជាមិនមានប៉ះគ្នាទេ។ បើថាតំបន់ផ្សេងទៀត អានោះខ្ញុំអត់ដឹងដែរបាទ។

**ស៖** ឥឡូវខ្ញុំសុំចូលទៅពេលមួយនោះ ដែលលោកក្លាយទៅជាប្រធានសេដ្ឋកិច្ចតំបន់៥។ តើត្រឹមត្រូវដែរឬក៏អត់ទេ ដែលថាលោកបានក្លាយទៅជាប្រធានសេដ្ឋកិច្ចតំបន់៥ នៅខែធ្នូ ១៩៧៧?

**ឆ៖** បាទ ពេលនោះគឺគេឲ្យខ្ញុំនៅបើកអង្ករ ក៏ដូចថាប្រធានដែរ បើខ្ញុំនៅចាត់ចែងអង្ករបាន។

**ស៖** ប៉ុន្តែតើត្រឹមត្រូវដែរទេថា លោកត្រូវបានគេចាត់តាំងឲ្យធ្វើប្រធានសេដ្ឋកិច្ចហ្នឹងក្នុងខែធ្នូ ១៩៧៧?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ បើមិនខែធ្នូទេ ក៏ខែ១អីនេះ ខែ១ ៧៨អី ព្រោះខ្ញុំចាំវាមិនបានដែរ។

**ស៖** តើនៅពេលនោះ លោកមានទទួលភ័ស្តុភារទាំងមូលតែម្ដងសម្រាប់តំបន់៥ ដែរឬទេ?

**ឆ៖** បាទ អត់ទេ។ ពេលនោះគឺសម្រាប់តែដោះស្រាយនៅចល័តតំបន់បាទ មួយតំបន់៥ មួយចល័ត។ ខ្ញុំមាននៅបើកអង្ករឲ្យតែចល័តតំបន់បាទ។

[១០:៤៣:៣៩]

**ស៖** ឥឡូវខ្ញុំសូមអាននូវអ្វីដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ERN ជាភាសាអង់គ្លេស 00731139, បារាំង <01123732> , ខ្មែរ 00728822។ "បាទ ខ្ញុំបានក្លាយទៅជាប្រធានដោយសារខ្ញុំដឹកធុងទទេទៅឲ្យ តារិន ។គាត់សួរពីប្រវត្តិរូបខ្ញុំ។ ខ្ញុំប្រាប់ថា ខ្ញុំអត់ដែលមានតួនាទីអីទេ គេដកខ្ញុំហើយ។ ក្រោយមកខ្ញុំចូលរួមប្រជុំនៅថ្នាក់ស្រុក ហើយគេចាត់តាំងឲ្យខ្ញុំទទួលខុសត្រូវភ័ស្តុភារនៅកងចល័តតែម្តង។ <អ៊ីចឹងបានជាខ្ញុំដឹងថា>មាន<កម្មករ>ប្រហែលជា៣២.០០០នាក់។" តើនេះជាចម្លើយរបស់លោកឆ្លើយប្រាប់ជម្ឈមណ្ឌលឯកសារកម្ពុជាថា លោកទទួលបន្ទុកខាងផ្នែក<ភ័ស្តុភារ>?

**ឆ៖** បាទ មែន ព្រោះខ្ញុំគេចាត់តាំងមកឲ្យដឹកជញ្ជូនអង្ករឲ្យចល័ត។

**ស៖** តើត្រឹមត្រូវដែរទេ ដែរថា តារីន ហើយនិង តាយ៉ាន់ ជាអ្នកចាត់តាំងលោក? តើ តារីន និង តាយ៉ាន់ ជាមេរបស់លោក ហើយចាត់តាំងលោកឲ្យធ្វើការងារនេះឬ?

**ឆ៖** បាទ។

**ស៖** លោកអាចរៀបរាប់បន្តិចបានទេ អំពីការរក្សាទុកនូវស្បៀងនេះ ជាអង្ករនេះ។ លោកទទួលខុសត្រូវឃ្លាំងអង្ករមួយណាដែរ?

**ឆ៖** អង្ករដែលខ្ញុំទទួលខុសត្រូវនោះ ពេលឡានដែលដឹកមក លើក មានកម្លាំងលើកទុក ហើយគ្រាន់តែគេឲ្យទុកនៅក្នុងឃ្លាំងសេដ្ឋកិច្ចនោះឲ្យបាន។ បើអង្កាល់ដែលចល័ត៣២.០០០ ធ្វើម៉េចឲ្យបានសល់នៅ១.០០០បាវ បាទ។

[១០:៤៦:៣៨]

**ស៖** តើនៅពេលនោះ លោកបានដឹងទេ ថាគេទុកអង្ករនៅឃ្លាំងមួយណាដែរ ឃ្លាំងឈ្មោះអ្វីដែរនៅក្នុងតំបន់៥?

**ឆ៖** អង្ករនោះ វាមិនមែនជាឃ្លាំងទេ ព្រោះអង្ករ ស្រូវប្រមូលតាមសហករណ៍ ស្រុកយកមកកិន ផ្តល់ឲ្យចល័ត បាទ។

**ស៖** ខ្ញុំសូមសួរតាមរបៀបផ្សេងអ្វីវិញ។ លោកដឹងទេថា អង្ករប៉ុន្មានដែរ ដែលគេរក្សាទុកនៅតាមឃ្លាំងផ្សេងៗ តាមស្រុក? ក្នុងតួនាទីរបស់លោកជាប្រធានផ្នែកសេដ្ឋកិច្ចទាំងមូល លោកដឹងថា គេទុកអង្ករនៅឃ្លាំងណាខ្លះដែរ នៅតាមស្រុក?

**ឆ៖** បាទ តាមស្រុក ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំគិតតែក្នុងចល័តតំបន់។ តែដល់ទៅស្រុក អត់បាន

ដឹងទេ អង្ករអី។ បើថាក្នុងចល័តតំបន់នោះ អង្ករខ្ញុំទុកនៅកន្លែងអាងត្រពាំងថ្មនេះឯង ទុកបើកឲ្យចល័ត បាទ។

**ស៖** ចុះលោកធ្លាប់ដែលឮអំពីការចោទប្រកាន់ណាមួយ ថាអំពីខ្មាំងនៅភូមិភាគពាយ័ព្យលាក់អង្ករទុកទេ លួចយកអង្ករទៅលាក់ទុក? លោកដែលឮពីចំណុចនេះទេ?

**ឆ៖** ខ្ញុំអត់ដែលបានឮអារឿងថា លួចយកទៅលាក់ទុកអី គឺដូចមិនបានឮ។

**ស៖** អានសម្រង់មួយជូនទៅលោកស្តាប់ នៃឯកសារដែលត្រូវបានទទួលយករួចមកហើយ <ពីរបីខែមុន>ពេលដែលលោកក្លាយជាប្រធានសេដ្ឋកិច្ច។ លោកប្រធាន ឯកសារនេះគឺជាឯកសារE3។

[១០:៤៩:៣៤]

**លោក នីកូឡាស គូមជែន៖**

សូមកែតម្រូវ សាក្សីនិយាយថា គាត់ជាប្រធាន<ភ័ស្តុភារ> ប៉ុន្តែសម្រាប់តែកងចល័តទេ។ <មេធាវីនិយាយតែពីផ្នែកសេដ្ឋកិច្ច។>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គាត់បានឆ្លើយដូច្នេះ នៅក្នុងឯកសារមួយជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា ជាប្រធានសេដ្ឋកិច្ច<>។ ខ្ញុំព្យាយាមកំពុងតែរកឯកសារយកមកសំអាង <>។ ឯកសារនេះ *អ៊ីងគ្លីស* ERN គឺ 00731139, បារាំង <01123732>, ខ្មែរ 00728821។ សំណួរ--

**លោក នីកូឡាស គូមជែន៖**

ប៉ុន្តែពេលដែលខ្ញុំអានទៅ គឺថាដូចដែលមេធាវីការពារក្តីអានដែរ គឺថាគាត់ត្រូវបានចាត់ឲ្យធ្វើជាប្រធាន<ភ័ស្តុភារ>សម្រាប់កងចល័ត។ <ប៉ុន្តែខ្ញុំមិនឃើញ -- ខ្ញុំឃើញតែអ្នកសម្ភាសប្រើពាក្យថា "ប្រធានសេដ្ឋកិច្ចតំបន់" ប៉ុន្តែខ្ញុំមិនឃើញសាក្សីនិយាយអ៊ីចឹងទេ ប្រហែលជាខ្ញុំមានខ្វះចន្លោះហើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំគិតថា លោកព្រះរាជអាជ្ញាពិតជាមានការខ្វះចន្លោះមែន។ សំណួរគឺ៖> "លោកត្រូវបានចាត់តាំងជាប្រធានសេដ្ឋកិច្ចនៅតំបន់៥?" ហើយសាក្សីឆ្លើយថា៖ "ត្រឹមត្រូវហើយ"។

[១០:៥១:០៩]

**លោក នីកូឡាស គូមជែន៖**

និងគាត់បានពន្យល់ គាត់ថា គាត់ទទួលខាង<ភ័ស្តុភារ> តែសម្រាប់កងចល័តទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមដោះស្រាយបញ្ហានេះឲ្យបានច្បាស់លាស់ សូមសួរទៅលោកសាក្សីផ្ទាល់តែម្តង។ តើលោកត្រូវបានគេចាត់តាំងឲ្យធ្វើជាប្រធានសេដ្ឋកិច្ចតំបន់៥ទាំងមូលតែម្តង ឬយ៉ាងណា?

**លោក ឈិត យឿក៖**

**ឆ៖** អាបញ្ហានោះ គឺយល់ច្រឡំហើយ ព្រោះមួយ មួយតំបន់៥ មួយជាចល័តតំបន់។ វាមិនមែនទៅប្រធានមួយតំបន់៥ឯណា ព្រោះខ្ញុំគ្រាន់តែបំណែកមួយដែលគេប្រើប្រាស់យើងឲ្យចែកចាយអង្ករទៅតាមចល័តបាទ។

**ស៖** បាទ នេះជាការចងចាំរបស់លោក។ ប៉ុន្តែខ្ញុំសូមអានសម្រង់មួយចេញពីឯកសារ E3/178 ឯកសារហៅថា របាយការណ៍ប្រចាំសប្តាហ៍ចេញពីគណៈកម្មាធិការ<តំបន់៥> ចុះថ្ងៃ<២១> ខែឧសភា <១៩៧៧>។ ERN អង់គ្លេស 00342708, បារាំង <00623304> និងខ្មែរ 00275587។ ខ្ញុំដឹងថា យូរហើយក៏ប៉ុន្តែប្រហែលជាលោកឮអំពីរបាយការណ៍នេះ ពេលដែលលោកបំពេញតួនាទីនេះ។ គឺឯកសារសរសេរដូចតទៅ ត្រង់ផ្នែកនិយាយអំពីសភាពការណ៍ការពារប្រទេស។ “ក្រោយពីការ<ស្វែងរកនូវឧបាយកលរបស់ខ្មាំង គឺ>រកឃើញថា អង្ករត្រូវបានគេលាក់នៅភ្នំស្រុក មានលាក់អង្ករ និងអំបិលដូចមាននៅស្រុកព្រះនេត្រព្រះ អង្ករលាក់នៅខាងស្រុកថ្មពួក មានលាក់អង្ករនៅខាងស្រុកស៊ីសុផុន កន្លែងខ្លះមួយតៅ កន្លែងខ្លះកន្លះបាវ កន្លែងខ្លះដាក់ក្នុងបំពង់លាន់ ឬក្នុងគុម្ពឫស្សី។” លោកដែលឮសួរទេលោក ថាគេមានលាក់អង្ករនៅក្នុងបណ្តាស្រុក ខ្ញុំទើបតែអានអម្បាញ់មិញនេះ ពេលវេលាគឺ<ប្រហែល១ខែមុនចាប់>ខ្លួន តាវ៉ាល់?

[១០:៥៤:០២]

**ឆ៖** ទេអានោះ វារឿងទៅដល់ស្រុកនោះ ខ្ញុំចាកចេញពីនោះមកហើយ មកនៅចល័ត។ តែវាគ្រាន់តែឮគេថា អង្ករនៅកន្លះបាវអី នៅដូចថាក្នុងព្រៃដែលថា អ្នកដែលរត់ ឬក៏អីយកទៅទុកម៉េច អានោះ ខ្ញុំអត់ដឹងដែរបាទ។

**ស៖** ចំណុចចុងក្រោយរបស់ខ្ញុំ មានសាក្សីម្នាក់បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយសាក្សីនេះឆ្លើយ នឹកឃើញអំពីការចងចាំនៃការប្រមូលអាវុធ សម្រាប់កម្លាំង គាត់ហៅថាជាកម្លាំងមួយ គឺថាវាយប្រយុទ្ធបំបាក់ជាមួយនឹងកងទ័ពខ្មែរក្រហម។ លោកដែលឮថា<មានការស្តុកអង្ករសម្រាប់កម្លាំង>ភូមិភាគពាយ័ព្យ ដើម្បីធ្វើការបះបោរប្រឆាំងជាមួយនឹងខ្មែរក្រហមដែរទេ?

**ឆ៖** បាទ ខ្ញុំដូចជាមិនធ្លាប់ឮ។ តែខ្ញុំយល់ថា បើគេធ្វើដល់កម្រិតនោះហើយ ឋានៈប្រហែលខ្ញុំប្រហែលជានឹងមិនដឹងបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ហើយ។ សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជម្រាបសួរអស់លោក លោកស្រី ដែលមានវត្តមាននៅទីនេះ។

[១០:៥៦:១៤]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ អាទួរ វែកគែន ខ្ញុំជាមេធាវីការពារលោក ខៀវ សំផន ខ្ញុំមានសំណួរខ្លីទេ។ បាទ សហភាតារបស់ខ្ញុំ លោក គង់ សំអុន នោះក៏គាត់មានសំណួរបន្តិចបន្តួចដែរ។ បាទ ជាសំណួរដើម្បីសុំការបំភ្លឺមួយ។ នៅពេលដែលអានសំណួរលោក ហើយនិងស្តាប់ចម្លើយរបស់លោកនោះ ខ្ញុំដូចជាភ្ញាក់ផ្អើលបន្តិចដែលឃើញលោកនិយាយហើយដដែលៗ ថាលោកមិនដឹងអំពីមូលហេតុនៃការដែលគេដកលោកចេញពីតំណែង គឺដោយ តាវ៉ាល់ ដកលោកចេញពីតំណែង។ ខ្ញុំធ្វើការកត់សម្គាល់នេះ ដោយសារតែយើងមានមនុស្សជាច្រើនដែលមកផ្តល់សក្ខីកម្មនៅទីនេះ ដែលសុទ្ធតែជាអ្នកដែលធ្លាប់ធ្វើការនៅក្រោមរបបខ្មែរក្រហម ហើយអ្នកទាំងអស់នោះ នៅពេលដែលគេត្រូវបានដកចេញពីតំណែងហើយ គេតែងតែដឹងពីមូលហេតុនៃការដកពីតំណែង ពីព្រោះថាជាទម្លាប់កាលនៅសម័យនោះៗ គឺគេតែងតែធ្វើការស្វ័យទិតៀន នៅពេលដែលគេដាក់ទណ្ឌកម្មដល់ខ្លួននោះ គេចង់ឲ្យអ្នកនុំងរីកចម្រើន កែប្រែ។ អ៊ីចឹង ខ្ញុំដូចភ្ញាក់ផ្អើលមែនទែន នៅពេលដែលលោកនិយាយថា លោកមិនដឹងពីមូលហេតុនៃការដកលោកចេញពីតំណែង គឺតាវ៉ាល់ គាត់ដកលោកចេញពីតំណែងនោះ។ អម្បាញ់មិញនោះលោកបាននិយាយថា លោកពន្យល់អំមិញ បើតាមការបកប្រែជាភាសាបារាំងដែលខ្ញុំឮ គឺលោកនិយាយថា លោកបានឮថា លោកនោះត្រូវបានគេចោទថា ដោយលោក<ជា>កូនប្រធានភូមិអង្គាល់សម័យ

មុន។ អ៊ីចឹង ខ្ញុំដូចជាមិនយល់ថា ហេតុអីក៏គេរិះគន់លោកបែបនេះ? ហេតុអីក៏លោកនៅតែបញ្ជាក់ថា លោកនៅតែមិនដឹងអំពីមូលហេតុនៃការដកលោករូបលោកចេញពីតំណែងនោះ? អ៊ីចឹង លោកអាចពន្យល់បានទេហេតុអីក៏លោកច្បាស់លាស់យ៉ាងដូច្នេះ?

[១០:៥៨:៣០]

**លោក ឈិត យឿក៖**

**ឆ៖** បាទ ព្រោះខ្ញុំអាចពន្យល់បាន តែជំនាន់នោះ បើកាលណាយើងមានជាប់និន្នាការ ដូចថា កូនជំទប់ មេភូមិ មេឃុំពីជំនាន់ លន់ នល់ គេអាចដកយើងបាន។ តែអាមូលហេតុផ្សេងៗនោះ វាមិនអាចដឹងទេ ព្រោះក្នុងនោះ ព្រោះវាមិនដឹងថាមូលហេតុអី ប៉ុន្តែខ្ញុំដឹងច្បាស់ថា មានគេអ្នករាយការណ៍ទៅថា ខ្ញុំនេះជាកូនមេភូមិ ហើយជំទប់លេខ១ ឯណាណោះទៅ បានខ្ញុំលែងនិយាយកើតទៅ។ ចប់ បាទ។

**ស៖** បាទ ខ្ញុំយល់ចម្លើយរបស់លោក។ មានចំណុចមួយទៀត ដែលខ្ញុំចង់សួរលោកដែរ គឺទាក់ទងទៅនឹងក្មេងៗ។ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននោះ គេបានចោទសំណួរទៅលោកទាក់ទងនឹងចំណុចនេះ។ អ៊ីចឹងខ្ញុំសូមអានចម្លើយរបស់លោក ដែលមាននៅក្នុងប្រតិចារឹកនៃតុលាការយើងនេះ គឺថ្ងៃទី១៣ ខែសីហា ក្រោយម៉ោង១៥:២៥:២៨វិនាទីបន្តិច។ ខ្ញុំសូមដកស្រង់៖ "ទាក់ទងទៅនឹងត្រពាំងថ្ម តើមានកូនក្មេងធ្វើការនៅទីនោះដែរឬទេ?" លោកឆ្លើយថា៖ បាទ មាន ពីព្រោះថាខ្ញុំជាអ្នកទទួលបន្ទុកក្នុងការចែកអង្ករទៅទីនោះ ហើយរបបអាហារសម្រាប់ក្មេងៗ តិចជាមនុស្សធំ។ ហើយទាក់ទងនឹងផែនការការកំណត់ការងារ ខ្ញុំមិនដឹងទេ។ ហើយជាការពិតណាស់ មានកុមារដែលធ្វើការនៅទីនោះ ក្មេងៗធ្វើការនៅទីនោះ។ មនុស្សធំទទួលបានបីកំប៉ុងមួយថ្ងៃ ហើយកុមារបាន<ពីរ>កំប៉ុងមួយថ្ងៃ។ ទាក់ទងនឹងកម្រិតការងារឲ្យក្មេងៗនោះ គេចែកការងារយ៉ាងម៉េចដែរ? ចម្លើយ៖ ពិបាកណាស់ ខ្ញុំមិនដឹងថាឆ្លើយឲ្យច្បាស់យ៉ាងដូចម្តេចទេ។ ខ្ញុំអាចនិយាយបានថា ប្រហែលជាពួកគេបានជាប្រហែលជាមួយម៉ែត្រទៅមួយម៉ែត្រកន្លះ មួយមែត្រគូបត្រូវរែក ក៏ប៉ុន្តែឲ្យឆ្លើយឲ្យច្បាស់ថា ប៉ុន្មានឲ្យច្បាស់នោះ ខ្ញុំមិនដឹងទេ។ លោកប្រហែលជាមានសាក្សីផ្សេងទៀតដែលដឹងច្បាស់ជាងខ្ញុំ ក៏ប៉ុន្តែរូបខ្ញុំផ្ទាល់នោះ ខ្ញុំទទួលបន្ទុកតែការចែកអង្ករ ហើយខ្ញុំមិនបានឃ្លាំមើលការដ្ឋាននុំងទេ បើនិយាយឲ្យចំទៅនោះ។" ខ្ញុំសូមបញ្ចប់ការដកស្រង់។

[១១:០១:១២]

អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះលោកសាក្សី លោក កូប៉េ ដែលទើបនឹងនិយាយពីសាក្សីនុំង ដែល

ទើបតែបានឆ្លើយមុនលោកនេះ។ លោកសាក្សីរូបនោះ គាត់ត្រូវបានចោទសំណួរទាក់ទងចំណុចដែលខ្ញុំទើបនឹងលើកឡើងហ្នឹងដែរ គឺនៅថ្ងៃទី១២ សីហា គឺមុនពេលដែលលោកមកផ្ដល់សក្ខីកម្មនៅទីនេះមួយថ្ងៃ។ ក្រោយម៉ោងប្រាំបួន ហាសិបពីរនាទីបន្តិច សំណួរគេសួរថា៖ “នៅ<ការដ្ឋាននេះ មានកងចល័ត> មានមនុស្សធំ <មានប្រុស មានស្រី, តើមានកុមារទេ?> ហើយបើសិនជាមាននោះ មានប៉ុន្មាននាក់ដែរ?” ចម្លើយដែលគេឆ្លើយថា៖ “មិនមានកុមារ<ក្នុងកងចល័តទេ។> កុមារគេដាក់នៅក្នុងក្រុមផ្សេងដែលគេហៅថា កន្លែងរក្សាកុមារនៅតាមភូមិ គឺថាមានយាយចាស់ៗអ្នកមើលកុមារទាំងអស់នោះ។” សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងលោកសាក្សី ខ្ញុំដោយសារចម្លើយលោក ដែលបានឆ្លើយកាលពី<ថ្ងៃព្រហស្បតិ៍>អាទិត្យមុននោះ ព្រោះថាលោកប្រយ័ត្នប្រយែងដែរ លោកនិយាយថា លោកប្រហែលជាមិនជាអ្នកដឹងច្បាស់ជាងគេនោះទេ ដែលទាក់ទងនឹងការងារកុមារនេះ។ អ៊ីចឹងខ្ញុំសូមសួរលោក តើឲ្យដឹងឲ្យច្បាស់ ថាតើ -- ខ្ញុំចង់សួរឲ្យច្បាស់ថាតើលោកដឹងអំពីការងារកុមារហ្នឹងដល់កម្រិតណាដែរ នៅការដ្ឋានទំនប់ត្រពាំងថ្មនោះ? តើលោកឃើញកុមារៗ ធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹងដែរ ឬក៏យ៉ាងណា?

[១១:០២:៤៧]

**ឆ៖** កុមារដែលមកធ្វើនៅអាងត្រពាំងថ្ម វាមិនមែនជាកុមារល្អិតល្អោចប៉ុន្មាន ប៉ុន្តែវាជិតជំទង់ៗហើយ ប៉ុន្តែគេដាក់ថាកុមារ។ ហេតុនេះ ខ្ញុំក៏ថាកុមារទៅ តែកុមារមួយដែលមានសាក្សីមុនផ្ដល់ឲ្យថា វាមានកន្លែងគេទុកដាក់នៅតាមភូមិ អានោះគឺខ្ញុំជឿថាមែន ព្រោះកុមារល្អិតល្អោចអី គឺនៅតាមភូមិ មានជាក្រុមគេបាទ។

**ស៖** បាទ ខ្ញុំសូមអរគុណដែលបានឆ្លើយបញ្ជាក់។ បាទ ដើម្បីឲ្យច្បាស់ជាងនេះទៀត ចំពោះលោកនោះ ក្មេងជំទង់នោះមានអាយុចាប់ពីប៉ុន្មានឡើងទៅ? ចំពោះរូបលោកផ្ទាល់នោះ នៅពេលថាមានក្មេងជំទង់នៅការដ្ឋានទំនប់ត្រពាំងថ្មនោះ លោកចង់សំដៅចាប់ពីអាយុប៉ុន្មានឡើងទៅ?

**ឆ៖** ខ្ញុំគិតថា ប្រហែលជាពី១៣ ទៅ ១៥, ១៦។

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរហើយនៅពេលនោះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមជម្រាបសួរលោកសាក្សី ខ្ញុំ គង់ សំអុន។ ខ្ញុំមានសំណួរតិចទេ ចង់សួរបញ្ជាក់

លោក។ ខ្ញុំបានពិនិត្យទៅលើឯកសារស្តាប់ចម្លើយរបស់លោកលេខ E3 (សូមទោស) E127/7.1.6 ហើយទាក់ទងនឹងសំណួរទី១០។ ហើយខ្ញុំក៏បានស្តាប់នូវសក្ខីកម្មរបស់លោក កាលពីថ្ងៃទី១៣ អាទិត្យមុននេះផងដែរ លោកបានឆ្លើយបញ្ជាក់ថា លោកជាឈ្លប ហើយក្រោយមកថាលោកថា លោកធ្វើការអាចជាមេឈ្លបគ្រប់គ្រងមនុស្សមួយចំនួន។ លោកអាចបញ្ជាក់ពីឋានៈពិតប្រាកដរបស់លោកថា បានទេថា ក្នុងឋានៈជាឈ្លបនោះ លោកស្ថិតនៅក្នុងឈ្លបអ្វី? មានថ្នាក់ភូមិ ឃុំ ស្រុក ឬក៏តំបន់ជាដើម លោកអាចបញ្ជាក់បានទេ?

[១១:០៥:៤០]

**លោក ឈិត យឿក៖**

**ឆ៖** បាទ ខ្ញុំអាចបញ្ជាក់បាន។ តែអង្កាល់ណោះ ពេលដែលយើង លន់ នល់ ចាញ់ខ្មែរក្រហមចូលមក ហេតុនេះ មុនដំបូងនោះអត់មានរចនាសម្ព័ន្ធអីថា ត្រូវទៅឯណាមកឯណីទេ គឺគេចាត់ចែងថាឈ្មោះនេះៗ ឥឡូវត្រូវដើរមើលប្រជាជនអី ក៏ដើរមើលតាមគេទៅបាទ។ វាមិនមែនជារៀបចំជាស្ទីរទេ ព្រោះបើនៅក្នុងព្រៃ អានោះមែន។ ដល់មកនោះ វាបែកគ្នាអស់ហើយ ទៅម៉ែទៅឪរៀងខ្លួនទៅបាទ។

**ស៖** លោកអាចចាំបានថា ស្ថិតនៅក្នុងរចនាសម្ព័ន្ធថ្នាក់ណាបានទេ?

**ឆ៖** រចនាសម្ព័ន្ធ បើតាមខ្ញុំដឹងដូចថា វាមិនដឹងថាភូមិ ឃុំអីអត់ទេ មិនដឹង ព្រោះដូចថាមានគេទុកមនុស្សម្នាក់នេះឲ្យទទួលខុសត្រូវ ក៏ខុសត្រូវទៅ។ ក្នុងនាមខ្ញុំដែលមកពីព្រៃនោះ ក៏គេជម្លៀសដូចគ្នាមានឲ្យនៅនឹងភូមិឯណា។ ម្ល៉ោះហើយវាពិបាកដែរ ពិបាកនឹងជម្រាបថា វារចនាសម្ព័ន្ធវាមានត្រឹមណាត្រឹមណីអី គឺអត់បានដឹងទេលោក។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារដែលខ្ញុំបានអានជូនអំមិញនេះ គឺកំណត់ហេតុរបស់លោក ត្រង់សំណួរចម្លើយលេខ១១។ សំណួរសួរថា៖ "ពេលលោកធ្វើជាឈ្លប តើលោកធ្វើអ្វីខ្លះ? ហើយត្រូវរាយការណ៍ទៅណាអ្នកណា?" ចម្លើយរបស់លោកគឺលោកឆ្លើយថា៖ "ខ្ញុំត្រូវរាយការណ៍ទៅប្រធានកងទ័ពតំបន់៥ នៅស្រុកព្រះនេត្រព្រះ។" ខ្ញុំចង់សួរថា តើមានរចនាសម្ព័ន្ធអ្វីជាក់លាក់ដែលថាឈ្លបត្រូវរាយការណ៍ទៅកងទ័ពតំបន់? លោកអាចបញ្ជាក់បានទេ?

[១១:០៧:០០]

**ប្រធានអង្គជំនុំ៖**

កុំទាន់ឆ្លើយតបសាក្សី! ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ។

**លោក ឈិត យឿក៖**

**ឆ៖** ព្រោះអង្គាល់ណោះវាអត់ទាន់បានដឹងរឿងរ៉ាវអីច្បាស់ទេ ព្រោះបើឮគេថាតំបន់ គឺតំបន់នឹងគេទៅ។ តែមិនដឹងជាទ័ពគេឲ្យវាយទៅខាងណាខាងណី តែមួយរយៈពេលដែលខ្ញុំធ្វើបានមួយរយៈនោះ គឺអត់មានបានវាយការណ៍ទៅឯណាផង។ ហើយក្រោយក៏គេឈប់ឲ្យធ្វើអស់ទៅ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងចំណុចមួយទៀត លោកបានលើកផងដែរកាលពីថ្ងៃទី១៣ ទាក់ទងទៅនឹងវត្តមានរបស់ យាយថែម ហើយមុននេះក៏លោកបានបញ្ជាក់ដែរថា យាយថែម គឺជាគណៈស្រុកព្រះនេត្រព្រះ។ ហើយលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លេខ១៣ លោកបញ្ជាក់ថា យាយថែម មកស្រុកព្រះនេត្រព្រះហ្នឹងគឺជំនួសឈ្មោះ រិន។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើឈ្មោះ រិន ដែលលោកបាននិយាយកន្លងមកហ្នឹង គាត់មកស្រុកព្រះនេត្រព្រះក្នុងពេលណាដែរ ហើយកាន់ជាគណៈស្រុកហ្នឹងក្នុងអំឡុងពេលណា? លោកចាំបានទេ?

**ឆ៖** ខ្ញុំវាមិនច្បាស់ តាមដែលយើងប៉ាន់ស្មានបែបក្នុងឆ្នាំ៧៧ តែវាមិនដឹងថាពាក់កណ្តាលឆ្នាំ ឬក៏វាចុងឆ្នាំទៀត វាយ៉ាប់អ៊ីចុះ វាមិនបានគិតដែរ។

[១១:១០:០៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់នូវសក្ខីកម្មរបស់លោក ជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ត្រង់សំណួរចម្លើយលេខ១៣។ លោកបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ "នៅតំបន់៥ ក្រោយពេល តាហ៊ីង្ស ត្រូវបានចាប់ខ្លួន តាជាល បានឡើងជំនួសពីរបីខែ។ រួចហើយ រិន (អ្នកនិរតី) បានឡើងជំនួស តាជាល ប្រហែលជាក្នុងខែមីនា ឬខែមេសា ឆ្នាំ១៩៧៨។ ហើយខ្ញុំមិនស្គាល់អនុរបស់គាត់ទេ។" បាទអ៊ីចឹងនៅក្នុងនេះ លោកឆ្លើយថាក្នុងខែមីនា ឬខែមេសា ឆ្នាំ១៩៧៨ហ្នឹង ឈ្មោះ រិន (អ្នកនិរតី) ឡើងមកជំនួស តាជាល។ តើលោកចាំបានទេថា សក្ខីកម្មដែលលោកផ្តល់ឲ្យនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមុននោះត្រឹមត្រូវ ឬមួយក៏អ្វីដែលលោកទើបមានប្រសាសន៍អំមិញនេះ ត្រឹមត្រូវ?

**ឆ៖** បាទ បើតាមខ្ញុំគិតទៅ ប្រហែលដែលខ្ញុំនិយាយអំមិញដូចថា ពាក់កណ្តាល៧៧ ឬក៏ចុងឆ្នាំ ៧៧ បាទ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទង យាយថែម លោកបានបញ្ជាក់មុននេះអំមិញហើយថា លោកមិនបានជួបគាត់ដោយផ្ទាល់ទេ នៅមុន នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ លោកបានធ្វើ

ទាហានជាមួយគាត់ហ្នឹងរហូតដល់ក្រោយ៧៩ហើយទេ។ ខ្ញុំចង់សួរលោកថា លោកមានទំនាក់ទំនងអ្វីដែលអាចឲ្យលោកដឹងពីវត្តមានរបស់ យាយថែម ពេលដែលគាត់មកធ្វើជាគណៈស្រុកព្រះនេត្រព្រះនេះដែរទេ?

**ឆ៖** បាទ អង្កាល់ណោះ គាត់មកធ្វើគណៈស្រុកព្រះនេត្រព្រះ ខ្ញុំនៅឯចល័តឯណោះបាទ មិនសូវបានដឹងទេ។

[១១:១២:៤០]

**ស៖** បាទ សំណួររបស់ខ្ញុំបន្ទាប់ទៀត ចង់ដឹងថា ចុះម៉េចបានលោកដឹងថា គាត់យាយថែមហ្នឹងមកធ្វើជាគណៈស្រុកព្រះនេត្រព្រះ? លោកដឹងនៅពេលណា?

**ឆ៖** ដែលដឹងនោះ នៅពេលដែលដូចខ្ញុំជម្រាបថា ពាក់កណ្ដាល៧៧ ឬក៏ចុងឆ្នាំ៧៧ ឮគេនិយាយថា យាយថែម គាត់ធ្វើជាគណៈស្រុកព្រះនេត្រព្រះបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកមានដឹងថា យាយថែម គាត់មានទំនាក់ទំនងអ្វី ទៅនឹងទំនប់ទឹកត្រពាំងថ្មនេះដែរទេ?

**ឆ៖** បើគិតពី យាយថែម ដូចជាមិនទាន់បានទៅទំនាក់ទំនងអីពីរឿងទំនប់ប្រឡាយអីនៅត្រពាំងថ្មទេ។

**ស៖** សូមអរគុណ។ លោកដឹងពីតួនាទីរបស់គាត់ក្នុងការគ្រប់គ្រង ឬក៏ធ្វើទំនប់ត្រពាំងថ្មដែរទេ?

**ឆ៖** ខ្ញុំមិនបានដឹងរឿងការដែលថា គម្រោងគាត់ត្រូវធ្វើយ៉ាងម៉េចអីនៅអាងត្រពាំងថ្មតទៀតអានោះខ្ញុំអត់បានដឹងបាទ។

**ស៖** បាទ សូមអរគុណ។ ត្រឡប់ទៅឈ្មោះ រិន វិញ លោកបញ្ជាក់ថាឈ្មោះ រិន នេះ មកពីនិរតី។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើគាត់មានស្រុកកំណើតមកពីនិរតី ឬក៏គាត់ជាកម្មាភិបាលដែលមកពីនិរតី ដែលមកធ្វើជាគណៈស្រុកនៅព្រះនេត្រព្រះ?

[១១:១៥:០៦]

**ឆ៖** គាត់ជាកម្មាភិបាលមកពីភាគនិរតី បាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សវនាការស្ដាប់សក្ខីកម្មសាក្សី ឈិត យឿក នាពេលនេះដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឈិត យឿក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណង់ចង់ទៅបានហើយ។ សូមលោក យឿក មាន ជួបតែសំណាងល្អ មានសេចក្ដីសុខសេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី ឈិត យឿក វិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណង់ចង់ទៅបានហើយ។

ហើយសវនាការជាបន្តនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-828 ដែលមានលោក ឌុច ផារី ជាមេធាវីប្រឹក្សាសាក្សី ហើយអង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវី ឌុច ផារី មកបន្តចូលរួមផ្ដល់សក្ខីកម្មនៅរសៀលនេះបន្តទៀត មកចូលរួមសវនាការនៅរសៀលនេះបន្តទៀត។

[១១:១៦:៤៧]

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅរសៀលនេះអង្គជំនុំជម្រះនឹងដំណើរការធ្វើនីតិវិធីសម្បថ សម្រាប់អ្នកស៊ើបអង្កេតថ្មីមួយទៀតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែលទើបបានជ្រើសរើស និងផ្ដល់សម្បទាដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ហើយនីតិវិធីសម្បថនឹងប្រព្រឹត្តទៅនៅរសៀលនេះ ដែលនឹងចាប់ផ្ដើមពីម៉ោងមួយរសៀល នៅបន្ទប់សវនាការនេះ។ ហើយភាគីដែលអង្គជំនុំជម្រះអញ្ជើញចូលរួម គឺសហព្រះរាជអាជ្ញា ឬតំណាងសហព្រះរាជអាជ្ញា ក្រឡាបញ្ជីអញ្ជើញអ្នកស៊ើបអង្កេតថ្មីដែលនឹងត្រូវធ្វើសម្បថឲ្យមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ ឲ្យបានម៉ោងមួយរសៀលនេះ។ ហើយដោយឡែកភាគីដទៃទៀតបើសិនបើមានបំណងចូលរួមជាភ្ញៀវកិត្តិយស ក៏អាចចូលរួមបាននៅវេលាម៉ោងមួយរសៀល តែបើមិនមានបំណងចូលរួមទេ គឺសូមពន្យារពេលនៅក្នុងការចូលមកកាន់ទីកន្លែងរៀងៗខ្លួន នៅក្នុងបន្ទប់សវនាការនេះ នៅក្រោយដែលអង្គជំនុំជម្រះធ្វើនីតិវិធីសម្បថចប់ ដែលទំនងជាអាចប្រព្រឹត្តទៅត្រឹម រហូតដល់ម៉ោងមួយ ម្ភៃនាទី។

ហើយអង្គជំនុំជម្រះសម្រេចផ្អាកសវនាការព្រឹកនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:១៨ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះចាប់ផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-828 ហើយសាក្សីរូបនេះ មានលោកមេធាវី ឌុច ផារី ដែលជាមេធាវីប្រឹក្សាសាក្សី។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ ឈុំ សេង។

**ស៖** អរគុណលោក ឈុំ សេង។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** ខ្ញុំបាទកើតនៅថ្ងៃទី០៣ ខែ៤ ឆ្នាំ១៩៥៤។

[១៣:៣៣:២៦]

**ស៖** អរគុណ។ ហើយតើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទទីកន្លែងកំណើតនៅភូមិភ្នំលៀប ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង។

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ន ខ្ញុំបាទរស់នៅភូមិតាវង ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** អរគុណ។ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំប្រកបមុខរបរធ្វើស្រែ។

**ស៖** អរគុណ។ តើឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុករបស់ខ្ញុំឈ្មោះ នូ គិន (ស្លាប់)។ ម្ដាយឈ្មោះ ហូ សួង (ស្លាប់)។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ វឿ ធូ។ មានកូនចំនួនបីនាក់។

**ស៖** អរគុណលោក ឈុំ សេង។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរទេ?

[១៣:៣៥:១០]

**ឆ៖** បាទ គឺពិតជាត្រឹមត្រូវ។

**ស៖** ហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានធ្វើសម្បថរួចហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទបានធ្វើសម្បថរួចហើយ។

**ស៖** បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក ក្នុងឋានៈជាសាក្សី។ អំពីសិទ្ធិ លោក ឈុំ សេង ក្នុងឋានៈជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬ

ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិដល់សាក្សីរួចហើយ អម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះដែរឬទេ?

[១៣:៣៦:៤៦]

**ឆ៖** បាទ ខ្ញុំបាទយល់ខ្លះ មិនយល់ខ្លះ។

**ស៖** ក្នុងករណីមានបញ្ហា ដែលក្នុងការដែលលោកអាចថា ជាសំណួរដាក់បន្ទុក ដាក់ពិរុទ្ធភាពលើខ្លួនលោកដែលនាំឲ្យឆ្លើយតបរបស់លោកដាក់ពិរុទ្ធភាពនោះ គឺលោកបានស្នើសុំឲ្យមានមេធាវីប្រឹក្សាសាក្សីរួចហើយ។ ហើយអង្គជំនុំជម្រះតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានចាត់តាំងលោកមេធាវី ឌុច ផារី ក្នុងការជួយលោកនៅក្នុងការដោះស្រាយបញ្ហានេះហើយ។ បានន័យថា គាត់នឹងមានសមត្ថភាពនៅក្នុងការពិនិត្យ ស្ដាប់នូវសំណួរទាំងឡាយដែលវានាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក វាអាចមានដាក់ពិរុទ្ធភាពលើខ្លួនឯង។ គឺលោកអាចឆ្លើយតប ឬមិនឆ្លើយតបក្នុងករណីសំណួរបែបនេះ។

ហើយបញ្ហាទី២ គឺករណីយកិច្ច យើងបានប្រាប់រួចហើយអំមិញ គឺត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ បានជួបប្រទះដោយផ្ទាល់ចៀសវាង ឆ្លើយស្មាន អាហ្នឹងគឺមិនមែនជាភស្តុតាងនៅក្នុងផ្លូវតុលាការទេ។ ហើយរាល់សំណួរដែលភាគី ឬចៅក្រមសួរចំពោះសាក្សីត្រូវតែឆ្លើយតប ទោះបីកម្រិតឆ្លើយតបថា “មិនដឹង” ក៏ជាចម្លើយតបដែរ។ នេះជានីតិវិធីដែលត្រូវឆ្លើយដេញដោល សួរចោទឆ្លើយតាមផ្លូវតុលាការ។ លោក ឈុំ សេង តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? ធ្វើនៅពេលណា?

[១៣:៣៨:៣៨]

**ឆ៖** បាទ ខ្ញុំបាទ បានធ្វើពីរដង គឺនៅនឹងផ្ទះរបស់ខ្ញុំបាទ។

**ស៖** អរគុណ។ ហើយលោកចាំទេ ចាំពេលវេលាទេ នៅក្នុងប្រហែលអំឡុងឆ្នាំណា ឬក៏ប៉ុន្មានឆ្នាំកន្លងមកហើយ? លោកប្រហាក់ប្រហែលបានទេ?

**ឆ៖** ខ្ញុំបាទ ពុំបានចាំថ្ងៃទីទេ ក៏ប៉ុន្តែខ្ទង់ឆ្នាំ១៩១១ លើកទី១។ លើកទី២ ហ្នឹងគឺរយៈកន្លងមកមួយឆ្នាំហើយ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទ បានអានម្តងហើយ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នា ឬស្របគ្នាទៅនឹងចម្លើយដែលលោកផ្តល់កិច្ចសម្ភាសន៍កាលពីមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៅនឹងផ្ទះរបស់លោកនោះដែរឬទេ?

**ឆ៖** បាទ មានចំណុចខ្លះក៏ខ្ញុំបាទចាំ តែយូរហើយ មានចំណុចខ្លះក៏ខ្ញុំបាទមានភ្លេចខ្លះដែរ។

[១៣:៤០:១១]

**ស៖** អរគុណ។ ហើយលោក ឈុំ សេង នៅពេលនេះលោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើរបស់លោកហើយ គឺលោកមេធាវី ឌុច ផារី។ តើពេលមុនចូលមកចំពោះមុខអង្គជំនុំជម្រះហ្នឹង លោកបានពិភាក្សា ឬបានប្រឹក្សាយោបល់ជាមួយនឹងលោកមេធាវីរបស់លោកហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទបានជួប និងសំណេះសំណាលជាមួយគាត់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ឈុំ សេង មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន។ សូមគោរពលោកចៅក្រម និង ភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទ ឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិ។ តទៅនេះ ខ្ញុំបាទមានសំណួរមួយចំនួនដើម្បីសាកសួរទៅលោកសាក្សី ហើយបន្ទាប់ពីខ្ញុំបាទបានសួរសំណួរមួយចំនួននោះទៅ សហការីរបស់ខ្ញុំដែលជាសហព្រះរាជអាជ្ញារងអន្តរជាតិនឹងបន្តនូវសំណួរមួយចំនួនថែមទៀត។ តើនៅចន្លោះពីថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ លោកត្រូវបានចាត់តាំងឱ្យធ្វើអ្វី? ហើយនៅកន្លែងណាខ្លះ?

[១៣:៤២:១៦]

**លោក ឈុំ សេង៖**

**ឆ៖** នៅក្នុងឆ្នាំហ្នឹង គឺខ្ញុំបាទ គេបានចាត់តាំងឱ្យធ្វើជាកងចល័តពីកំបោរទៅភ្នំស្រេះ ភ្នំកំបោរ-ស្រេះ។

**ស៖** ក្រៅៗពីកំបោរ-ស្រេះហ្នឹង តើមានកន្លែងណាទៀតក្នុងមួយអំឡុងពេលនៃចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ហ្នឹង?

**ឆ៖** លើកទំនប់កំបោរ-ស្រេះរួច លើកទំនប់ពីស្រេះមកព្រះនេត្រព្រះ។ បន្តមកទៀតធ្វើចម្ការកប្បាសនៅជប់វារី លើកអាងត្រពាំងថ្ម ហើយលើកនៅ -- ធ្វើចម្ការកប្បាសនៅស្រុកសិរីសោភ័ណ។

**ស៖** ពាក់ព័ន្ធនឹងទីកន្លែងទាំងអម្បាលម៉ានដែលលោកបានលើកខាងដើមនេះ ខ្ញុំសូមសួរលោកតែចំពោះចំណុចពាក់ព័ន្ធនឹងអាងត្រពាំងថ្ម សូមលោកស្តាប់កន្លែងនេះជ្រាបឱ្យច្បាស់។ អ៊ីចឹងរាល់សំណួរដែលខ្ញុំនឹងតាំងជូនលោកបន្តបន្ទាប់ទៅនេះ គឺពាក់ព័ន្ធតែនឹងចន្លោះពេលដែលលោកស្ថិតនៅក្នុងអាងត្រពាំងថ្ម។ តើអាងត្រពាំងថ្មហ្នឹងស្ថិតនៅទីកន្លែងណា? បានន័យថានៅភូមិណា ឃុំណា ស្រុកណា។

[១៣:៤៣:៥៦]

**ឆ៖** អាងត្រពាំងថ្មស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** តើលោកត្រូវបានបញ្ជូនទៅការដ្ឋាននោះនៅក្នុងឆ្នាំណា?

**ឆ៖** គេបញ្ជូនខ្ញុំបាទទៅនៅឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩។

**ស៖** សូមលោកបញ្ជាក់កន្លែងនេះឲ្យបានច្បាស់បន្តិច គឺនៅពេលដែលគេបញ្ជូនលោកទៅអាងត្រពាំងថ្មនៅក្នុងឆ្នាំណា? ខ្ញុំអត់សំដៅទៅលើការដ្ឋានផ្សេងទៀតទេ គឺសំដៅទៅលើអាងត្រពាំងថ្ម។ សូមលោកបញ្ជាក់កន្លែងនេះឲ្យច្បាស់បន្តិច តើនៅឆ្នាំណាពិតប្រាកដ?

**ឆ៖** ខ្ញុំគឺៗនៅឆ្នាំ១៩៧៧។

**ស៖** សូមលោកជួយបញ្ជាក់បន្តិចមើល តើនៅពេលដែលគេចាត់លោកទៅនៅក្នុងឆ្នាំ១៩៧៧ហ្នឹង លោកអាចចាំបានទេថា តើនៅដើមឆ្នាំ នៅពាក់កណ្តាលឆ្នាំ ឬក៏នៅចុងឆ្នាំ១៩៧៧ហ្នឹង?

**ឆ៖** នៅក្នុងឆ្នាំហ្នឹង គេឲ្យខ្ញុំនៅពីពាក់កណ្តាលឆ្នាំរហូតដល់ចុងឆ្នាំ។

**ស៖** នៅពេលដែលលោកត្រូវបានចាត់តាំងឲ្យទៅដល់អាងត្រពាំងថ្ម នៅពាក់កណ្តាលឆ្នាំ១៩៧៧ហ្នឹង លោកសង្កេតឃើញថា ការដ្ឋានហ្នឹង គេចាប់ផ្តើមដំណើរការឬនៅ?

**ឆ៖** ពេលឆ្នាំហ្នឹង ដំណើរការគេធ្វើបណ្តើរៗតាំងពីមុនខ្ញុំទៅម្ល៉េះ។

[១៣:៤៦:៣៤]

**ស៖** បើតាមការសង្កេតរបស់លោក តើនៅពេលហ្នឹងមានមនុស្ស មានពលករប៉ុន្មាននាក់ចូលរួម?

**ឆ៖** ពេលដែលលើកអាងត្រពាំងថ្មនោះ តាមការពិនិត្យរបស់ខ្ញុំ គឺមានចល័តតំបន់ និងចល័តសហករណ៍។

**ស៖** បើគិតជាចំនួនមនុស្សវិញ ប៉ុន្មានដែរ?

**ឆ៖** បើគិតពីចំនួនមនុស្សប្រហែលជាមានដល់ទៅម៉ឺននាក់។

**ស៖** តើអ្នកទាំងអស់ហ្នឹង ក្រៅពីៗក្រុមលោក មានអ្នកផ្សេងហ្នឹងមកពីកន្លែងណាខ្លះដែរ?

**ឆ៖** ក្រៅពីកងរបស់ខ្ញុំបាទ គឺមានកងច្រើនដែលទៅពីស្រុកព្រះនេត្រព្រះ ស្រុកថ្មពួក។

**ស៖** ពាក់ព័ន្ធនឹងការងារវិញ នៅពេលដែលលោកទៅដល់ ក្នុងអំឡុងពេលតាមដែលលោករៀបរាប់អំមិញហ្នឹង គឺពាក់កណ្តាលឆ្នាំ៧៧ តាំងពីពាក់កណ្តាលឆ្នាំ៧៧មក តើលោកត្រូវបានគេចាត់តាំងឲ្យធ្វើការងារអ្វីខ្លះ តាំងពីចាប់ផ្តើមទៅដល់ រហូតទៅដល់ពេលបញ្ចប់?

**ឆ៖** ពេលទៅដល់គេចាត់តាំងឲ្យរូបខ្ញុំ ក្នុងកងខ្ញុំរែកទឹកលាយស៊ីម៉ង់ត៍ធ្វើស្ពានទី១។

**ស៖** បន្ទាប់មកទៀត?

**ឆ៖** បន្ទាប់មកទៀត ពេលដែលស៊ីម៉ង់ត៍ ខ្សាច់ ថ្មអស់ គេក៏ឲ្យកងខ្ញុំរែកដីដាក់ទំនប់ជាធម្មតា។

**ស៖** អ៊ីចឹងបានន័យថា ទៅដល់ការដ្ឋានអាងត្រពាំងថ្មភ្លាម កងរបស់លោក គឺត្រូវបានចាត់តាំងឲ្យរែកទឹកធ្វើស្ពាន ហើយបន្ទាប់មកបានឲ្យរែកដីចាក់ទំនប់។ អ៊ីចឹងមែនទេបាទ?

[១៣:៤៩:៤៥]

**ឆ៖** បាទៗ ពិតដូចលោកមានប្រសាសន៍។

**ស៖** ចុះក្រៅពីការងារនេះ មានការងារណាផ្សេងទៀត ដែលលោក និងកងរបស់លោកបានទទួលគួរឲ្យកត់សម្គាល់ ជាការងារធំៗ ក្រៅពីរែកទឹកលាយស៊ីម៉ង់ត៍ ក្រៅពីរែកដី លើកទំនប់ តើមានការងារអីផ្សេងពីហ្នឹងទៀតទេ?

**ឆ៖** បើនៅទំនប់អាងត្រពាំងថ្ម គ្មានអ្វីក្រៅពីហ្នឹងទេ។

**ស៖** ពាក់ព័ន្ធនឹងការងារនេះ តើក្រុមរបស់លោកត្រូវបានចាត់តាំងឲ្យបំពេញការងារដូចម្ដេចដែរ? បានន័យថាបែងចែកការងារយ៉ាងដូចម្ដេច? មានផែនការមួយកងទទួលផែនការប៉ុន្មានអីប៉ុន្នានឬក៏ធ្វើរួមគ្នារហូត?

**ឆ៖** ពេលហ្នឹងដែលខ្ញុំធ្វើការងារហ្នឹង គឺគេបែងចែកជាកង ជាវរៈសម្រាប់កាប់ដី រែកដាក់លើអាងត្រពាំងថ្ម។

**ស៖** ចំណុចត្រង់នេះ គឺលោកសំដៅទៅលើការងារដែលទទួលបន្ទុកខាងរែកដីដាក់អាងត្រពាំងថ្ម។ អ៊ីចឹងការកាប់ដីហ្នឹង តើមានផែនការយ៉ាងម៉េចដែរ? ឧទាហរណ៍ថា បានន័យថាលោកត្រូវធ្វើតាមអំពើចិត្ត ធ្វើបានប៉ុនណាយកប៉ុណ្ណឹង ឬក៏មានផែនការកំណត់ដែរ?

**ឆ៖** បាទ ធ្វើហ្នឹងគឺធ្វើតាមការកំណត់របស់អង្គការ ក្នុងម្នាក់ គឺរែកដីឲ្យបានពី២ម៉ែត្រគូបទៅ៣ម៉ែត្រគូបក្នុងមួយថ្ងៃ។

[១៣:៥២:០៧]

**ស៖** ចុះការងារហ្នឹង ចំពោះខ្លួនលោកធ្វើទាន់ទេ?

**ឆ៖** នៅក្នុងពេលនោះ ខ្ញុំបាទក៏ធ្វើផ្ទាល់ដែរ តែពុំបានរែកដីនឹងគេទេ គ្រាន់តែនៅលើខ្នងទំនប់ហើយឈូសឆាយពង្រាបឲ្យស្មើ។

**ស៖** លោកមានតួនាទីជាអ្វីដែរ បានលោកអត់វែកដី?

**ឆ៖** ពេលនោះ គេចាត់តាំងឲ្យខ្ញុំបាទធ្វើជាប្រធានកងធំ។

**ស៖** បើដូច្នេះ តើសមាជិកកងរបស់លោកវែកទាន់ទេ ដែលលោកថាចន្លោះពី២ម៉ែត្រគូបទៅ៣ម៉ែត្រគូបហ្នឹង? សូមលោកបញ្ជាក់ឲ្យច្បាស់មើល៍ រវាង២ម៉ែត្រគូបទៅ៣ម៉ែត្រគូបហ្នឹង គឺមានក្នុងថេរវេលាជាក់លាក់ណាមួយ បានន័យថាក្នុងរដូវនេះ ២ម៉ែត្រគូបទាំងអស់គ្នា ក្រោយមក៣ម៉ែត្រគូបទាំងអស់គ្នា ឬក៏ក្នុងពេលតែមួយហ្នឹង អ្នកខ្លះ២ម៉ែត្រគូប អ្នកខ្លះ៣ម៉ែត្រគូប?

**ឆ៖** រឿងវែកដីហ្នឹង គឺគេកំណត់ច្បាស់ ក្នុងមួយថ្ងៃឲ្យបាន៣ម៉ែត្រគូបជារៀងរហូត រាល់ថ្ងៃមិនថាភ្លៀង ឬក៏មិនភ្លៀងទេ។

**ស៖** ពួកគាត់ធ្វើទាន់ទេ ៣ម៉ែត្រគូបក្នុងមួយថ្ងៃ?

**ឆ៖** បាទ មានខ្លះក៏ធ្វើទាន់ តែមានខ្លះក៏ធ្វើមិនទាន់ដែរ។

**ស៖** ចុះបើធ្វើអត់ទាន់ មានអីកើតឡើងចំពោះគាត់?

**ឆ៖** អ្នកដែលធ្វើមិនទាន់ គេកំណត់ថាព្រឹកឡើង គឺឲ្យបានមួយម៉ែត្រគូបកន្លះ ល្ងាចឡើងឲ្យបានមួយម៉ែត្រកន្លះ សរុប៣ម៉ែត្រគូប។ បើមិនបានគម្រប់ផែនការទេ គឺគេបង្អត់អាហារ គេអត់ឲ្យបាយហូប។

[១៣:៥៤:៥០]

**ស៖** ពាក់ព័ន្ធនឹងអាហារនេះ ខ្ញុំនឹងត្រឡប់មកសួរលោកបញ្ជាក់ឲ្យច្បាស់ឡើងវិញ។ ប៉ុន្តែពាក់ព័ន្ធនឹងអ្នកដែលវែកមិនទាន់ក្នុងរយៈពេល ក្នុងអំឡុងពេលមួយថ្ងៃ បានន័យថាវែកអត់គ្រប់៣ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹង ក្រៅពីបង្អត់អាហារ តើមានអ្វីកើតឡើងផ្សេងទៀតចំពោះគាត់ទេ?

**ឆ៖** ពេលដល់ចំណុចនោះ គឺខ្ញុំជាប្រធានកងធំគ្រប់គ្រងតែកងតូចបីនាក់។ ដូច្នេះកងតូចទី១ គឺគ្រប់គ្រងកម្លាំង៣០នាក់ កងតូចទី២ គ្រប់គ្រងកម្លាំង៣០នាក់ កងតូចទី៣ គ្រប់គ្រងកម្លាំង៣០នាក់ ទាំងអ្នកដាំបាយអីទៅ សរុបនេះទៅគឺ១០០នាក់។ ដូច្នេះ៣០នាក់ហ្នឹង គឺខ្ញុំគ្រាន់តែដឹងតែពីប្រធានកងគ្រប់គ្រងប្រធានកងតូចតែប៉ុណ្ណឹងទេ។

**ស៖** ប្រហែលជាលោកស្តាប់សំណួរខ្ញុំអត់បាន ហើយសំណួរខ្ញុំចង់សួរថា ក្រៅៗ -- លោកថាបើធ្វើអត់ទាន់ គេបង្អត់អាហារ តែចំពោះករណីនេះ ខ្ញុំអត់ទាន់សួរបញ្ជាក់ទេ។ ខ្ញុំសួរថាតើក្រៅពីការបង្អត់អាហារហ្នឹង គាត់អាចទទួលរងនូវអំពីណាមកលើគាត់ផ្សេងទៀតទេ ក្នុងករណីដែលគាត់ធ្វើការ

អត់ទាន់?

**ឆ៖** មានខ្លះដែរ ដោយមនោសញ្ចេតនាអីទៅ ខ្វះតិចតួច ក៏ឲ្យទៅហូបបាយ ឬក៏ខ្វះច្រើនបន្តិចក៏ដោយ ក៏ប៉ុន្តែមើលលទ្ធភាពដែលគ្នាធ្វើមិនបាន ធ្វើមិនអស់ ក៏អាចទៅហូបបាយបាន។ ក៏ប៉ុន្តែឡើងក្រោយគេ រហូតម៉ោងប្រាំពីរយប់ក៏មាន។

[១៣:៥៧:០៧]

**ស៖** ពាក់ព័ន្ធនឹងចំណុចចុងក្រោយនេះ តើជាទូទៅ ការងារៗរបស់ក្រុមលោកហ្នឹង ចាប់ផ្តើមពីម៉ោងប៉ុន្មាន ហើយបញ្ចប់ទៅវិញនៅម៉ោងប៉ុន្មាន?

**ឆ៖** ការងារនោះគឺមិនទៀង ជួនកាលម៉ោងបួន ម៉ោងប្រាំម៉ោងប្រាំមួយឡើងក៏មាន ជួនកាលវាយសម្រុកមួយយប់វាល់ព្រឹកក៏មាន តាមផែនការដែលអង្គការកំណត់។

**ស៖** តើជួបប្រទះញឹកញាប់ទេ ក្នុងករណីដែលធ្វើការវាល់ព្រឹក ដូចអ្វីដែលលោកបានលើកឡើងមុនៗហ្នឹងបន្តិចហ្នឹងថា បើៗមានផែនការពីលើមក គឺនឹងធ្វើរហូតដល់វាល់ព្រឹក។ តើមានករណីហ្នឹងកើតឡើងញឹកញាប់ទេ?

**ឆ៖** ក្នុងពេលហ្នឹងគឺពុំសូវបានញឹកញាប់ទេ។ គ្រាន់តែនៅចំណុចណាដែលជ្រៅ រាងយើងរែករហូតដល់ទៅប្រាំមួយ ប្រាំពីរម៉ែត្រហ្នឹង គឺត្រូវតែវាយសម្រុកម្តង កន្លែងដែលទំនាប។

**ស៖** ហើយករណីដែលកើតឡើងធ្វើការទល់ភ្លឺ វាល់ព្រឹកហ្នឹង បានន័យថា ទល់ភ្លឺ ខ្ញុំប្រើពាក្យអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** តើករណីបែបនេះ កើតឡើងជាញឹកញាប់ ហើយមានរយៈពេលយូរប៉ុនណាដែរ?

**ឆ៖** ភាពដែលកើតឡើងនេះ ជួនកាលក៏មួយអាទិត្យ ជួនកាលក៏លើសពីមួយអាទិត្យទៅទៀត។

[១៣:៥៩:៣១]

**ស៖** សូមលោកជួយពន្យល់កន្លែងនេះ ឲ្យបានច្បាស់បន្តិចមើល៍ ខ្ញុំស្តាប់ទៅហាក់ដូចជាមិនសូវយល់ច្បាស់។ លោកបញ្ជាក់ថា ធ្វើការវាល់ព្រឹក ឬក៏មួយយប់ទល់ភ្លឺ។ អ៊ីចឹងបានន័យថាអត់មានពេលសម្រាកសោះ ហើយរយៈពេលនេះ វាកើតឡើងរហូតដល់មួយអាទិត្យ ឬក៏លើស។ អ៊ីចឹងបានន័យថាអត់មានពេលសម្រាកទាល់តែសោះតែម្តង ឬយ៉ាងណា? សូមលោកបញ្ជាក់កន្លែងហ្នឹងឲ្យច្បាស់បន្តិច។

**ឆ៖** បាទ មានពេលសម្រាកតែពេលដែលយើងហូបបបរតែប៉ុណ្ណោះ រួចក៏យើងចុះធ្វើការវិញ។

**សះ** អ៊ីចឹងបានន័យថា ក្នុងមួយថ្ងៃ២៤ម៉ោង គាត់ធ្វើការងាររហូត ពេញមួយអាទិត្យ ឬក៏លើស ដោយសម្រាកតែក្នុងអំឡុងពេលហូបបបរ ក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថានេះ គឺជាការសង្ខេបមួយទូលំទូលាយមែនទែន។ ខ្ញុំគិតថាគាត់មិនបាននិយាយពីរឿងមានអ្នកធ្វើការធ្វើ២៤ម៉ោងអីណានោះទេ។

[១៤:០១:១៤]

**លោក ស្រ៊ា រតនៈ៖**

ចំពោះបញ្ហានេះ លោកប្រធាន ខ្ញុំមិនដឹងថាមានបញ្ហាដោយសារការបកប្រែ ឬយ៉ាងណាទេ ក៏ប៉ុន្តែបើយើងស្តាប់ជាភាសាខ្មែរទៅ ខ្ញុំសួរគាត់បញ្ជាក់ពីរដង។ ទី១ គាត់ថាធ្វើការវាល់ព្រឹក។ វាល់ព្រឹកនេះ ខ្ញុំសួរគាត់បញ្ជាក់ថាតើហ្នឹងធ្វើការមួយយប់ទល់ភ្លឺមែនឬ?

**លោក គង់ សំអុន៖**

លោកប្រធាន ចំណុចល្អប្រហែលជាសហព្រះរាជអាជ្ញាត្រូវសួរសាឡើងវិញទៅលើចំណុចនេះ ហើយបើតាមខ្ញុំស្តាប់មុនដំបូងគឺ សួរពីរឿងរយៈពេល ថាញឹកញាប់ប៉ុនណា ហើយគាត់ថា មួយសប្តាហ៍ម្តង ឬក៏លើស។ ដូច្នេះវា១អាចមានការភ័ន្តច្រឡំ។ អ៊ីចឹងសូមឲ្យព្រះរាជអាជ្ញាសួរសាជាថ្មីទាក់ទងនឹងចំណុចនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សួរបញ្ជាក់ឡើងវិញ វាអាចមានការភ័ន្តច្រឡំ ហើយបើសិនជាមនុស្សឯណាធ្វើការដោយអត់មានសម្រាកសោះ ហើយមួយសប្តាហ៍ ទាំងព្រឹក ទាំងយប់ ទាំងថ្ងៃ អត់ដេក តើអាចធ្វើកើតទេ? សូមបញ្ជាក់បញ្ហានេះឡើងវិញឲ្យច្បាស់លាស់ កុំឲ្យវាមានបញ្ហា ព្រោះបញ្ហានេះពាក់ព័ន្ធជាមួយនឹងការដ្ឋានការងារ វាគឺជាការងារធ្ងន់ធ្ងរ ការងារដោយបង្ខំនៅការដ្ឋាន វាជាចំណុចសំខាន់នៃសវនាការអង្គហេតុនេះ។ ហើយយើងមិនអាចធ្វើគ្រួសៗអ៊ីចឹងបានទេ។

[១៤:០២:៣៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ស្រ៊ា រតនៈ៖**

បាទ លោកប្រធាន ហើយដោយសារថាខ្ញុំស្ដាប់មើលទៅហាក់ដូចជាចម្លែកដែរ បានខ្ញុំសង្កត់សួរគាត់បញ្ជាក់ហើយបញ្ជាក់ទៀត ពីរបីសំណួរក្នុងរយៈពេលនេះ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសុំសាសួរសំណួរនេះ ចំណាយពេលសួរសំណួរនេះឡើងវិញបន្តិច។ ខ្ញុំមុននឹងសួរឲ្យលោកឆ្លើយ ខ្ញុំសូមរំឭកឡើងវិញបន្តិច។ លោកបានឆ្លើយថា ក្នុងម៉ោងធ្វើការហ្នឹងគឺធ្វើការជួនណាឡើងម៉ោងបួន ហើយមានពេលខ្លះវាល់ព្រឹក។ ហើយខ្ញុំសួរបន្ថែមទៀតថា តើធ្វើការវាល់ព្រឹកបែបហ្នឹង កើតឡើងញឹកញាប់ទេ? ហើយបើកើតឡើង តើក្នុងអំឡុងពេលប៉ុន្មានដែរ? លោកស្ដាប់សំណួរខ្ញុំបានទេ ហើយនិងអ្វីដែលខ្ញុំសង្ខេបចម្លើយលោកហ្នឹង តើអ៊ីចឹងមែនទេ?

**លោក ឈុំ សេង៖**

**ឆ៖** អំមិញខ្ញុំស្ដាប់បានដែរ ក៏ប៉ុន្តែខ្ញុំច្រឡំត្រង់ថា ឧទាហរណ៍ថាផែនការមួយអាទិត្យ ធ្វើពីរបីថ្ងៃហ្នឹង គឺរែកទាំងយប់ទាំងថ្ងៃហើយ ក៏ប៉ុន្តែអត់មានពេលសម្រាកទេ។ ក៏ប៉ុន្តែបើផែនការបានមុនអាទិត្យ យើងអាចសម្រាកបានពីរបីម៉ោងដែរ ក្នុងមួយពេល។

**ស៖** អ៊ីចឹងលោកឆ្លើយតបទៅនឹងអ្វី ទៅនឹងសំណួរ -- ខ្ញុំសួរឡើងវិញតែម្ដងពាក់ព័ន្ធនឹងករណីនេះ។ បានន័យថា ក្នុងមួយថ្ងៃ២៤ម៉ោង លោកអត់ នៅពេលដែលសម្រុកខ្លាំងហ្នឹង អត់មានពេលសម្រាកសោះ? ខ្ញុំថាសម្រាកហ្នឹង គឺបានន័យថាពេលដែលលោកត្រូវចូលសម្រាន្ត តើក្នុងរយៈពេល -- ឥឡូវខ្ញុំសួរបញ្ជាក់ឲ្យច្បាស់តែម្ដង។ តែក្នុងលក្ខណៈមួយដែលលោកថាប្រញាប់ខ្លាំង មានផែនការៗនៅក្នុងកន្លែងដែលទំនាបខ្លាំង ៧ម៉ែត្រឡើងលើហ្នឹង លោកបញ្ជាក់ឲ្យច្បាស់ តើលោកធ្វើការប៉ុន្មានម៉ោង? ហើយសម្រាន្តប៉ុន្មានម៉ោង?

[១៤:០៤:៤៩]

**ឆ៖** បាទ នៅពេលព្រឹកយើងហូបបាយ រួចអាចសម្រាកបានពីរម៉ោង។ ហើយពេលល្ងាច ក៏យើងអាចសម្រាកបានប្រហែលជាពីរម៉ោងដែរក្នុងមួយថ្ងៃ។

**ស៖** នេះជាករណីទូទៅ ឬក៏ក្នុងពេលដែលលោកប្រញឹកនឹងការងារខ្លាំង?

**ឆ៖** បាទ នេះជាពេលដែលយើងរើសម្រុក ដើម្បីសម្រេចផែនការកន្លែងណាដែលទាប។

**ស៖** អ៊ីចឹងពេលព្រឹកចាប់ផ្ដើមពីម៉ោងប៉ុន្មាន? ពេលរសៀលចាប់ផ្ដើមពីម៉ោងប៉ុន្មាន? ហើយ

មានការងារយប់ឬអត់?

**ឆ៖** ពេលដែលវាយសម្រុក គឺពុំបានគិតម៉ោងទេ។ គិតតែម៉ោងដែលហូបបាយ ពេលដែលថ្ងៃត្រង់ហូបបាយ ហូបបាយសម្រាកពីរម៉ោង ចុះទៅធ្វើការទៀត រហូតដល់ម៉ោងប្រាំ ម៉ោងប្រាំមួយ ទើបបានហូបបាយម្ដងទៀត។

**ស៖** ចុះបន្ទាប់ពីហ្នឹងមកទៀត មានការងារពេលយប់ទៀតអត់?

**ឆ៖** ពេលដែលផែនការមួយអាទិត្យចប់ នៅផែនការធម្មតា គឺយើងបានហូបធម្មតា ហើយសម្រាកធម្មតា។

**ស៖** អ្វីដែលខ្ញុំកំពុងសាកសួរលោកនៅពេលនេះ គឺពាក់ព័ន្ធនឹងផែនការ។ លោកថាមួយអាទិត្យនេះ ខ្ញុំប្រើប្រាស់ពាក្យលោកថា "ផែនការមួយអាទិត្យ" នេះ តើពេលហ្នឹង លោកមានពេលសម្រាន្តឬទេ?

**ឆ៖** ក្នុងមួយអាទិត្យនេះ បើមានការសម្រាក ក៏សម្រាកតិចតួចណាស់។

[១៤:០៦:៥៦]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាគួរញែកឱ្យបានច្បាស់លាស់ទៅ ហើយពេលថ្ងៃ មួយថ្ងៃហ្នឹង វាអាចច្រឡំថ្ងៃមួយថ្ងៃ២៤ម៉ោង និងមួយថ្ងៃ ពេលដែលមានពន្លឺថ្ងៃ ហើយនិងយប់។ អ៊ីចឹងឱ្យបញ្ជាក់ឱ្យច្បាស់ លោកបានបញ្ជាក់ពីរឿងពេលថ្ងៃ ធ្វើការនៅពេលថ្ងៃរួចហើយ ពីព្រឹកទល់នឹងរសៀល ទល់នឹងល្ងាច នៅពេលយប់ទៀត ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់នៅពេលដែលសម្រុកខ្លាំងហ្នឹង វាយ៉ាងដូចម្ដេច។ កុំឱ្យវាច្រឡំថ្ងៃហ្នឹង គឺពេលថ្ងៃ ពេលមានពន្លឺថ្ងៃ ហើយនិងពេលមួយថ្ងៃ វាមួយថ្ងៃមួយយប់។ ២៤ម៉ោង វាមានមួយថ្ងៃមួយយប់។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឡើងវិញ ពាក់ព័ន្ធនឹងសំណួរនេះដដែល។ គឺនៅពេល ខណៈពេលដែលសម្រុកធ្វើការងារខ្លាំង តើមាន -- បន្ទាប់ពីហូបបាយល្ងាចហើយ តើមានការងារពេលយប់ឬអត់?

**ប្រធានអង្គជំនុំ៖**

ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក ឈុំ សេង៖**

**ឆ៖** ពេលហ្នឹង ធ្វើការរួចហើយ គឺមានពេលសម្រាកប្រហែលជាពីរម៉ោង សម្រាប់ពេលយប់ក៏

ដូចជាពេលថ្ងៃដែរ។

[១៤:០៨:២៣]

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងករណីនេះ។ បានន័យថា ក្រោយពីហូបបាយពីរម៉ោងហើយ ធ្វើការដល់ភ្លឺវិញ?

**ឆ៖** បាទ ក្នុងដំណាក់កាលដែលវាយសម្រុក គឺសម្រាកបានយ៉ាងច្រើន គឺប៉ុណ្ណឹងទេ។ បើថាផែនការប្រាំពីរថ្ងៃ មិនបានដល់ប្រាំពីរថ្ងៃ តែបីបួនថ្ងៃក៏ គឺយើងត្រូវតែបានសម្រាក។ ទៅក្រោយគេ ទៅវិញថែមធម្មតា។

**ស៖** ចុះបើធ្វើការងារអត់មានពេលសម្រាកអ៊ីចឹង ក្នុងខណៈពេលហ្នឹង មានអ្នកតវ៉ានឹងម៉ោងការងារ មានអ្នកប្រកែកថាមិនទៅធ្វើការ ឬក៏ថា អ្ហែ! ម៉ោងច្រើនពេក អត់ធ្វើទេ អត់ទៅធ្វើការ ហើយឬក៏តវ៉ាថា សូមធ្វើតែថ្ងៃ អត់ធ្វើយប់ទេ ពេលនុ៎ង?

**ឆ៖** អាចមានខ្លះ ក៏ប៉ុន្តែមិនអាចនិយាយឲ្យអ្នកណាដឹងបានទេ និយាយតែគ្នាឯង។

**ស៖** លោកចង់មានន័យថាម៉េច និយាយតែគ្នាឯង អត់មានឲ្យអ្នកណាដឹង? បានន័យថា អត់មានតវ៉ាជាមួយនឹងថ្នាក់លើទេ ចង់មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលហ្នឹងគឺនិយាយតែគ្នាឯងប៉ុណ្ណឹងទេ តែមិនអាចនិយាយឲ្យអង្គការខាងលើដឹងបានទេ។

**ស៖** ជាទូទៅ តើចំពោះលោក និងកងរបស់លោក ការហូបចុកនៅក្នុងការដ្ឋានការងារហ្នឹងយ៉ាងដូចម្ដេចដែរ? បានន័យថា តើគ្រប់គ្រាន់ ឬក៏មានការខ្វះខាតយ៉ាងដូចម្ដេច?

[១៤:១០:៤៨]

**ឆ៖** ពេលហ្នឹងគឺហូបពុំបានគ្រប់គ្រាន់ទេ។ ពេលណាដែលអង្ករគេដឹកមកទាន់ពេលវេលាក៏បានហូបបបរមធ្យមទៅ។ ពេលណាដឹកអង្ករមិនទាន់ ក៏ហូបបបររាវ តែពុំដែលបានឆ្អែតទេ។

**ស៖** ក្រៅពីបរិមាណដែលលោកទទួលបានហ្នឹង តើម្ហូបអ្វីខ្លះដែល ប្រភេទម្ហូបអ្វីខ្លះដែលលោកទទួលបាននៅពេលនោះ?

**ឆ៖** នៅពេលនោះ ជួនកាលអំបិល ជួនកាលមានប្រហុក ជួនកាលក៏មានត្រីងៀត ដែលពួកនេសាទគេបញ្ជូនមកដល់កងរបស់ខ្ញុំបាទ។

**ស៖** បើគិតទៅ តើទាំងម្ហូបទាំងបាយ -- ខ្ញុំប្រើពាក្យថា "ម្ហូប" នេះគឺសំដៅលើសម្ល និងបាយ

រួមគ្នាតែម្តង។ តើបើគិតពីគុណភាពវិញ ម្ហូបអាហារដែលលោកទទួលបានហ្នឹង និងកងរបស់លោកទទួលបានហើយយកទៅហូបពេលហ្នឹង តើវាឆ្លើយតបទៅនឹងទំហំការងារដែលលោកត្រូវបំពេញ ឬទេ? បានន័យថា តើហូបទៅហ្នឹង វាមានកម្លាំងគ្រប់គ្រាន់ ដើម្បីលើកដី៣ម៉ែត្រគូបក្នុងមួយថ្ងៃដែរឬទេ?

**ឆ៖** ពេលហ្នឹង ជួនកាលប្របហុក ជួនកាលត្រីងៀតអីទៅ ក៏ប៉ុន្តែយើងពុំអាចមានកម្លាំងដែលទទួល ដែលយើងរែកដីចំនួន៣ម៉ែត្រគូបបានទេ។

[១៤:១៣:០៣]

**ស៖** នេះលោក អ្វីដែលលោកលើកឡើងនេះ គឺក្នុងលក្ខខណ្ឌធម្មតាដែលចំពោះពលករដែលបំពេញការងារបានគ្រប់គ្រាន់។ ចុះចំពោះពលករដែលបំពេញការងារមិនគ្រប់គ្រាន់ ហើយទទួលទណ្ឌកម្មដូចដែលលោកបានលើកឡើងខាងដើមហ្នឹងថា នៅពេលហ្នឹងគេបង្អត់អាហារ។ តើការបង្អត់អាហារហ្នឹងរបៀបម៉េចដែរ? បានន័យថា អត់ទទួលបានទាំងអស់ហ្នឹងទៀតតែម្តង ឬយ៉ាងម៉េច?

**ឆ៖** នៅពេលហ្នឹងកងចល័តរបស់កងចល័តហ្នឹង គេបែងចែកជាបីក្រុម បែងចែកជាបីកង។ កងទី១ គឺកងពិសេស ដែលរែកបានពីបួនទៅប្រាំហ្នឹង គេឲ្យហូបបាយផ្សេង របបគេផ្សេង។ ពី២ម៉ែត្រគូប ទៅ៣ម៉ែត្រគូប គឺហូបផ្សេង ហើយអ្នកដែលគ្មានសមត្ថភាពដូចជា ងងឹតមាន់ ដូចជាខ្វាក់ វាភ្នែកមីញ៉ូប ឬក៏ជើងពិការ ជើងអី អាន់ុងគេកំណត់ផ្សេង។

**ស៖** លោកអាចឲ្យចម្លើយជាក់លាក់បានទេ ពាក្យថា “ផ្សេងៗពីគ្នា” ហ្នឹង ហូបបាយផ្សេងហ្នឹងគឺមានអ្វីខ្លះ? ហើយកងទី២ហ្នឹងទទួលបានអ្វីខ្លះ? កងទី៣ហ្នឹងទទួលបានអ្វីខ្លះ? លោកអាចផ្តល់ចម្លើយជាក់លាក់បានទេ?

**ឆ៖** បាទ កងទី១ ដែលរែកបានពីបីបួនម៉ែត្រគូបហ្នឹង ៤ម៉ែត្រគូបហ្នឹង របបអង្ករគេ គេបានពីរកំប៉ុងជាង ពីពីរកំប៉ុងទៅបីកំប៉ុង។ ហើយចាប់កងទី២ហ្នឹង គឺបានយ៉ាងច្រើនបំផុតពីរកំប៉ុង។ ហើយកងដែលក្រោមគេហ្នឹង ជួនកាលបានមួយថ្ងៃកន្លះកំប៉ុង ឬមួយថ្ងៃមួយកំប៉ុង។

[១៤:១៥:១១]

**ស៖** ប៉ុន្តែអ្វីដែលខ្ញុំសាកសួរលោកចុងក្រោយមុននេះបន្តិចហ្នឹង គឺពាក់ព័ន្ធនឹងអ្នកដែលទទួលទណ្ឌកម្ម បានន័យថាអ្នកដែលអត់លើក ដែលធ្វើមិនគ្រប់ផែនការ។ តើការកាត់របបអាហារហ្នឹង គេធ្វើឡើងដូចម្តេចដែរ? លោកយល់នឹងសំណួរខ្ញុំទេ?

**ឆ៖** បាទ សំណួរនេះសូមលោកបញ្ជាក់ម្តងទៀត។

**ស៖** ឃើញថាអ្នកធម្មតាទទួលបានរបបអាហារដូច្នេះហើយ។ ចុះចំពោះអ្នកដែលទទួលទណ្ឌកម្ម បានន័យថាអ្នកដែលអត់បានបំពេញតាមផែនការដាក់លាក់ ឧទាហរណ៍ពាម៉ែត្រគូបក្នុងមួយថ្ងៃដែលលោកបានលើកឡើងខាងដើមហ្នឹង តើការកាត់របបអាហារហ្នឹងដូចម្ដេច? បន្ថយអាហារ ឬក៏អត់ឲ្យបាយហូបតែម្ដង?

**ឆ៖** មានជួនកាល ក៏គេបង្អត់អាហារដែរ គេមិនឲ្យយើងហូបទេ នៅដំណាក់កាលហ្នឹង។

**ស៖** ចុះនៅក្នុងដំណាក់កាលសម្រុកការងារដែលលោកលើកឡើងខាងដើមហ្នឹង មានការផ្ដល់អាហារបំប៉នបន្ថែមទេ?

**ឆ៖** ក្រៅពីបបរមួយមុខហ្នឹង គឺគ្មានអាហារអ្វីណាមួយដែលយកមកបំប៉នទេ។

[១៤:១៦:៥៦]

**ស៖** ប្រហែលជាលោកស្ដាប់ច្រឡំនឹងសំណួរខ្ញុំ។ ខ្ញុំអត់សំដៅលើប្រភេទអាហារបំប៉នផ្សេងទៀតទេ គឺចង់និយាយថា ក្រៅពីអាហារទៀងពេលនេះ ឧទាហរណ៍អ្នកទទួលបាន -- ក្រុមទី២ អ្នកទទួលបានពីរកំប៉ុងហ្នឹង នៅពេលដែលសម្រុកធ្វើការងារខ្លាំង គាត់បានអាហារ គាត់បានទទួលរបបបន្ថែមផ្សេងទៀតទេ?

**ឆ៖** ពេលនោះ អង្គការកំណត់តែពីរកំប៉ុង គឺពីរកំប៉ុងគត់ គឺគ្មានអាហារណាដែលបន្ថែមទៀតទេ។

**ស៖** ពាក់ព័ន្ធនឹងអាហារនេះដែរ តើអាហារទាំងនោះមានអនាម័យគ្រប់គ្រាន់ទេ?

**ឆ៖** ពេលហ្នឹងអាហារដែលចម្អិនហើយ គឺគ្មានអនាម័យទេ គឺប្រកបដោយសត្វរុយ សត្វអីរោមរាល់តែពេល។

**ស៖** រុយៗច្រើនទេកាលៗសម័យហ្នឹង កាលពេលហ្នឹង?

**ឆ៖** បាទ នៅពេលហ្នឹងក៏មានឈឺច្រើន។ តែមួយចំនួនហ្នឹង ក៏គេយកទៅវៃចោល ដូចថាយើងឈឺសតិអារម្មណ៍ ការពិតគ្នាពិតជាឈឺមែន។

**ស៖** អត់ទេ ខ្ញុំសួរពីសត្វរុយ លោកលើកឡើងថា អាហារហ្នឹងមានរុយរោម។ តើៗរុយមានច្រើនទេកាលនុ៎ង?

**ឆ៖** ពេលហ្នឹងគឺរុយច្រើនណាស់ រុយដែលមករោមអាហារហ្នឹង។

**ស៖** បើរុយច្រើនម្ល៉ឹង តើកាលនោះអង្គការមានវិធានការសម្លាប់សត្វរុយ ឬក៏ការពារកុំឲ្យមាន

រុយយ៉ាងដូចម្ដេចទេ?

[១៤:១៩:៣៧]

**ឆ៖** ពេលនោះ អង្គការគ្មានផែនការណាមួយដែលទប់ទល់ជាមួយសត្វរុយទេ។

**ស៖** ដោយឡែកចំពោះទឹកវិញ តើនៅពេលនោះ លោកហូបទឹកអី? ហើយមានទឹកហូបគ្រប់គ្រាន់ទេ?

**ឆ៖** នៅក្នុងពេលហ្នឹងទឹក គឺមានឡានគេដឹកមកហើយ ក៏ប៉ុន្តែគេវាល់ជារបបសម្រាប់ឲ្យយើងហូប។

**ស៖** ហូបគ្រប់គ្រាន់ទេ?

**ឆ៖** បាទ បើពេលដែលហូបបាយ យើងអាចហូបគ្រប់គ្រាន់ ក៏ប៉ុន្តែពេលដែលយើងឈប់សម្រាកដូចជា ពេលចូលសម្រាកចូលអី គឺគ្មានទឹកហូបទេ។

**ស៖** ចុះទឹកហ្នឹងមានអនាម័យទេ?

**ឆ៖** ទឹកហ្នឹងគ្មានអនាម័យទេ ព្រោះទឹកដឹកពីត្រពាំងមក។

**ស៖** ដែលលោកសំដៅថា អត់អនាម័យហ្នឹង មានន័យថាដូចម្ដេច? បានន័យថា ទឹកហ្នឹងអត់ត្រូវបានដាំឲ្យឆ្អិន ឬក៏លោកមើលនឹងភ្នែកទៅឃើញថា ទឹកហ្នឹងមិនល្អ?

[១៤:២១:២៤]

**ឆ៖** នៅពេលដែលគេចែកទឹកតាមកង យើងមើលទៅទឹកហ្នឹងគឺកករល់ ហើយជួនកាលដោយទាំងសារាយ ដោយអីដែលនៅក្នុងទឹកមកជាមួយដែរ។ ទើបខ្ញុំបាទថា ទឹកហ្នឹងគ្មានអនាម័យ។

**ស៖** ចុះនៅសម័យនោះ -- អំមិញខ្ញុំស្ដាប់បានលោកលើកមកខ្លះៗហើយ ថាមានអ្នកឈឺ។ ឈឺច្រើនទេ កាលសម័យនុ៎ង?

**ឆ៖** បាទ ពេលហ្នឹងក៏មានឈឺច្រើនដែរ ហើយអ្នកឈឺ ខ្លះក៏គេពិនិត្យមើលជាក់ស្ដែង គេបញ្ជូនទៅមន្ទីរពេទ្យ។

**ស៖** បញ្ជូនទៅមន្ទីរពេទ្យ តើមន្ទីរពេទ្យហ្នឹងនៅកន្លែងណា? ហើយតើមានពេទ្យ មានមន្ទីរពេទ្យនៅកន្លែងការដ្ឋានហ្នឹងដែរឬទេ?

**ឆ៖** នៅមន្ទីរពេទ្យការដ្ឋានគឺមាន ក្នុងមួយកងគឺមានម្នាក់។ ហើយបើសិនជាឈឺពិតប្រាកដមានមន្ទីរពេទ្យដូចជា នៅក្នុងវត្តត្រពាំងថ្ម។

**ស៖** ពេទ្យហ្នឹង គាត់មានជំនាញវិជ្ជាជីវៈពិតប្រាកដទេ ដែលតាមលោកពិនិត្យមើលទៅ?

**ឆ៖** ពេទ្យជំនាន់ហ្នឹង គឺគ្មានអីជាក់លាក់ទេ ទោះបីជាឈឺប្រាប់ថា ឈឺក្បាលក៏គេឲ្យអាថ្នាំហ្នឹង ដូចអាចម៍ទន្សាយ ឈឺពោះគេក៏ឲ្យថ្នាំហ្នឹង ឈឺអីក៏គេឲ្យថ្នាំហ្នឹងដែរ។

[១៤:២៣:២៤]

**ស៖** បើតាមលោកសង្កេតមើលទៅអ្នកដែលចូល -- អ្នកដែលត្រូវបានគ្រូពេទ្យនៅការដ្ឋានព្យាបាល ក៏ដូចជាអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរពេទ្យហ្នឹង ត្រូវបានព្យាបាលឲ្យជាសះស្បើយមកវិញទេ?

**ឆ៖** មានមួយចំនួនតូចដែលជាសះស្បើយ ហើយមានចំនួនធំក៏ស្លាប់នៅក្នុងមន្ទីរពេទ្យ។

**លោក ស្រ៊ា រតនៈ៖**

សូមអរគុណចំពោះលោកសាក្សី ដែលបានឆ្លើយតបនូវសំណួរទាំងអម្បាលម៉ានរបស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរ សូមជូនវេទិកាទៅសហការីរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពភាគីទាំងអស់ សូមគោរពសាធារណជន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ាំងសង់ ដេស្នាឯល។ ខ្ញុំនឹងសួរសំណួរតាងឲ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំនឹងសួរសំណួរតាមលំដាប់កាលប្បវត្តិ។ យើងចេញពីទំនប់ត្រពាំងថ្ម<បន្តិចសិន> ហើយចូលទៅនិយាយអំពីរឿងរ៉ាវមុន<លោកទៅដល់ទីនោះ>។ ខ្ញុំចង់ដឹងថា មុនខែមេសា ឆ្នាំ ១៩៧៥ តើលោកធ្វើជាទាហាន លន់ នល់ មែនទេ? ហើយបើលោកធ្វើជាទាហានហ្នឹង ធ្វើពីពេលណាដល់ពេលណា? ហើយមានឋានន្តរសក្តិជាអ្វីដែរ?

**លោក ឈុំ សេង៖**

**ឆ៖** ខ្ញុំអត់ដឹងនិយាយអី ខ្ញុំស្តាប់អត់បាន។

[១៤:២៥:៤០]

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ។ តើមុនខែមេសា ឆ្នាំ១៩៧៥ គឺចន្លោះពីឆ្នាំ៧២ ដល់ឆ្នាំ៧៤នោះ លោកធ្លាប់ធ្វើជាទាហាន លន់ នល់ ដើម្បីវាយប្រយុទ្ធគ្នាជាមួយនឹងទាហានខ្មែរក្រហមទេ?

**ឆ៖** ពេលហ្នឹង ខ្ញុំអត់ចេះភាសាបរទេស ខ្ញុំស្ដាប់មិនបាន មិនគាត់និយាយរឿងអី។

**ប្រធានអង្គជំនុំ៖**

បញ្ហាឧបករណ៍ស្ដាប់សំឡេងទេដឹង អស់ថ្ម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** មិនអីទេលោកសាក្សី ខ្ញុំនឹងព្យាយាមសួរឲ្យបានច្បាស់ ដើម្បីឲ្យលោកទទួលបានការបកប្រែ។ ខ្ញុំចង់ដឹងថា មុនខែមេសា ឆ្នាំ៧៥ គឺមុនពេលខ្មែរក្រហមចូលកាន់អំណាច តើលោកធ្លាប់ធ្វើជាទាហានឲ្យរដ្ឋាភិបាល លន់ នល់ ទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ នៅពេលដែលនៅក្នុងរបប លន់ នល់ គឺខ្ញុំបាទធ្វើជាទាហានរបស់ លន់ នល់។

**ស៖** តើលោកមានស័ក្ដិទេ ឬក៏លោកគ្រាន់តែជាកូនទាហានធម្មតា?

**ឆ៖** ខ្ញុំបាទពុំមានស័ក្ដិទេ គឺជាកូនទាហានធម្មតា។

[១៤:២៧:៣៣]

**ស៖** ក្រោយពីខ្មែរក្រហមចូលកាន់អំណាច គឺក្រោយ <ថ្ងៃទី១៧> ខែមេសា ឆ្នាំ៧៥ ពេលវាយយកភ្នំពេញបាន តើលោកដឹងថាមានអ្វីកើតឡើងចំពោះអ្នកដែលត្រូវបានគេរកឃើញថាជាអតីតទាហាន លន់ នល់? តើខ្មែរក្រហមធ្វើយ៉ាងម៉េចចំពោះទាហាន និងនាយទាហាន លន់ នល់ នៅក្នុងស្រុករបស់លោក គឺស្រុកភ្នំស្រុកនោះ?

**ឆ៖** បាទ ពេលដែលកងទ័ពខ្មែរក្រហមចូលរំដោះបាន គឺកងទ័ពរបស់ខ្មែរក្រហម គឺដាច់ខាតត្រូវតែសម្លាប់ទាហាន លន់ នល់ ឲ្យអស់។

**ស៖** តើខ្មែរក្រហមធ្វើយ៉ាងម៉េចទើបអាចកំណត់បានថាអ្នកណាខ្លះជាទាហាន លន់ នល់ នោះ?

**ឆ៖** ពេលនោះ ការដែលរៀបចំចាត់តាំងឈ្លប គឺអ្នកភូមិហ្នឹងទេ ជាអ្នកធ្វើឈ្លប។ ដូច្នេះប្រវត្តិរបស់យើង គឺមិនអាចលាក់ជិតទេ។

**ស៖** តើគេមានឲ្យប្រជាជនធ្វើប្រវត្តិរូបទេ?

**ឆ៖** ពេលហ្នឹងគេឲ្យធ្វើដែរ ក៏ប៉ុន្តែខ្លះដែលស្មោះត្រង់នឹងអង្គការ ក៏សរសេរប្រវត្តិត្រង់។ អ្នកខ្លះ

ក៏គេសរសេរប្រវត្តិដោយមិនត្រង់ ហើយគេក៏រត់គេចទៅមួយចំនួនអ៊ីចឹង។

**ស៖** តើលោកដឹងថា គេនាំទាហាន និងនាយទាហាន លន់ នល់ ហ្នឹងយកទៅសម្លាប់ចោលនៅកន្លែងណាទេ?

**ឆ៖** ពេលហ្នឹងដូចជាសម្លាប់ ភូមិខ្ញុំនៅភ្នំលៀប គឺគេចាប់យកទៅវាយតែក្បែរៗជើងភ្នំហ្នឹងទេ។ អ្នកណារត់រួច ក៏រួច អ្នកណាដែលរត់មិនរួច គេចាប់យកទៅវាយចោល។

[១៤:៣០:០៧]

**ស៖** ចុះខ្លួនលោកផ្ទាល់មានប៊ិះត្រូវបានគេចាប់ខ្លួនទេ? ហើយលោកធ្វើយ៉ាងម៉េចបានគេចផុត?

**ឆ៖** ពេលហ្នឹងខ្មែរក្រហមជម្លៀសពីភ្នំលៀបទៅភ្នំកំបោរ ហើយគេក្តាប់បានប្រវត្តិរូបរបស់ខ្ញុំ ខ្ញុំក៏រត់ពីភូមិកំបោរ មកចូលជាកងចល័ត។

**ស៖** តើគ្រួសាររបស់លោកមានការព្រួបារម្ភទេ ព្រោះថាលោកនេះជាទាហាន លន់ នល់ នោះ?

**ឆ៖** ពេលហ្នឹងឪពុកខ្ញុំក៏បានទៅសុំកងឈ្លបដែរ តែកងឈ្លបគេថា មិនអាចជួយបាន ព្រោះទាហានអាយ៉ង។ ពេលនោះឪពុកខ្ញុំក៏បានប្រាប់ខ្ញុំថា "ពុកជួយមិនរួចទេ កូនឯងត្រូវតែគេចខ្លួន" ខ្ញុំក៏គេចខ្លួនចូលកងចល័តទៅ។

**ស៖** <ខ្ញុំសូមរំឭកការចងចាំរបស់លោកនូវអ្វីដែល>លោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានមកសួរលោកកាលពីឆ្នាំ២០១១ គឺឯកសារ <E3/901.10> គឺនៅទំព័រ៣ ជាភាសាបារាំង, ៣ ជាភាសាអង់គ្លេស និងទំព័រ៤ ជាភាសាខ្មែរ។ គឺ វ៉ាន់ថាន់ ដារ៉ា បានសួរលោកថា៖ "តើខ្មែរក្រហមមានស្វែងរកសមាជិកគ្រួសាររបស់លោក ឪពុកម្តាយលោកទេ ពីព្រោះថា លោកត្រូវបានគេស្គាល់ថាជាទាហាន លន់ នល់ នោះ?" ពេលនោះលោកបានឆ្លើយដូចតទៅ៖ "គេដឹងពីរឿងខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា នៅសម័យនោះកម្មាភិបាលភូមភាគនិរតីមិនទាន់មកដល់ទេ គេមានកម្រិតនៃការអត់ឱនដែលធ្វើឱ្យយើងបានរួចខ្លួន។ ឪពុកម្តាយខ្ញុំមិនមានការគ្រោះថ្នាក់អ្វីទេ។" សូមបញ្ចប់ការដកស្រង់។ លោកបាននិយាយអំពីកម្រិតនៃការអត់ឱន ឬក៏អនុគ្រោះពីសំណាក់កម្មាភិបាលភូមិភាគពាយ័ព្យមុនពេលភូមិភាគនិរតីមកដល់ តើលោកអាចបញ្ជាក់បានទេថាកម្រិត អត់ឱន ឬក៏អនុគ្រោះហ្នឹងមានន័យយ៉ាងម៉េចដែរ?

[១៤:៣២:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ការតាំងសំណួរដោយសហព្រះរាជអាជ្ញានេះ គឺវាផ្ទុយទាំងស្រុងទៅនឹងសេចក្ដីសម្រេចនៅក្នុងឯកសារ <E315> នៅក្នុងកថាខណ្ឌ<១៥(គ)>ស្ដីអំពី<ការប្រព្រឹត្តលើ>អតីតមន្ត្រីរដ្ឋការស៊ីវិលនៅស្រុកត្រាំកក់, <ទំនប់១មករា,> ក្រាំងតាចាន់ និងស-២១។ ខ្ញុំបានជំទាស់ពីរបីដងរួចមកហើយ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ វាស្ថិតនៅក្រៅវិសាលភាពនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សំណួរចុងក្រោយអម្បាញ់មិញនេះ និយាយអំពីភាពខុសគ្នារវាងកម្មាភិបាលពាយ័ព្យ និងកម្មាភិបាលនិរតី។ នេះគឺជាសំណួរដែលស្ថិតនៅក្នុងក្របខ័ណ្ឌ នៃការបោសសម្អាតដែលបានប្រព្រឹត្តទៅនៅទីនោះ ហើយដែលខ្ញុំនឹងនិយាយនៅពេលអម្បាញ់មិញនេះទៀត។ ដូច្នេះ ខ្ញុំចង់ដឹងថា តើនៅពេលនោះហេតុអ្វីបានជាសាក្សីគាត់និយាយអំពី "កម្រិតនៃការអត់ឱន" ដោយសារតែនៅពេលនោះកម្មាភិបាលភូមិភាគនិរតីមិនទាន់ចូលមកដល់នៅឡើយទេ។ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាឲ្យខ្ញុំសួរសំណួរនេះ។

[១៤:៣៤:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៥:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី លោក វ៉ិចទ័រ កូប៉េ ចំពោះសំណួរនេះ។ ហើយសំណួរនេះ គឺវាមានការពាក់ព័ន្ធទៅនឹងអង្គហេតុនៃការបោសសម្អាត ហើយអង្គជំនុំជម្រះក៏ត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សី ចំពោះសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិចំពោះសាក្សីនូវសំណួរចុងក្រោយអម្បាញ់មិញនេះដែរ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលៈ**

**ស៖** លោកសាក្សីអម្បាញ់មិញនេះ ខ្ញុំសួរលោកថា តើលោកចង់បានន័យថាម៉េច នៅពេលដែលលោកនិយាយថា <“កម្រិត>អត់ឱន” ដោយសារតែពេលនោះ ពួកនិរតីមិនទាន់មកដល់នៅឡើយ?

**លោក ឈុំ សេង៖**

**ឆ៖** ពេលដំណាក់កាលហ្នឹង គឺដូចជាកងឈ្លបហ្នឹង វាត្រូវជាបងប្អូនជាមួយទាហានហ្នឹងដែរ។ ហ្នឹងទើបវាមានការអត់ឱនខ្លះ។

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថា លោកបានរត់គេច ហើយលោកបានទៅចូលទៅក្នុងកងចល័តតំបន់៥។ នៅក្នុងកងចល័តនៃតំបន់៥នេះ តើអ្នកណាជាមេរបស់លោកនៅក្នុងភូមិភាគពាយ័ព្យនោះ?

**ឆ៖** បាទ ខ្ញុំស្គាល់តែប្រធានធំដែលគ្រប់គ្រងក្នុងកងចល័តតំបន់ គឺឈ្មោះ តាវ៉ាល់។

**ស៖** សូមអរគុណ។ <នៅពីក្រោម តាវ៉ាល់ តើ>អ្នកណាជាប្រធានវរសេនាតូចដែលលោកធ្វើការ<>នោះ គឺនៅពេលដែលលោកធ្វើការនៅសាងសង់ទំនប់ មុនពេលទៅដល់ត្រពាំងថ្ម ហើយនិងក្រោយពេលដែលលោកទៅដល់កងវ៉ានោះ?

**ឆ៖** អ្នកគ្រប់គ្រងខ្ញុំបាទផ្ទាល់ ដែលជាប្រធានវរសេនាតូច គឺឈ្មោះ តាខូវ និង តាវន។

**ស៖** សំណួរចុងក្រោយ មុនពេលឈប់សម្រាកលោកប្រធាន។ អម្បាញ់មិញនេះ លោកនិយាយថា លោកជាប្រធានកងធំ។ អ៊ីចឹង តាខូវ ហើយនិង តាវន ដែលតែងតាំងលោកជាប្រធានកងធំហ្នឹង ខ្ញុំចង់ដឹងថា តើមានមនុស្សប៉ុន្មាននាក់ដែរ ដែលធ្វើការនៅក្នុងកងធំ ឬក៏កងអនុសេនាធំនេះ?

**ឆ៖** បាទ ចំពោះកងធំ គឺគ្រប់គ្រងកម្លាំង១០០នាក់ ហើយចំពោះវរសេនាតូចហ្នឹងគឺគ្រប់គ្រងកម្លាំង៣០០នាក់។ ដូចជា តាខូវ និង តាវន គ្រប់គ្រងកម្លាំងបីនាក់ ខ្ញុំគ្រប់គ្រង១០០នាក់។

[១៤:៣៨:៣៣]

**ស៖** ចំពោះខ្ញុំ ខ្ញុំឮពាក្យ “កងតូច” ជាភាសាបារាំងនោះ។ អ៊ីចឹង តើពាក្យថា “វរសេនាតូច” ហ្នឹង យើងអាចប្រើបានដែរ បើយើងនិយាយអំពីកងចល័តនោះ ដែលមានសមាជិកប្រហែល៥០០នាក់នោះ -- ៣០០នាក់ (សូមទោស)?

**ឆ៖** ពេលនោះ គឺអង្គការខាងលើ គេរៀបចំអ៊ីចឹងឯង។ ខ្ញុំចំពោះម៉េចៗ ក៏ខ្ញុំអត់បានដឹងដល់ដែរ។

**ស៖** អ៊ីចឹង នៅពីលើកងធំដែលលោកដឹកនាំ ដែលមានគ្នា១០០នាក់ហ្នឹង តើគេមានលំដាប់ថ្នាក់ដែលនៅពីលើហ្នឹង ដែលថាមានគ្នាច្រើនជាងហ្នឹងទេ? ខ្ញុំចង់សំដៅថា តើនៅពីលើកងធំហ្នឹង មានឋានៈអីផ្សេងទៀត?

**ឆ៖** បាទ ចាប់ពីថ្នាក់វរសេនាតូចទៅ ឡើងទៅគឺមាន តាវ៉ាល់ ជាអ្នកគ្រប់គ្រងផ្ទាល់ កម្លាំងទាំងប៉ុន្មានទាំងអស់ក្នុងចល័តតំបន់៥។

**ប្រធានអង្គជំនុំ៖**

បានហើយ។ អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មានបញ្ហាអីលោក សូមអញ្ជើញ!

**លោក អាកទូរ វ៉ែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមការបញ្ជាក់ពីអង្គជំនុំជម្រះ ព្រោះថា ខ្ញុំមិនយល់អំពីអ្វីដែលមានរឿងកើតឡើងមុនពេលសម្រាកអម្បាញ់មិញនេះ។ ខ្ញុំស្តាប់លោកសហព្រះរាជអាជ្ញាចោទសំណួរទាក់ទងទៅនឹងការប្រព្រឹត្តទៅលើអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ហើយគាត់ព្យាយាមបញ្ជាក់មូលហេតុអំពីសំណួររបស់គាត់ ទាក់ទងទៅនឹងការបោសសម្អាត ក៏ប៉ុន្តែសំណួរទាំងអស់នេះ វា

ពាក់ព័ន្ធទៅនឹងទីតាំងមួយដែលនៅក្រៅវិសាលភាពនៃការជំនុំជម្រះសេចក្ដីយើងនេះ។ ខ្ញុំសូមអានកថាខណ្ឌមួយនៃសេចក្ដីសម្រេច E301/9/1 ចុះថ្ងៃទី០៤ មេសា <ឆ្នាំ២០១៤>។ អ៊ីចឹងខ្ញុំដូចឆ្ងល់<។ មានបីឃ្លាដែលខ្ញុំដកស្រង់៖> "អង្គជំនុំជម្រះសាលាដំបូងបញ្ចូលនៅក្នុងវិសាលភាពសំណុំរឿង ០០២/០២ នេះ ទាក់ទងនឹងគោលនយោបាយ ទាក់ទងទៅនឹងមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ។ <ប៉ុន្តែសម្រាប់>តែ<ការ>លើក<ទាក់ទង>ទៅនឹងការអនុវត្តគោលនយោបាយទាំងអស់នេះនៅ<សហករណ៍>ត្រាំកក់ នៅទំនប់១មករា នៅមន្ទីរសន្តិសុខស-២១ ហើយនិងក្រាំងតាចាន់តែប៉ុណ្ណោះទេ"។ នេះជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ អ៊ីចឹងខ្ញុំដូចជាមានអារម្មណ៍ថា នៅពេលដែលស្ដាប់សេចក្ដីសម្រេចអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះអនុញ្ញាតឲ្យព្រះរាជអាជ្ញា និយាយអំពីការប្រព្រឹត្តទៅលើអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ នៅនឹងការដ្ឋានដែលយើងកំពុងតែនិយាយនេះ។ ក៏ប៉ុន្តែសេចក្ដីសម្រេចមុនរបស់អង្គជំនុំជម្រះនោះ គឺកម្រិតមកត្រឹមតែត្រាំកក់ ទំនប់១មករា មន្ទីរស-២១ ហើយនិងក្រាំងតាចាន់តែប៉ុណ្ណឹងទេ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមឲ្យជួយបំភ្លឺ ខ្ញុំដូចជាមិនយល់សេចក្ដីសម្រេចអម្បាញ់មិញនេះសោះ ព្រោះថាខ្ញុំឃើញថាមើលទៅបើកាលណាសម្រេចបែបហ្នឹង ហាក់ដូចជាពង្រីកវិសាលភាពនៃ<> ជំនុំជម្រះសេចក្ដីនេះហើយលោកប្រធាន។ អ៊ីចឹងសូមឲ្យលោកប្រធានជួយបំភ្លឺ។

[១៥:០១:៣១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ដើម្បីឆ្លើយឲ្យខ្លី គឺថាមានពីរចំណុច។ គឺថាមានគោលនយោបាយ ហើយនិងការអនុវត្តគោលនយោបាយ។ យើងតែងតែនិយាយថា ដើម្បីបង្ហាញថាមានអត្ថិភាពនៃគោលនយោបាយមួយ គឺមានមធ្យោបាយពីរ គឺថាបង្ហាញពីខាងលើ ដោយថាបញ្ជាចុះមកក្រោម តើមានការបញ្ជាអ្វីខ្លះ? ឬក៏ពីខាងក្រោម<ទៅលើ តើ>គេធ្វើអ្វីខ្លះនៅថ្នាក់មូលដ្ឋាន? ក៏ប៉ុន្តែ<នេះមិនមែនជារឿងសំខាន់នោះទេ> សំណួរអម្បាញ់មិញដែល<នាំទៅដល់>ការជំទាស់នេះ គឺជាសំណួរដែលពាក់ព័ន្ធទៅនឹងភាពខុសគ្នារវាងកម្មាភិបាលពាយ័ព្យ ហើយនិង<កម្មាភិបាល>និរតី បន្ទាប់ពីពួកនិរតីចូលមកដល់ភូមិភាគពាយ័ព្យ <ក្នុងបរិបទនៃការបោសសម្អាត>។ ខ្ញុំគិតថា <មិនចាំបាច់>ពិភាក្សាគ្នាវែងឆ្ងាយអ្វីនោះទេ លោកប្រធាន។

**លោក អាកទ្ធូរ វែកគែន៖**

<ទោះបីវាមិនមែនជាការពិភាក្សាគ្នាធំដុំមែន តែ>ការពិភាក្សា<នេះក៏>សំខាន់<ដែរ> ពីព្រោះ

ថា តុលាការបានចេញសេចក្តីសម្រេច<រួចទៅហើយ>នៅក្នុង វគ្គទី១<នៃការជំនុំជម្រះ> ថាមាន <គោលនយោបាយ>ពេញមួយរបបតែម្តង។ ដោយសារតែអ៊ីចឹងហើយ បានតុលាការកំពូលនោះ បដិសេធ។ អ៊ីចឹង ខ្ញុំដូចជាមិនយល់ថា ហេតុអីក៏<ត្រូវ>និយាយអំពីចំណុច<>នេះ<ទៀត> ពីព្រោះថា <មានការសម្រេចរួចហើយស្តីពី>ការកំណត់វិសាលភាព ហើយនិងពាក់ព័ន្ធនឹងគោលនយោបាយនេះ <>។

[១៥:០៣:០៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមនិយាយដោយខ្លីទេ ខ្ញុំសូមអភ័យទោសចំពោះការិយាល័យ សហព្រះរាជអាជ្ញាដែលបាន<ប្រើពេលវេលារបស់លោក>។ បើតាមឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ តុលាការ គឺឯកសារ 301/9/1.1 ដែលនិយាយអំពីផ្នែក<>នៃ<ដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះ ប្រើក្នុងសំណុំរឿង០០២ ដែលមាននៅក្នុងសាលក្រម។>។ <អង្គជំនុំជម្រះត្រូវសម្រេចអំពី>អត្ថិភាពនៃ គោលនយោបាយថ្នាក់ជាតិនេះជាដើមនេះ ខ្ញុំសូមយោងទៅកថាខណ្ឌ១៧៨ ទៅ២០៤ ដែលអង្គជំនុំ ជម្រះសាលាដំបូងបានទទួលបណ្តឹង។ <ជាបឋម> គឺនិយាយអំពីអត្ថិភាពគោលនយោបាយនៅថ្នាក់ ជាតិ ហើយបន្ទាប់មកទៀតហ្នឹង ការប្រព្រឹត្តឧក្រិដ្ឋដែលចេញពីការអនុវត្តនៃគោលនយោបាយទាំងអស់ នេះ ហើយឧក្រិដ្ឋកម្មដែលកើតមាននៅទីតាំងឧក្រិដ្ឋមួយចំនួន<ដែលមានកំណត់>។ ហើយទាក់ទងទៅ នឹងអតីតមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរនោះ គឺទាក់ទងទៅក្រាំងតាចាន់ <ត្រាំកក់> និងទំនប់១មករា អីជាដើម។ <ខ្ញុំមិនចាំលម្អិតទេ ដោយសារតែខ្ញុំមិនមានឯកសារនៅក្នុងដៃ។> អ៊ីចឹងខ្ញុំ<យោងទៅលើ គោលការណ៍ដែលអង្គជំនុំជម្រះសម្រេចលើអត្ថិភាពគោលនយោបាយ ហើយខ្ញុំ>ឃើញថា<យើងហាក់ ដូចជាបង្កើតការជំនុំជម្រះថ្មីអ៊ីចឹង។> ឥឡូវនេះ នៅពេលដែលកំពុងតែមាន<បណ្តឹង>ឧទ្ធរណ៍ហើយ គឺ ថាយើងចាប់ផ្តើមពីចំណុចសូន្យមកវិញ មានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅកន្លែងមួយចំនួន។ អ៊ីចឹងត្រូវតែ គោរពតាមឧបសម្ព័ន្ធ អ្វីដែលមានចែងនៅក្នុងឧបសម្ព័ន្ធតែប៉ុណ្ណឹងទេ។ អ៊ីចឹងចំពោះយើង យើងគិតថា យើងអាចចោទសំណួរជាទូទៅ បាន ទាក់ទងទៅអត្ថិភាពនៃគោលនយោបាយទាំងប្រាំនោះ ពីព្រោះថា អង្គជំនុំជម្រះត្រូវតែធ្វើសេចក្តីសម្រេចទៅលើចំណុចទាំងអស់នេះ នៅក្នុងសំណុំរឿង០០២/០២។

[១៥:០៥:១៣]

**លោក អាកទួរ វែកគែន៖**

<បើតាមខ្ញុំយល់> បើសិនជានៅក្នុងសំណុំរឿង០០២/០២នេះ ហើយមិនមានចេញសេចក្ដីសម្រេចពីតុលាការកំពូលមកនោះ យើងឈប់ធ្វើអ្វីទៀតកើតហើយ។ ខ្ញុំមិនដឹងថា បើការជម្រះសេចក្ដីនេះយ៉ាងម៉េចទេ ដូចជាមានផ្ទត់បត់បែនច្រើនថ្នាក់ច្រើនលំដាប់នោះ ខ្ញុំអត់ច្បាស់ទាល់តែសោះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមិនចង់តទល់គ្នារវាងមេធាវី<តែពីរនាក់នោះ>ទេ ក៏ប៉ុន្តែនៅពេលណាមួយបើសិនជាមានចេញសាលដីកា<ពីតុលាការកំពូល>មក ដោយនឹងមានផលប៉ះពាល់មកលើសំណុំរឿងយើងនេះហើយ។ អ៊ីចឹងអានេះជារឿងច្បាស់ហើយ អ្នកណាក៏ដឹងដែរ។ អ៊ីចឹងតុលាការកំពូលនឹងពិនិត្យ ពិចារណាលើ<អត្ថិភាព>គោលនយោបាយ និង -- ឬក៏ការអនុវត្តគោលនយោបាយមួយចំនួន ហើយជាពិសេសទាក់ទងអ្វីដែលកើតឡើង<រហូតដល់ខែធ្នូ> នៅឆ្នាំ១៩៧៧ អីហ្នឹងជាដើម។

[១៥:០៦:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៦:៥៤]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយមេធាវីការពារក្ដីលោក ខៀវ សំផន លើបញ្ហាអម្បាញ់មិញនេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះមិនចង់ធ្វើការអត្ថាធិប្បាយវែងឆ្ងាយទាក់ទងទៅនឹងការកត់សម្គាល់របស់មេធាវី<ការពារក្ដីនោះ>ទេ។<>អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចហើយទាក់ទងទៅនឹងការជំទាស់របស់មេធាវី វែកគែន ហើយនិងមេធាវីការពារក្ដីជាទូទៅ។ អ៊ីចឹង សូមឲ្យអានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី ហើយនៅក្នុងនោះមានការពន្យល់នោះ វាក្បោះក្បាយលម្អិតអស់ហើយ សូមឲ្យអានសេចក្ដីសម្រេចហ្នឹងឡើងវិញចុះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវលោកសាក្សីខ្ញុំសូមបន្តសំណួរទៀត។ លោកនិយាយអំពីកងធំរបស់លោកដែលមានមនុស្ស១០០នាក់។ អ៊ីចឹងខ្ញុំសួរថា ក្មេងៗដែលជាសមាជិកនៃកង១០០ហ្នឹង មានអាយុពីប៉ុន្មានទៅប៉ុន្មានដែរ?

[១៥:០៨:២៧]

**លោក ឈុំ សេង៖**

**ឆ៖** ពេលនោះ គាត់ទាំងអស់គ្នានេះ គឺចាប់ពីអាយុ១៨ ដល់ទៅ២០, ៣០លើសទៅហើយ។

**ស៖** លោកនិយាយថាលោកនៅ<កងវរសេនាតូចទី១>ហើយទទួលបន្ទុកខាងធ្វើស្ពានទី១<នៅទំនប់ត្រពាំងថ្ម>។ តើលោករាយការណ៍ទៅប្រធានកងវរៈហ្នឹង ដែលឈ្មោះថា ខូវ ហ្នឹងតាមរបៀបណាដែរ យ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ នៅពេលនោះ គឺខ្ញុំបាទ ពុំចេះអក្សរបានច្បាស់ទេ គឺរាយការណ៍ដោយមាត់។ ជួបគាត់ផ្ទាល់ រាយការណ៍ផ្ទាល់។

**ស៖** តើលោកទទួលសេចក្ដីណែនាំ<អ្វីខ្លះ>ពីប្រធានកងវរសេនាតូចហ្នឹង<>? ហើយតើមានការណែនាំទាក់ទងនឹងវិន័យ និងការងារ <>ឬក៏គោលនយោបាយអីទេ? <>

**ឆ៖** ពេលនុ៎ង គឺប្រធានវរសេនាតូចកំណត់ថាឲ្យរែកដីឲ្យអីប៉ុណ្ណឹងទេ គ្មានបទបញ្ជាណាវែងឆ្ងាយតទៅទៀតទេ។

**ស៖** បើតាមលោកដឹងនោះ តាខូវ ហើយនិង តាវន នោះថាមេកងវរសេនាតូច ហើយនិងអនុប្រធានហ្នឹង តើអ្នកទាំងពីរនាក់ហ្នឹង គាត់រាយការណ៍ទៅអ្នកណាដែរ?

**ឆ៖** បាទ ពេលនុ៎ងគឺគាត់រាយការណ៍ទៅលើទៀត ក៏ប៉ុន្តែខ្ញុំពុំអាចដឹងច្បាស់ថារាយការណ៍ឲ្យអ្នកណាទេ។

**ស៖** តើរវាង តាវ៉ាល់ ហើយនិងកងវរសេនាតូចហ្នឹង មានថ្នាក់អីមួយទៀតទេនៅចន្លោះពីរហ្នឹង ឬក៏គេធ្វើការរាយការណ៍ទៅ តាវ៉ាល់ ដោយផ្ទាល់តែម្ដង?

[១៥:១១:០៦]

**ឆ៖** ខ្ញុំបានដឹងត្រឹមតែថ្នាក់កងធំ រាយការណ៍វរសេនាតូច ហើយវរសេនាតូចរាយការណ៍ឡើង

ទៅលើទៀត គឺខ្ញុំពុំបានដឹងទេ។

**ស៖** ខ្ញុំគិតថា មានពាក្យ “កង<វរសេនាតូច>” រាយការណ៍ទៅ<កងអនុសេនាធំ>។ មើលទៅប្រហែលជាមានបញ្ហាបកប្រែ។ <តាមការពន្យល់របស់លោក គឺកងអនុសេនាធំរាយការណ៍ជូនកងវរសេនាតូច។> នៅក្នុងកំណត់ស្តាប់ចម្លើយលោកនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា នៅក្នុងកងធំរបស់លោកនុ៎ងមានថ្នាក់ច្រើន គឺថាមានកងតូចៗបីដែលមានសមាជិក៣០នាក់ក្នុងមួយកងតូច ហើយនិងមានក្រុមដែលមានសមាជិកតែ១០នាក់ទេ ហើយមានអនុក្រុមទៀតដែលមានសមាជិកតែបីនាក់ទេ។ លោកបានរៀបរាប់អ៊ីចឹងជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកពិតជាបាននិយាយអ៊ីចឹងមែន ឬក៏យ៉ាងណា?

**ឆ៖** បាទ នៅពេលហ្នឹងគឺអង្គការរៀបចំលម្អិតក្នុងមួយក្រុម គឺមានបីពួក។ ក្នុងមួយពួកមានបីនាក់។ ហើយក្នុងមួយកង ក្នុងបីកងតូចគឺមានមួយកងធំ។ ក្នុងបីកងធំគឺមានមួយវរសេនាតូច។

**ស៖** តើលោកទទួលខុសត្រូវចំពោះការគោរពវិន័យរបស់អ្នកធ្វើការនៅក្នុងកងធំរបស់លោកដែរឬទេ?

**ឆ៖** បាទ រឿងហ្នឹងគឺត្រូវតែគោរព។ បើយើងមិនគោរពតាមការចាត់តាំងរបស់អង្គការទេ យើងក៏មានបញ្ហាដែរ ត្រូវទទួលខុសត្រូវចំពោះមុខអង្គការ។

[១៥:១៣:៣២]

**ស៖** តើលោកទទួលបន្ទុកក្នុងការរាយការណ៍ទាក់ទងនឹងវិន័យ ហើយនិងសន្តិសុខ ឬក៏ការកំណត់អត្តសញ្ញាណខ្មាំងនៅក្នុងកងធំរបស់លោកដែរឬទេ?

**ឆ៖** បាទ នៅពេលហ្នឹង គឺអង្គការឲ្យយើងតាមដានក្នុងមួយថ្ងៃឲ្យបានម្នាក់ ហើយចំពោះនោះអង្គការក៏បានចាត់តាំងកម្លាំងពិសេសឲ្យតាមដានជាបន្តបន្ទាប់ដែរ។ មួយថ្ងៃគឺឲ្យបានម្នាក់ៗ។

**ស៖** ខ្ញុំនឹងត្រឡប់ចូលមកនិយាយចំណុចទាំងពីរនេះបន្តិចទៀត។ តើនៅក្នុងកង<ចល័ត>តំបន់៥នោះ មានកម្មាភិបាលមកធ្វើការនៅទំនប់<ត្រពាំងថ្ម>ហ្នឹងដែលជាប្រជាជន<ថ្មី>ដែរឬទេ<>?

**ឆ៖** បាទ កម្មាភិបាលចាស់ៗដែលគេហៅដូចជា យើងតំបន់ដែលរំដោះ១៧មេសាហ្នឹង គឺគេហៅកម្មាភិបាលចាស់។ ដូច្នេះ គេឲ្យយើងធ្វើជាប្រធាន ឬក៏ប្រធានក្រុម ប្រធានកង។

**ស៖** បើតាមលោកចាំនោះ តើប្រធានស្រុកនៅតំបន់៥<ក្នុងភូមិភាគពាយ័ព្យ>មានឈ្មោះអ្វីខ្លះដែលបានបញ្ជូនអ្នកធ្វើការពីសហករណ៍នានាទៅការដ្ឋានទំនប់ត្រពាំងថ្មនោះ? លោកមានចាំឈ្មោះ

ចៅហ្វាយស្រុកទាំងអស់នុ៎ងទេ នៅក្នុងតំបន់៥ហ្នឹង?

**ឆ៖** បាទ នៅពេលហ្នឹង ខ្ញុំចាំបានថា នៅក្នុងស្រុកភ្នំស្រុក ថ្នាក់ស្រុកគឺឈ្មោះ តាហាត់ ហើយ នៅស្រុកព្រះនេត្រព្រះ គឺឈ្មោះ តាម៉ោង។ នៅស្រុកថ្មពួក ខ្ញុំពុំបានចាំទេ ខ្ញុំភ្លេច។

**ស៖** តើមានរឿងអីកើតឡើងចំពោះ តាម៉ោង ដែលជាចៅហ្វាយស្រុកព្រះនេត្រព្រះ ហើយនិង តាហាត់ ដែលជាចៅហ្វាយស្រុកភ្នំស្រុក នៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មនោះ <>?

[១៥:១៦:៣០]

**ឆ៖** ពេលហ្នឹង គឺដំណាក់កាលដែលពួកនិរតីចូលដល់ហើយ គេថា ហៅគាត់ទៅរៀនសូត្រ តែ ចំពោះរឿងអីផ្សេងទៀត ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងថា ពាក្យដែលគេហៅ “ទៅរៀនសូត្រ” សម័យនុ៎ងនោះ ចំពោះលោក លោក យល់យ៉ាងម៉េចដែរ ពេលគេប្រើពាក្យថា “ទៅរៀនសូត្រ កោះហៅទៅរៀនសូត្រ”?

**ឆ៖** ពេលដែលអង្គការហៅទៅរៀនសូត្រ គឺពិតជាយកទៅសម្លាប់ចោលហើយ។

**ស៖** តើអ្នកណាជាប្រធានតំបន់ ឬក៏លេខាតំបន់៥នោះ លោកនៅចាំទេ?

**ឆ៖** បាទ នៅពេលហ្នឹង តាវ៉ាល់ បានប្រជុំថា ឈ្មោះ តាហ៊ីង្ស ជាប្រធានតំបន់៥ ហើយ សម្រាប់គាត់ គឺជាអ្នកគ្រប់គ្រងចល័តតំបន់៥។

**ស៖** តើ តាហ៊ីង្ស ខ្លួនគាត់ផ្ទាល់ហ្នឹង ធ្លាប់ត្រូវបានគេបោសសម្អាតទេ ជាកម្មវត្ថុនៃការបោស សម្អាតទេ នៅពេលណាមួយនៅសម័យខ្មែរក្រហមហ្នឹង?

**ឆ៖** ឆ្នាំដែលពួកនិរតីចូលមកដល់ភូមិភាគពាយ័ព្យ បានប្រមាណជាបីបួនខែ ស្រាប់តែឮបញ្ហា ថា គេហៅ តាហ៊ីង្ស ហៅអីហ្នឹងទៅរៀនសូត្រ។ ខ្ញុំដឹងតែប៉ុណ្ណេះ។

**ស៖** តើលោកមានស្គាល់អ្នកដែលជំនួស តាហ៊ីង្ស ទេ គឺចូលមកកាន់ធ្វើជា<លេខា>តំបន់៥ ជំនួស តាហ៊ីង្ស? លោកដឹងថា គាត់ឈ្មោះអីទេ?

**ឆ៖** ខ្ញុំបាទពុំបានស្គាល់ទេ។ ពេលនោះ គឺជាពួកនិរតីដែលជាអ្នកគ្រប់គ្រង។

[១៥:១៩:២៩]

**ស៖** តើលោកស្គាល់ឈ្មោះ តារិន ទេ? ទោះយ៉ាងណាក្តីលោកបាននិយាយអំពីឈ្មោះ តារិន នេះប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារួចទៅហើយ តើលោកស្គាល់ឈ្មោះ តារិន ទេ?

**ឆ៖** ឈ្មោះ តារិន ហ្នឹង គឺពេលហ្នឹង តាវ៉ាល់ បានប្រជុំប្រាប់ពីរឿង តាម៉ោង, តារិន ដែលមាន

តួនាទីរៀងៗខ្លួន។ តែចំពោះមុខ ខ្ញុំបាទពុំដែលបានឃើញគាត់ទេ។

**ស៖** តើលោកមាននៅចាំរយៈពេលដែលមានការបោសសម្អាតនេះដែរឬទេ គឺនៅពេលដែលគេចាប់ផ្ដើមកោះហៅកម្មាភិបាលភូមិភាគពាយ័ព្យទៅរៀនសូត្រ ឬក៏ពេលដែលកម្មាភិបាលពីភូមិភាគនិរតីមកជំនួសកម្មាភិបាលភូមិភាគពាយ័ព្យហ្នឹង? លោកចាំពេលវេលាទេ តើពីខែណាដល់ខែណាដែរ ដែលមានការបោសសម្អាតបែបហ្នឹង?

**ឆ៖** ចំពោះថ្ងៃខែ ខ្ញុំពុំបានចាំទេ ក៏ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៧៨ ដែលភូមិភាគនិរតីចូលមកដល់ភូមិភាគពាយ័ព្យ។

**ស៖** តើនៅពេលនោះនោះ លោកនៅតែធ្វើការនៅទំនប់ត្រពាំងថ្មដដែលឬ ពេលគេចាប់ផ្ដើមធ្វើការបោសសម្អាតហ្នឹង?

**ឆ៖** ពេលហ្នឹង គេដកកម្លាំងខ្ញុំទាំងកង ទាំងអីទាំងអស់ហ្នឹងមកធ្វើចម្ការកប្បាសនៅភ្នំកងវ៉ាក្នុងស្រុកសិរីសោភ័ណ។

[១៥:២១:៣៥]

**ស៖** តើកូនប្រពន្ធរបស់កម្មាភិបាលនៃភូមិភាគពាយ័ព្យហ្នឹង ចាប់ពីថ្នាក់ឃុំ ស្រុក តំបន់អីជាដើមហ្នឹង តើប្រពន្ធកូនគាត់ទាំងអស់គ្នាហ្នឹង មានរឿងអីកើតឡើងចំពោះពួកគាត់ដែរ ឬក៏គេយកទៅធ្វើអីដែរ?

**ឆ៖** រឿងទាំងអស់ហ្នឹង គឺខ្ញុំដឹងតែរឿងភាគច្រើនគឺរឿងកងចល័តរបស់ខ្ញុំ តែរឿងនៅសហករណ៍ ឬរឿងនៅតាមតំបន់ គឺខ្ញុំបាទពុំអាចដឹងទេ។

**ស៖** តើ តាវ៉ាល់ ហ្នឹងត្រូវបានគេចាប់ខ្លួនដែរឬទេ? ហើយបើសិនជាគាត់ត្រូវបានគេចាប់ខ្លួនមែននោះ តើលោកដឹងតាមរបៀបណាដែរ?

**ឆ៖** ពេលនោះបាត់ឈ្មោះ តាវ៉ាល់ ខ្ញុំស្រាប់តែឮឈ្មោះ ស្រេះ នៅក្នុងកងវរៈ មិនមែនជាវរៈរបស់ខ្ញុំទេ គេបានប្រាប់ថា តាវ៉ាល់ អង្គការហៅទៅរៀនសូត្រហើយ។

**ស៖** បើតាមលោកគឺ តាហ៊ិង្ស, តាម៉ោង, តាហាត់, តាវ៉ាល់ ពួកគាត់ទាំងអស់ហ្នឹងត្រូវបានគេចាប់ខ្លួនក្នុងពេលតែមួយ ឬក៏យ៉ាងណា?

**ឆ៖** រឿងទាំងអស់ហ្នឹង គឺខ្ញុំគេបញ្ជូនពីអាងត្រពាំងថ្ម មកធ្វើការនៅចម្ការកប្បាស។ រឿងគេចាប់ក្នុងមួយពេលតែមួយហ្នឹង ឬក៏ចាប់ក្រោយគ្នា មុនគ្នា ខ្ញុំបាទពុំបានដឹងទេ។

[១៥:២៣:៤៥]

**ស៖** លោកអាចជម្រាបជូនតុលាការបានដែរឬទេ ថា តាខូវ ហើយនិង តាវន ហ្នឹងដែលជាប្រធានកងវរសេនាតូចហ្នឹងត្រូវបានជំនួសដោយកម្មាភិបាលមកពីនិរតី? ហើយបើសិនជាត្រូវបានជំនួសពីខាងនិរតីមែន លោកអាចឲ្យឈ្មោះ ជម្រាបឈ្មោះជូនតុលាការបានដែរឬទេ អ្នកមកជំនួសហ្នឹងឈ្មោះអ្វីខ្លះ?

**ឆ៖** ពេលដែលនិរតីចូលមកដល់ជំនួស តាវ៉ាល់ គឺដោយឈ្មោះ តាពាល់ ហើយជំនួសវរសេនាតូច ដែលឈ្មោះ តាវន និង តាខូវ គឺឈ្មោះ តានិន និង តាចេង ដែលមកពីភូមិភាគនិរតី។

**ស៖** តើលក្ខខណ្ឌការងារ ហើយនិងជីវភាពនៅពេលដែល តាពាល់ មកជំនួស តាវ៉ាល់ ហើយនិង តានិន ហើយនិង តាចេង ហ្នឹងបានជំនួស តាខូវ និង តាវន នោះតើមានការប្រែប្រួលជីវភាពឬក៏លក្ខខណ្ឌការងារ ហើយនិងការប្រែប្រួលទាក់ទងនឹងវិន័យហ្នឹងយ៉ាងណាដែរ<ក្នុងវរសេនាតូចទី១របស់លោក>?

**ឆ៖** រឿងទាំងអស់ហ្នឹង បើខាងជីវភាពគឺដូចតែគ្នា។ ហើយពេលនោះពួកនិរតី គឺរឹងរឹតតែតាមដានកម្មាភិបាលនៅភូមិភាគពាយ័ព្យ ហើយក៏មានចាប់ខ្លួនជាបណ្ដើរៗទៅដែរ។

**ស៖** តើមានចាត់វិធានការយ៉ាងម៉េចដែរ ដើម្បី<បង្កើនការឃ្លាំមើល និងការចាប់មនុស្ស? តើ> តាពាល់ <និងបញ្ជាការកងវរសេនាតូចកាលនោះប្រើមធ្យោបាយអ្វីខ្លះ?>

**ឆ៖** ចំពោះចំណាត់ការថ្មីរបស់ពួកដែលមកថ្មី គឺវាដូចជាពួកចាស់ដែរ គឺថាឲ្យយើងខំធ្វើការជូនអង្គការ កុំក្បត់អង្គការ ដូចៗតែគ្នាហ្នឹង។

[១៥:២៦:២៧]

**ស៖** អ៊ីចឹងខ្ញុំសួរថា ហេតុអីបានក៏មានការចាប់ខ្លួនច្រើនជាងមុន? <តើគេធ្វើអ្វីខ្លះ ដើម្បីធានាការចាប់មនុស្សឲ្យបានច្រើន?> តើពួកអ្នកមកថ្មីហ្នឹងគេតឹងរ៉ឹងជាងអ្នកចាស់ ឬក៏យ៉ាងណា?

**ឆ៖** ពេលដំណាក់កាលហ្នឹង តាមខ្ញុំពិនិត្យមើលទៅដូចជាពួកនិរតីនេះ សម្រាប់កម្មាភិបាលពាយ័ព្យដូចជាមិនទុកចិត្ត ហើយក៏ដូចជាយ៉ាងម៉េចថាមិនត្រូវដែរ ព្រោះថ្នាក់ត្រឹមវរសេនាតូចឡើងទៅគឺកម្មាភិបាលរបស់ភូមិភាគនិរតីតាមដានជាប់រហូត។

**ស៖** នៅពេលដែលលោកនៅត្រពាំងថ្ម តើមាន<បញ្ជាការ>កងវរសេនាតូច ជាពិសេសហ្នឹងកងវរសេនាតូចទី២ ដែលព្យាយាមរត់គេចខ្លួន ឬក៏ត្រូវបានគេបោសសម្អាត? តើមានករណីហ្នឹងកើត

ឡើងទេ?

**ឆ៖** បាទ ពេលហ្នឹង គេហៅៗឈ្មោះ ស្រេះ ឈ្មោះខ្ញុំបាទផងអីផងមកប្រជុំ តែសម្រាប់យោធារបស់ភូមិភាគនិរតី គេចាប់តែឈ្មោះ ស្រេះ មួយទេ។ ក្រោយមកទៀតដល់វរៈ២ហ្នឹង ឮថាចាប់ឈ្មោះ ស្រេះ មានគ្នាប្អូនបីប្អូននាក់ ក៏នាំគ្នារត់ចោលអង្គភាព មិនដឹងជាឆ្ពោះទៅទិសខាងណា។

**ស៖** លោកបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9010 លោក <នៅទំព័រ២៤ ជាភាសាបារាំង, ទំព័រ៤២ ជាភាសាខ្មែរ, និងទំព័រ២៥ ជាភាសាអង់គ្លេស ហើយលោក>បានឆ្លើយដូចតទៅនេះ៖ “អារ៉ិត, អាស្រេះ, អាធួន, អារ៉ៃ អ្នកទាំងអស់នោះសុទ្ធតែព្យាយាមរត់គេចខ្លួន គេសុទ្ធតែជាប្រធានកងវរសេនាតូចទាំងអស់។” សំណួរគេសួរលោកថា៖ “តើពួកគេទាំងអស់ធ្វើការនៅឯណា?” លោកឆ្លើយថា៖ “គេធ្វើការនៅអាងត្រពាំងថ្ម ប៉ុន្តែគេនៅក្នុងកងវរសេនាតូចទី២។” គេសួរទៀតថា៖ “តើអ្នកទាំងអស់ហ្នឹងមកពីពាយ័ព្យ?”។ សំណួរខ្ញុំសួរលោកថា តើគាត់ហ្នឹងសុទ្ធជាអ្នកមកពីពាយ័ព្យ ឬក៏មកពីនិរតី? ហើយលេខ ERN នៃឯកសារអម្បាញ់មិញនេះ គឺជាភាសាបារាំងទំព័រ ២៤ សុំទោស។

[១៥:២៩:២៦]

**ឆ៖** បាទ ឈ្មោះ ស្រេះ ដែលយោធានៅភូមិភាគពាយ័ព្យចាប់ទៅ ហើយឈ្មោះ រ៉ិត, ឈ្មោះ វ៉ុយ មិនមែន រ៉ៃ ទេគឺឈ្មោះ វ៉ុយ, ឈ្មោះធួន ហ្នឹងគឺជាភូមិពាយ័ព្យ ភូមិភាគពាយ័ព្យទាំងអស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមឱ្យសហព្រះរាជអាជ្ញារង ប្រាប់លេខ ERN ជាភាសាខ្មែរ និងភាសាអង់គ្លេសផងបាទ។ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំឱ្យលេខទំព័រ ខ្ញុំគិតថាប្រហែលគ្រប់គ្រាន់ តែបើសិនជាចង់បានលេខ ERN នោះ ប្រហែលជាត្រូវការចំណាយពេលបន្តទៀត។ ជាភាសាខ្មែរទំព័រ៤២។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទយើងនិយាយពីការបោសសម្អាត ហើយនិងកម្មាភិបាលដែលគេត្រូវបានកោះហៅទៅ

ប្រជុំរៀនសូត្រ ហើយក្រោយមកបានបាត់ខ្លួន។ តើបើតាមលោកដឹងនោះ តើមានការប៉ុនប៉ងអំពីសំណាក់កម្មាភិបាលនៃភូមិភាគពាយ័ព្យ ហើយជាពិសេសនោះ គឺនៅក្នុងតំបន់៥តែម្តងក្នុងការប្រឆាំងនឹងការបោសសម្អាត<>ដែលគេបានធ្វើទៅលើខ្លួននៅពេលនោះដែរឬទេ?

[១៥:៣១:០២]

**លោក ឈុំ សេង៖**

**ឆ៖** បាទ សំណួរហ្នឹង ខ្ញុំស្តាប់អត់ច្បាស់។ សូមលោក--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មានឱកាសមួយចំនួននោះ ខ្ញុំចង់ជំទាស់ដែរ ប៉ុន្តែខ្ញុំសូមជំទាស់តែចំពោះឧទាហរណ៍ជាក់លាក់មួយនោះទេ។ ការជំទាស់របស់ខ្ញុំគឺផ្តោតទៅលើពាក្យថា "បោសសម្អាត"។ បើសាក្សីគាត់ប្រើប្រាស់ពាក្យនេះជាទូទៅ ខ្ញុំមិនជំទាស់អីទេ ក៏ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាប្រើពាក្យនេះ គឺដើម្បីមកឲ្យវារៀបរាប់គ្រប់ដណ្តប់ទៅដល់សកម្មភាព និងព្រឹត្តិការណ៍ទាំងអស់។ ខ្ញុំយល់ថាសាក្សីរូបនេះ គឺថាមិនមានតួនាទីណាមួយអាចបញ្ជាក់ច្បាស់លាស់ អំពីការបោសសម្អាត ការចាប់ខ្លួន ឬក៏សួររឿងអប់រំនេះ យើងអាចសួរបាន ក៏ប៉ុន្តែពាក្យ "បោសសម្អាត" នេះគឺថាជាពាក្យមួយ ដែលមានតែថ្នាក់ខ្ពស់មួយចំនួនទេ ទើបយល់អំពីពាក្យនេះបាន។ ដូច្នេះ សាក្សីដែលនៅពេលនោះមានកម្រិតប៉ុណ្ណោះ។ <សាក្សីរូបនេះ អាចផ្តល់សក្ខីកម្មនូវអ្វីដែលគាត់បានឃើញផ្ទាល់ និងឆ្លងកាត់ផ្ទាល់តែប៉ុណ្ណោះ។> ថាតើ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយបោសសម្អាតយ៉ាងណានោះ សាក្សីរូបនេះមិនដឹងទេ។ អ៊ីចឹងសាក្សីនេះ គឺថាសួរតែផ្តោតខ្លាំងបំផុតទៅលើតែអង្គហេតុបានហើយ ហើយគ្រាន់តែសួរសាក្សីគាត់បានឃើញអ្វី ជាជាងថាគាត់គិតយ៉ាងម៉េច យល់យ៉ាងម៉េច ពាក្យបោសសម្អាតអីនេះ។ ដោយសារតែពាក្យពេចន៍ទាំងអស់នេះ គឺថាទាមទារឲ្យមានការយល់ដឹង គឺថាភ្លាមៗតែម្តងចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា <ដូចជាហេតុផលជាក់លាក់នៃការចាប់ខ្លួនជាដើម>។ ដូច្នេះ ការជំទាស់ គឺសុំកុំឲ្យប្រើពាក្យ "បោសសម្អាត" នេះ យើងសួរតែបញ្ហាអង្គហេតុឲ្យបានជាក់លាក់តែម្តង។

[១៥:៣៣:១៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសុំឱ្យមេធាវីការពារក្តីជំទាស់ខ្លី ហើយឆាប់ស្រួលយល់។ ឥឡូវដើម្បីឆ្លើយទៅការជំទាស់នេះ ពាក្យហ្នឹង គឺជាពាក្យដែលខ្មែរក្រហមប្រើដោយខ្លួនឯងតែម្តង។ អម្បាញ់មិញនេះ សាក្សីបាននិយាយថា នៅពេលដែលគេកោះហៅទៅរៀនសូត្រនោះ ចំពោះរូបគាត់នោះ គឺថាគឺច្បាស់ហើយ គឺយកទៅសម្លាប់។ អ៊ីចឹងបើសិនជានិយាយអំពីពាក្យពេចន៍ និងការប្រើពាក្យពេចន៍នេះ ឥឡូវខ្ញុំសួរសំណួរម្តងទៀត។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី នៅក្នុងចំណោមកម្មាភិបាលនភូមិភាគពាយ័ព្យ តំបន់៥ តើមានកម្មាភិបាលណាដែលព្យាយាមប្រឆាំងនឹងការ<ចាប់ខ្លួនធ្វើឡើងពីសំណាក់កម្មាភិបាល>ភូមិភាគនិរតីដែរឬទេ? <នៅពេល>ខ្ញុំនិយាយ<ថា "ប្រឆាំងនឹងការចាប់ខ្លួន" គឺខ្ញុំចង់មានន័យថា ការប្រឆាំងតស៊ូដោយប្រដាប់អាវុធ ដើម្បីមិនឱ្យគេចាប់។>

**លោក ឈុំ សេង៖**

**ឆ៖** ពេលដំណាក់កាលហ្នឹង គឺខ្ញុំពុំបានដឹងដល់ទេ។ គ្រាន់តែថា និរតី ពួកនិរតីប្រជុំគឺប្រាប់ថាឱ្យយើងទាំងអស់គ្នាស្មោះត្រង់ជាមួយអង្គការ ជាមួយបក្សតែប៉ុណ្ណឹង។

[១៥:៣៤:៤៨]

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីតួនាទីរបស់ តាវ៉ាល់ នៅពេលដែលគាត់ជាប្រធានកងចល័ត<។> នៅ<ការដ្ឋាន>ត្រពាំងថ្មនោះ <តើ>គាត់<មាន>គ្រប់គ្រងលើអ្នកធ្វើការផ្សេងៗទៀតដែលមកពីស្រុកនានា ឬក៏ពីសហករណ៍នានាដែរឬទេ?

**ឆ៖** បាទ នៅពេលហ្នឹងមកពីសហករណ៍ហ្នឹង គឺមានមេគេម្នាក់ៗរួចស្រេចមកទៅហើយ ក៏ប៉ុន្តែបើចូលមកដល់ជីកអាងត្រពាំងថ្មនេះ គឺក្រោមការគ្រប់គ្រងរបស់ តាវ៉ាល់ ទាំងអស់។

**ស៖** តើ តាវ៉ាល់ គាត់មកពីណាដែរ? ហើយគាត់ធ្វើការនៅឯណា ពេលដែលលោកធ្វើការនៅត្រពាំងថ្មនោះ? ឧទាហរណ៍ដូចជា ថាតើមន្ទីររបស់គាត់ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ពេលនោះ ខ្ញុំទៅនៅចម្ការកប្បាស ក៏ប៉ុន្តែ តាវ៉ាល់ គ្រាន់តែដឹងថា តាវ៉ាល់ ហ្នឹងជាភូមិភាគពាយ័ព្យ ហើយទីតាំងរបស់គាត់ ពេលនោះនៅជិតអាងត្រពាំងថ្មដែរ ដែលមានរោងម៉ាស៊ីនចាស់មួយរោងម៉ាស៊ីននោះឈ្មោះ តាប៉ាត ហើយគាត់ក៏ស្នាក់នៅកន្លែងហ្នឹងទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមអរគុណ។ អម្បាញ់មិញ លោកនិយាយអំពីចម្ការកប្បាស។ <តើនៅជប់ឬ?> អ៊ីចឹងខ្ញុំចង់ដឹងថាតើ តាវ៉ាល់ ហ្នឹងគាត់មានមន្ទីរគាត់នៅចម្ការកប្បាសហ្នឹងមែនទេ?

**ឆ៖** បាទ ពេលដែលចប់អាងត្រពាំងថ្ម គេបញ្ជូនអង្គភាពរបស់ខ្ញុំបាទមកចម្ការកប្បាសកងវ៉ា ពេលនោះអង្គការបានហៅឈ្មោះ តាវ៉ាល់ នេះទៅរៀនសូត្របាត់ទៅហើយ។

[១៥:៣៧:១៨]

**ស៖** លោកបាននិយាយថា គាត់មានមន្ទីរនៅជិតត្រពាំងថ្ម។ តើ តាវ៉ាល់ គាត់ទៅការដ្ឋានទៀងទាត់ទេ? ហើយបើគាត់ទៅហ្នឹង គាត់ទៅពេលថ្ងៃ ឬក៏ពេលយប់?

**ឆ៖** រឿងទាំងអស់នេះ មិនទៀងទេ ជួនកាលកន្លះខែទៅម្តង ជួនកាលពីរបីថ្ងៃទៅម្តង ក៏ប៉ុន្តែមានពេលខ្លះក៏នៅយូរជាងនោះទៀត ដែលគាត់បានទៅមើលការដ្ឋានម្តង។

**ស៖** នៅពេលដែល តាវ៉ាល់ ចុះទៅមើល តើកម្មករមានអាកប្បកិរិយាផ្សេងពីមុនទេ ហើយពួកគេខ្លាច តាវ៉ាល់ ទេ?

**ឆ៖** បាទ ពេលហ្នឹង គឺប្រជាពលករទាំងអស់ មិនថារូបខ្ញុំ មិនថាអ្នកណាទេ ឲ្យតែឃើញ ឮថា តាវ៉ាល់ ទៅ ឬក៏ឃើញ ពេលនោះគឺទាំងអស់គ្នាគឺប្រឹងអស់ពីសមត្ថភាព គិតតែពីខាងកាប់ដោយគ្មានអើតមើលគ្នាទៅវិញទៅមកបានទេ។

**ស៖** ចុះនៅពេលដែលអ្នកបន្ទាប់ពី តាវ៉ាល់, តាពាល់ ហ្នឹងមកចុះមកមើលការដ្ឋានហ្នឹង លោកធ្វើដូចនៅពេលដែល តាវ៉ាល់ ចុះមកដែរមែនទេ?

**ឆ៖** បាទ តាពាល់ ពេលដែល តាវ៉ាល់ ទៅរៀនសូត្រ ហើយ តាពាល់ ចុះមក ក៏ពេលដែលឃើញ តាពាល់ ក៏ដំណើរការសម្រាប់យើងជីក ឬយើងកាប់អាហ្នឹងគឺធ្វើដូចគ្នា។

[១៥:៣៩:២៨]

**ស៖** តើលោកមានទំនាក់ទំនងល្អជាមួយ តាវ៉ាល់ ទេ? លោកជិតស្និទ្ធនឹង តាវ៉ាល់ ទេ? <បើស្និទ្ធស្នាល តើស្ថានភាពទំនាក់ទំនងនេះយ៉ាងម៉េចដែរ?>

**ឆ៖** ក្នុងដំណាក់កាលនោះគឺ តាវ៉ាល់ គាត់បានហៅខ្ញុំទៅប្រើ។ ដូច្នេះខ្ញុំដូចជា ថាបានជិតស្និទ្ធជាមួយគាត់ដែរ ព្រោះគាត់ហៅខ្ញុំទៅប្រើ ដូចជាប្រើទៅណេះទៅណោះអី គឺគាត់ជាអ្នកបញ្ជាខ្ញុំ។

**ស៖** ដូច្នេះមានន័យថា លោកជួបគាត់ជាញឹកញាប់។ <តើអ៊ីចឹងមែនទេ?> អ៊ីចឹងខ្ញុំចង់ដឹងថាលោកទៅមន្ទីរគាត់ហ្នឹងញឹកញាប់ទេ ដើម្បីទៅទទួលបញ្ជានៅទីនោះនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ មិនជាញឹកញាប់ប៉ុន្មានទេ ក៏ប៉ុន្តែការងារដូចជាទៅឆ្ងាយ ដូចជាទៅដកកងកម្លាំងពីភ្នំកូនខ្លែងមកអាងត្រពាំងថ្មវិញ គឺគាត់បានប្រើខ្ញុំ។

**សៈ** ចុះលោកមានធ្លាប់ចូលរួមក្នុងកិច្ចប្រជុំដែលដឹកនាំដោយ តាវ៉ាល់ ទេពេលនៅត្រពាំងថ្ម?

**ឆ៖** បាទ ពេលហ្នឹងត្រឹមលំដាប់កងធំ ទូទាំងវរៈ ហើយនិងប្រធានវរៈ គឺបើមានផែនការណាប្លែកគឺ តាវ៉ាល់ តែងហៅទៅប្រជុំជានិច្ច។

**សៈ** អម្បាញ់មិញនេះលោកនិយាយថា អង្គការឲ្យតាមដានមនុស្សនៅក្នុងកងរបស់លោក<ឲ្យបានយ៉ាងហោចម្នាក់>។ អ៊ីចឹងខ្ញុំចង់ដឹងថា តាវ៉ាល់ ហ្នឹងផ្ទាល់មែនទេ ជាអ្នកប្រាប់លោកឲ្យតាមដានមនុស្សនៅក្នុងកងរបស់លោកនោះ?

**ឆ៖** បាទ ពេលហ្នឹងគឺ តាវ៉ាល់ បានប្រជុំប្រាប់ត្រឹមថ្នាក់កងអនុសេនាធំ ហើយនិងកងវរៈ ថាមួយថ្ងៃគឺត្រូវតាមដានក្នុងកងនោះឲ្យបានមួយថ្ងៃម្នាក់ តើអ្នកណាជានិស្សិត អ្នកណាជាបញ្ញវន្ត អ្នកណាទាហាន លន់ នល់។

[១៥:៤២:២១]

**សៈ** ចុះ តាវ៉ាល់ មានចេញសេចក្ដីណែនាំយ៉ាងម៉េចទៀត នៅពេលដែលប្រធានកងធំបានរកឃើញថា អ្នកណាម្នាក់ជាអតីតទាហាន លន់ នល់ ឬក៏ជាអតីតបញ្ញាជននោះ? តើគេធ្វើយ៉ាងម៉េចបន្តទៅទៀត<ជាមួយមនុស្សទាំង>ហ្នឹង?

**ឆ៖** បាទ នេះនៅលើគ្រប់គ្រងផ្ទាល់។ បើអ្នកគ្រប់គ្រងមិនរាយការណ៍ទៅឲ្យ តាវ៉ាល់ ក៏មនុស្សនុ៎ងក៏រួចខ្លួន។ បើសិនជាប្រធានកងរាយការណ៍ទៅ តាវ៉ាល់ គឺមនុស្សនោះ ដឹងតែគេយកទៅសម្លាប់។

**សៈ** <តាមបញ្ជារបស់ តាវ៉ាល់> តើប្រធានកងធំអាចសម្រេចខ្លួនឯងផ្ទាល់ថា ត្រូវសម្លាប់ ឬមិនសម្លាប់ខ្មាំងដែលគេរកឃើញហ្នឹងបានដោយខ្លួនឯងទេ?

**ឆ៖** បាទ ក្នុងដំណាក់កាលហ្នឹង ប្រសិនបើអ្នកណាដែលប្រើឲ្យទៅរែកដី ហើយតវ៉ានឹងមេកង បើមេកងស្អប់ផង មេកងអាចបំភ្លៃថា ហ្នឹងគឺប្រឆាំងនឹងអង្គការ អ្នកហ្នឹងគឺជាទាហានលន់ នល់ ជាដើម ។ល។

**សៈ** អ៊ីចឹងក្នុងករណីបែបនេះ នៅពេលដែលគាត់ចង់នាំមនុស្សទៅសម្លាប់ហ្នឹង ខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នក ជាជនដៃដល់ ជាអ្នកដែលសម្លាប់ទាហានទាំងអស់នោះផ្ទាល់តែម្ដងនោះ?

**ឆ៖** ពេលហ្នឹងរាយការណ៍ទៅដល់ តាវ៉ាល់ អីទៅ គឺខ្ញុំមិនស្គាល់ឈ្មោះទេ ក៏ប៉ុន្តែគ្រាន់តែថា

មនុស្សនោះជាមនុស្សដែលធ្វើទាហានរបស់អង្គការ ដែលគេមានអាវុធមានអីត្រឹមត្រូវ មកចាប់មនុស្សនោះយកទៅសម្លាប់ចោល។

[១៥:៤៤:៥១]

**ស៖** អ្នកដែលសម្លាប់ហ្នឹងជាឈ្លប ឬក៏ជាកងទ័ព?

**ឆ៖** បាទ ដែលខ្ញុំបាទ បានមកធ្វើការនៅអាង នៅចម្ការកប្បាសហ្នឹង គឺការពិត គឺសុទ្ធតែជាកងទ័ពទាំងអស់ ដែលចាប់យកទៅសម្លាប់ចោល។

**ស៖** ខ្ញុំនិយាយនេះ គឺខ្ញុំសំដៅទៅលើត្រពាំងថ្ម។ នៅពេលដែលគេរកឃើញថា អ្នកណាម្នាក់ជា <អតីត>ទាហាន លន់ នល់ ហើយគេចោទថាជាខ្មាំង ហើយយកទៅសម្លាប់នោះ នៅត្រពាំងថ្មនោះ។ ខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកសម្លាប់នៅត្រពាំងថ្មហ្នឹង គឺអ្នកណាជាឃាតករ? ខ្ញុំ<មិន>សំដៅទៅលើនៅចម្ការកប្បាសទេ ខ្ញុំសំដៅទៅត្រពាំងថ្ម។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៥:៤៥:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ចំពោះការតាំងសំណួរនេះ ដូចដែលខ្ញុំជំទាស់ពីខាងដើមដែរ ដោយសារសំណួរពាក់ព័ន្ធទៅនឹងការកំណត់មកលើគោលដៅ មកលើរដ្ឋការនៃរបប លន់ នល់។ ប៉ុន្តែឥឡូវហ្នឹង គឺថាខ្ញុំអត់មានឮសួរសួរអំពីរឿងកម្មាភិបាលនិរតីអ្វីសោះ។ ក៏ប៉ុន្តែចំណុចនេះច្បាស់ហើយ គឺវាពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយនៅឯការដ្ឋានទំនប់ត្រពាំងថ្ម ហើយអង្គជំនុំជម្រះបានសម្រេចច្បាស់លាស់ហើយ។ បាទ ដូច្នេះ ខ្ញុំសូមជំទាស់ ព្រោះថានិយាយអំពីការដ្ឋាននេះវិញ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំសូមជំទាស់ទៅនឹងការជំទាស់នេះ។ ក្នុងក្របខ័ណ្ឌនៃត្រពាំងថ្មហ្នឹងខ្ញុំចង់ដឹងថា តើមានរឿងអ្វីកើតឡើងចំពោះខ្មាំងគ្រប់ទាំងអស់ ដូចជា<អតីត>ទាហានលន់ នល់ <ឬក៏ជាអ្នកដែលមិនចង់ធ្វើការ>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឬក៏ជាបញ្ញាជន<>នោះ<។ ក្នុងករណីនេះ ពិតណាស់ គឺជាមាន>ប្រជាជនថ្មី<>ធ្វើការនៅ<អាង>ត្រពាំងថ្មនោះ<ដែរ>។ តើវាហេតុការណ៍យ៉ាងម៉េច? យើងឃើញហើយមានឧក្រិដ្ឋកម្មប្រព្រឹត្តនៅទីនោះ ហើយយើងមិនដឹងថាតើឧក្រិដ្ឋកម្មហ្នឹង គឺតម្រង់ទិសទៅរកតែទាហាន លន់ នល់ ឬក៏យ៉ាងម៉េច។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរ<>ថា តើ<មានអ្វីកើតឡើង ហើយ>នៅ<ទីណា ហើយអ្នកណាគេជាអ្នកសម្លាប់មនុស្សទាំងនេះ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំអាចសួរសំណួរនេះបាន លោកប្រធាន>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក វ៉ិចទ័រ កូប៉េ ចំពោះសំណួរនេះ។ ហើយចំណុចនេះមានការពាក់ព័ន្ធនូវអង្គហេតុដែលអង្គជំនុំជម្រះកំពុងធ្វើសវនាការ ហើយអង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីរូបនេះ ចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ សូមអញ្ជើញសាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិចុងក្រោយអម្បាញ់មិញនេះ!

[១៥:៤៧:៥១]

**លោក ឈុំ សេង៖**

**ឆ៖** បាទ សំណួរអំមិញវែងពេក ហើយដល់អ៊ីចេះទៅ ខ្ញុំស្ដាប់មិនបាន។ សូមឲ្យលោកមានប្រសាសន៍ម្ដងទៀត បាទ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ អម្បាញ់មិញនេះ លោកនិយាយថានៅត្រពាំងថ្ម នៅពេលប្រជុំ តាវ៉ាល់ ប្រាប់ឲ្យប្រធានកងធំ តាមដានទៅលើសមាជិកកងរបស់ខ្លួន។ ឥឡូវនេះ ខ្ញុំចង់ដឹងថា នៅពេលដែលគេរកឃើញថា អ្នកណាម្នាក់ជាខ្មាំងនោះ លោកបានឆ្លើយថា គឺមានពួកឃាតករមានកាំភ្លើងយកទៅសម្លាប់ចោល។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅ<អាង>ត្រពាំងថ្មហ្នឹង តើជាឈ្លបស្រុកដែលមានកាំភ្លើង ឬក៏ជាទាហាន ឬក៏ជាកងទ័ព ដែលជាអ្នក ដែលជាជនដៃដល់ក្នុងការសម្លាប់ជនរងគ្រោះទាំងអស់នោះ?

**ឆ៖** បាទ ពេលដែលនៅជំនាន់ហ្នឹង ពេលកងទ័ពនិរតីមិនទាន់មកដល់ គឺទាហានរបស់ភូមិភាគពាយ័ព្យហ្នឹង ដែលសម្លាប់ប្រជាជននៅនេះ។ ហើយដែលពេលដែលនិរតីចូលមកដល់ ពេលហ្នឹងភូមិភាគពាយ័ព្យក៏បានបែកបាក់គ្នា ខ្លះក៏មិនដឹងជាទៅណា ហើយក៏ភូមិភាគនិរតីបន្តចាប់ប្រជាជនទាំងអស់នោះ យកទៅបាញ់ចោលតាមកម្រិតរបស់គេទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៤៩:២៨]

**ស៖** តើមានអ្នកណាដែលត្រូវបានគេសម្លាប់ចោលនៅជិតនឹង ឬក៏ជុំវិញនឹងស្ពានទី១ហ្នឹងតែម្ដង? <ជាកន្លែងគេឲ្យលោកធ្វើការ។> ខ្ញុំមិនសួរថា ជាលោកឬក៏អត់ទេ ខ្ញុំគ្រាន់តែសួរថា តើមានអ្នកណាដែលត្រូវបានគេសម្លាប់ ហើយគេទម្លាក់ចោលនៅអាង នៅរណ្ដៅក្បែរនឹងស្ពានទី១ហ្នឹងទេ?

**ឆ៖** បាទ នៅពេលហ្នឹង គឺខ្ញុំបានឃើញ។ ពេលនោះក្នុងកងនោះ មិនមែនជាកងរបស់ខ្ញុំទេ គឺជាកងអ្នកនៅក្បែរហ្នឹងដែរ ដែលយប់ដែលវ៉ៃសម្រុកហ្នឹងគឺចំនួន១២នាក់ឈឺ ហើយ តាវ៉ាល់ ក៏មានផែនការឲ្យដុតភ្លើង ដុតឲ្យឆេះទៅរួច ពន្លត់ចោល ពន្លត់ចោលរួច ឲ្យចាប់ដៃគ្នាដើរទៅ បើអ្នកជាន់ភ្លើង អ្នកនោះពិតជាងងឹងមាន់មែន ពិតជាខ្វាក់មែន។ តែបើអ្នកណាដើរមិនជាន់ភ្លើង អ្នកនោះគឺឈឺសតិអារម្មណ៍។ ដូច្នេះក្នុងចំណោម១២នាក់នោះ គឺ១១នាក់ ដែលដើរគេចពីភ្លើង ហើយម្នាក់នោះគឺដើរជាន់ភ្លើង បានន័យថា អ្នកនោះពិតជាខ្វាក់មាន់មែន។ ដូច្នេះបានរស់តែមួយគត់។ ក្រៅពីនោះ គឺពួកទាហាន ពួកយោធាយកទៅសម្លាប់ចោល មិនដឹងជាសម្លាប់នៅកន្លែងណា ព្រោះកន្លងមក តាំងពីយកទៅ គឺបាត់ខ្លួន អត់ឃើញមកកន្លែងវិញ។

**ស៖** <ពេលលោកនិយាយថា ពួកគេរួចខ្លួន>អ៊ីចឹង លោកចង់និយាយថា មានអ្នកខ្លះ<រួចខ្លួនដោយមិន>ដើរជាន់<រងើក>ភ្លើង មែនទេ? អ៊ីចឹងតើក្នុងចំណោមអ្នកទាំង<១២នាក់ហ្នឹង> តើមានអ្នកណាខ្លះដែលរួចខ្លួន ដែល<>ត្រូវបានគេសម្លាប់<តាមវិធី>នោះ?

**ឆ៖** បាទ ក្នុងចំនួន១២នាក់ហ្នឹង គឺ១១ដើរគេចភ្លើង ហើយនៅតែម្នាក់ទេ ដែលខ្ញុំមិនចាំឈ្មោះ។ ដូច្នេះមានតែម្នាក់មួយដែលគេច ដូច្នេះ តាវ៉ាល់ អនុញ្ញាតឲ្យរស់បានតែមួយគត់ ក្នុងចំណោម១២នាក់ហ្នឹង។

[១៥:៥១:៥០]

**ស៖** តើគេមានធ្វើតេស្តសាកល្បងអ្វីខ្លះទៀតទេ ដើម្បីចង់ដឹងថាអ្នកណាធ្វើពុតជាខ្វាក់មាន់ ឬក៏មិនមែននោះ? ដូចជាលោកធ្លាប់ឮ គេនិយាយថា តាវ៉ាល់ គាត់បានប្រើតេស្តផ្សេង ក្រៅពីរងើកភ្លើងដូចជាឧទាហរណ៍ ដូចជាគាត់មានប្រើជារណ្ដៅ ជាអីជាដើម ដើម្បីឲ្យអ្នកដែលខ្វាក់មាន់ហ្នឹងដើរទេ?

**ឆ៖** បាទ ក្រៅពីហ្នឹង ខ្ញុំដូចជាមិនដែលបានឃើញអីទេ ក្រៅពីការដែលដើរឲ្យដឹកមនុស្សដែលខ្វាក់មាន់នេះឲ្យដើរជាន់ភ្លើង។ ខ្ញុំមិនដែលឃើញគាត់ឲ្យធ្វើអីទៀតទេ។

**ស៖** តើ តាវ៉ាល់ ជាកម្មាភិបាលស្មោះត្រង់នឹងថ្នាក់លើ និងបក្សដែរឬទេ? ព្រោះថាលោក

លោកស្គាល់គាត់គួរសមដែរ អ៊ីចឹងតើគាត់ជាមនុស្សស្មោះត្រង់នឹងបក្ស និងថ្នាក់លើដែរឬទេ?

**ឆ៖** បាទ ក្នុងសម្ដីរបស់គាត់ ដែលប្រជុំប្រធានទាំងអស់ ថាគាត់ស្មោះត្រង់នឹងបក្ស តស៊ូស្លាប់រស់ជាមួយបក្ស។ តែសម្រាប់ចិត្តគាត់ គឺខ្ញុំមិនអាចស្មានបាន មិនអាចស្ទង់បាន មិនដឹងជាគាត់ស្មោះត្រង់ឬយ៉ាងណា។

**ស៖** បើតាមលោកសង្កេតឃើញហ្នឹង គាត់ជាមនុស្សហ្មត់ចត់ តឹងរ៉ឹងដែរឬទេ?

**ឆ៖** បាទ មនុស្ស តាវ៉ាល់ បើខ្ញុំស្មានទៅ បើអ្នកណាម្នាក់ចេះអែបអប បងអីចេះចុះ ប្រហែលជារួចខ្លួន មិនអីទេ ក៏ប៉ុន្តែបើសិនជាជំទាស់ គឺដឹងថាស្លាប់។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីកិច្ចប្រជុំដែលលោកបានចូលរួម ហើយគេប្រាប់លោកថា ត្រូវតាមដានសមាជិកកងធំមួយថ្ងៃឲ្យបានម្នាក់។ តើលោកអាចជម្រាបបានទេថា អ្នកណាខ្លះចូលរួមក្នុងកិច្ចប្រជុំហ្នឹង? ហើយគេចេញបញ្ជាបែបហ្នឹងតែម្ដងទេ នៅក្នុងពេលប្រជុំហ្នឹង ឬក៏គេប្រាប់ប្រជុំច្រើនដង ហើយគេប្រាប់ដដែលៗថាឲ្យតាមដានហ្នឹង?

[១៥:៥៤:៣៨]

**ឆ៖** បាទ នៅពេលហ្នឹង គឺចាប់ពីប្រធានកងធំ រហូតដល់ប្រធានវរៈអី គឺគាត់ប្រជុំតែម្ដងទេ ប្រជុំប្រាប់ឲ្យយើងចាំ ហើយឲ្យតាមដានជាប្រចាំ។

**ស៖** តើគេមានធ្លាប់ដាក់ទណ្ឌកម្មចំពោះប្រធានកង ដែលបានសម្លាប់ខ្មាំងដែលគេរកឃើញទេ? អម្បាញ់មិញនេះ លោកនិយាយថា ប្រសិនបើមេកងមិនពេញចិត្តអ្នកណាម្នាក់ហ្នឹង គឺថារាយការណ៍អាក្រក់ពីអ្នកហ្នឹងទៅ ដើម្បីសម្លាប់អ្នកហ្នឹងចោល។ អ៊ីចឹងនៅពេលដែលមានការរាយការណ៍អាក្រក់ថាអ្នកហ្នឹងជាខ្មាំងអីអ៊ីចឹង តែតាមពិតគាត់មិនមែនជាខ្មាំងទេ ហើយមេកងសម្លាប់ចោលអ៊ីចឹង គេមានដាក់ទណ្ឌកម្មអីទៅលើមេកងហ្នឹងទេ?

**ឆ៖** ពេលហ្នឹង ពុំមានទេ ព្រោះដោយសារមេកងហ្នឹង វាអត់យោគយល់ចិត្តគ្នា គ្រាន់តែគ្នាទំនាស់តិចតួច ក៏មេកងរាយការណ៍ទៅឲ្យខាងលើនោះទៀតថាឈ្មោះ “ក” ហ្នឹង ឧទាហរណ៍ថា ឈ្មោះ “ក” នេះពិតជាទាហានលន់ នល់ ពិតជានិស្សិតបញ្ញវន្ត ពិតជាកូនអ្នកមាន នាយទុនសក្តិភូមិ។ ហើយពេលដែលយកមនុស្សទៅសម្លាប់ចោល មានតែអង្គការខាងលើថា ល្អ អូខេ ល្អ។

**ស៖** លោកបាននិយាយអំពីការសម្លាប់អ្នកដែលគេរកឃើញថាជាខ្មាំង នៅក្នុងកង<អនុសេនាធំ និងកងវរសេនាតូចអីជាដើម។> ហើយលោកនិយាយអំពីការសម្លាប់មនុស្ស១១នាក់ ដែលធ្វើពុតជា

ខ្វាក់មាន់ ហើយត្រូវបាន តាវ៉ាល់ ធ្វើតេស្តឲ្យដើរលើភ្លើង។ ក្រៅពីអ្នកទាំងអស់ហ្នឹង តើមានអ្នកណាផ្សេងទៀត ដែលបានបាត់ខ្លួន ឬក៏ត្រូវបានសម្លាប់នៅត្រពាំងថ្មទេ បើតាមការមើលឃើញ ឬក៏ស្តាប់ឮរបស់លោកនោះ?

**ឆ៖** ក្រៅពី--

[១៥:៥៦:៥៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថា តើយើងបានស្វែងយល់ ថាតើពិតជាមានការសម្លាប់នៅឯការដ្ឋានទំនប់ត្រពាំងថ្ម ឬក៏អត់នោះទេ។ ខ្ញុំឮសាក្សីនិយាយ ថាគេនាំមនុស្សយកទៅសម្លាប់ចោល។ <"យកទៅ" អាចមានន័យថាយកទៅណាក៏បានដែរ។> ដូច្នេះទី១ ខ្ញុំយល់ថាគួរតែស្វែងរកឲ្យឃើញ ថាតើសាក្សីរូបនេះ ពិតជាបានឃើញការសម្លាប់ហ្នឹងដោយផ្ទាល់ភ្នែក ពិតជាឃើញមនុស្សស្លាប់ដោយផ្ទាល់ភ្នែកដែរឬក៏អត់។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីគង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយនេះ ជាពិសេសទាក់ទងទៅនឹងការសន្និដ្ឋានរបស់តំណាងសហព្រះរាជអាជ្ញា ដែលថាមានគេយកទៅសម្លាប់នៅក្នុងកងរបស់សាក្សី។ ហើយកន្លងមកនេះ គឺសាក្សីមិនដែលបាននិយាយថា មានការយកមនុស្សទៅសម្លាប់ក្នុងកងរបស់ខ្លួនទេ គឺគាត់បានឃើញក្រុមអ្នកជិតខាង កងអ្នកជិតខាង។ ដូច្នេះការធ្វើសេចក្តីសន្និដ្ឋានទៅលើអង្គហេតុដែលមិនមែនជាសក្ខីកម្មរបស់សាក្សីនេះ គឺមិនអាចទទួលយកបានទេ។ សូមអរគុណបាទ។

[១៥:៥៨:១៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

យើងឯកភាពគ្នាហើយ លោកមេធាវី គង់ សំអុន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវនេះដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោកសាក្សី លោកបាននិយាយអំពីមនុស្ស១១នាក់ដែលត្រូវបានសម្លាប់ចោល ដោយសារតែធ្វើតេស្តមិនជាប់។ អ៊ីចឹងតើលោកធ្លាប់ឃើញគេសម្លាប់មនុស្សនៅទំនប់ហ្នឹង នៅជុំវិញស្ពានលេខ១ហ្នឹងទេ? លោកឃើញផ្ទាល់ភ្នែកទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ នៅពេលហ្នឹងសម្រាប់អ្នក១១នាក់ហ្នឹង ខ្ញុំសូមបញ្ជាក់ម្តងទៀត ថាមិនមែនជាកងខ្ញុំទេ គឺនៅក្នុងវរៈ២។ ហើយពេលដែលយោធាគេចង់ធ្វើអី គឺគេយកទៅសម្លាប់ចោលនៅនឹងៗបាតទំនប់ហ្នឹងឯង រួចគេវែកដីកប់។ ហើយសម្រាប់ខ្ញុំហ្នឹង គឺជាអ្នកឆាយដីឲ្យស្មើ ដូច្នេះឆាយដីទៅក៏ឃើញខ្មោចងាប់នៅនឹងទៅ។ បានខ្ញុំថាពិតជាអា១១នាក់ដែល តាវ៉ាល់ បញ្ឆោតឲ្យជាន់ភ្លើងហ្នឹងហើយ។ ពេលនោះខ្ញុំឃើញតែស្លាប់ហើយបាទ។ តែត្រង់គេវាយផ្ទាល់ ឬគេបាញ់ចោល ខ្ញុំមិនដែលបានឃើញទេ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណសហព្រះរាជអាជ្ញាអន្តរជាតិ។ បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៨ ខែសីហា ឆ្នាំ២០១៥ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ឈុំ សេង សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមកាលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ឈុំ សេង ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ឥឡូវនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឈុំ សេង ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យអញ្ជើញគាត់ ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក ឲ្យបាននៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណដែរ ចំពោះលោកមេធាវី ឌុច ផារី មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះក៏សូមអញ្ជើញលោកមកចូលរួមសវនាការក្នុងស្តាប់សក្ខីកម្មសាក្សី ឈុំ សេង នៅថ្ងៃស្អែកទៀត។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលមករួមសវនាការ នៅ

ថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*